**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# **សារណាបញ្ចប់ការសិក្សា**

# **ការបង្កើតក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា**

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយនិស្សិតឈ្មោះ
កញ្ញា **ហាយ ជីលីន**
កញ្ញា **ប៊ឹន ស៊ាងហ៊ា់**

សាស្ត្រាចារ្យណែនាំ
លោកគ្រូ **ភង ស៊ីផាន់ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយនិស្សិតឈ្មោះ
កញ្ញា **ហាយ ឌីលីន**
កញ្ញា **ប៊ឺន ស៊ាងហ៊ង់**

សាស្ត្រាចារ្យណែនាំ
លោកគ្រូ **គង ស៊ីផាន់ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហាយ ជីលីន** និង នាងខ្ញុំឈ្មោះ **ចឹន ស៊ាងហង់** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ជំនាន់ទី ២១ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១។

**សូមសម្ដែងគារវកិច្ច និងកតញ្ញូតាធម៌ជូនចំពោះ**

**លោកឪពុក និងអ្នកម្ដាយ** ជាអ្នកមានគុណយ៉ាងធំធេង ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ ទំនុកបម្រុងកូនតាំងពីតូចក្រូចឆ្មា រហូតដល់កូនអាចបន្តការសិក្សាថ្នាក់បរិញ្ញាបត្រមកដល់សព្វថ្ងៃនេះ។ បើគ្មានការយកចិត្តទុកដាក់ ថ្នាក់ថ្នម ស្រលាញ់ពីអ្នកមានគុណទេ ម្ល៉េះកូនមិនអាចក្លាយខ្លួនជា កូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គមបានឡើយ។ នេះជាគុណូបការៈដ៏វិសេសវិសាលខ្ពង់ខ្ពស់ដែលមិនអាចយកអ្វីមកកាត់ថ្លៃបានឡើយ។

**ឯកឧត្តម បណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រចារ្យទាំងអស់ដែលបានបំពេញការងារ ក្នុងការគ្រប់គ្រង ដឹកនាំ និងបង្ហាត់បង្ហាញផ្លូវ និងជួយតម្រង់ទិសពួកយើងខ្ញុំ ដោយមិនខ្លាចនឿយហត់ដោយអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីចូលរួមបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាពពេញលេញ មុននឹងឈានទៅដល់ការប្រកបវិជ្ជាជីវៈនាថ្ងៃអនាគត។

**លោក កង ស៊ីផាន់ណារ៉ា** ជាសាស្ត្រាចារ្យនៃមហាវិទ្យាល័យនីតិសាស្ត្រដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំ និងជ្រោមជ្រែង រហូតដល់ការរៀបរៀងសារណានេះអាចលេចចេញជាផ្លែផ្កាមក។ ទោះបីជាលោករវល់នឹងកិច្ចការលោកយ៉ាងណាក្ដី ក៏លោកតែងតែផ្ដល់ស្នាមញញឹមរីករាយស្វាគមន៍ជានិច្ច ក្នុងការជួយបង្ហាត់បង្ហាញ និងផ្ដល់មតិដើម្បីកែតម្រូវកំហុសឆ្គងមួយចំនួន ក្នុងការសរសេរសារណានេះ ព្រមទាំងអនុសាសន៍ល្អៗដែលលោកបានផ្ដល់ឲ្យរូបយើងខ្ញុំទាំងពីរដើម្បីយកមកពិចារណា។

ជាកិច្ចចុងក្រោយ យើងខ្ញុំទាំងពីររូប សូមជូនពរឲ្យអ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកបម្រើការងារនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងនិស្សិតទាំងអស់ឲ្យមានសុខភាពល្អ សម្រេចជោគជ័យគ្រប់ភារកិច្ចដូចអ្វីដែលបានប៉ងប្រាថ្នា និងសូមជូនពរឲ្យជួបប្រទះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លាងឃ្លៀតឡើយ។

ដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតពីរូបយើងខ្ញុំទាំងពីរនាក់។

# អារម្ភកថា

ជាកិច្ចចាប់ផ្តើម នាងខ្ញុំឈ្មោះ **ហាយ ជីលីន** និង នាងខ្ញុំឈ្មោះ **ចឹន ស៊ាងហាង** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សា។ រូបយើងខ្ញុំទាំងពីរសូមធ្វើការស្វាគមន៍យ៉ាងកក់ក្តៅដល់ប្រិយមិត្តអ្នកអានគ្រប់ទិសទី ជាពិសេសនិស្សិតជាទីរាប់អាន និងសាស្ត្រចារ្យជាទីគោរព។

សារណានេះមានចំណងជើងថា «**ការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា**» មានគោលបំណងឲ្យអ្នកអានបានយល់ដឹងស៊ីជម្រៅពីសញ្ញាណទូទៅនៃក្រុមហ៊ុន ក៏ដូចជានីតិវិធីនៃការបង្កើតក្រុមហ៊ុន និងទម្រង់ក្រុមហ៊ុនដែលមានវត្តមាននាពេលបច្ចុប្បន្ននេះ។ នេះជាការកើតចេញពីសមិទ្ធផលនៃការខិតខំស្រាវជ្រាវ និងរៀបចំចងក្រងឡើង ដោយផ្អែកលើច្បាប់ និងបទដ្ឋានគតិយុត្តនានា ដើម្បីឲ្យប្រធានបទនេះប្រកបដោយសុក្រិតភាព ហើយម្យ៉ាងវិញទៀត វាក៏ជួយឲ្យនិស្សិតបានសិក្សាផ្នែកមួយជ្រុងនៃបច្ចុប្បន្នភាពនៃច្បាប់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោក គង ស៊ីផាន់ណារ៉ា** ជាសាស្ត្រាចារ្យនៃមហាវិទ្យាល័យនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជំរុញទឹកចិត្ត និងបង្ហាត់បង្ហាញផ្លូវ ឆ្លៀតពេលវេលាក្នុងការណែនាំដល់រូបខ្ញុំទាំងពីររហូតអាចបញ្ចប់ការសរសេរសារណានេះឡើងបាន។

នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើនក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗដែលមានស្រាប់នៅក្នុងបណ្ណាល័យ និងតាមគេហទំព័រផ្សេងៗ ដើម្បីចងក្រងជាសៀវភៅសារណានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះអាចជាចំណែកនៃគុណប្រយោជន៍តូចមួយ ដើម្បីជំនួយដល់ការសិក្សាស្រាវជ្រាវបន្ថែមរបស់និស្សិតជំនាន់ក្រោយដែលមានបំណងក្នុងការសិក្សាស្វែងយល់នូវប្រធាបទនេះ។ យើងខ្ញុំយល់ថា ការសរសេរ និងរៀបរៀងសរសេរសារណានេះ អាចនៅមានចំនុចខ្វះខាតទាំងពាក្យពេចន៍ និងខ្លឹមសារ មិនទាន់ពេញលេញនៅឡើយទេ ដូច្នេះហើយយើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា។ យើងខ្ញុំស្វាគមន៍ទទួលមតិរិះគន់ជានិច្ចពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើជាទុនក្នុងការស្ថាបនាឲ្យសារណានេះកាន់តែមានអត្ថន័យត្រឹមត្រូវ និងកាន់តែប្រសើរថែមមួយកម្រិតទៀត។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរដល់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិត និងអ្នកអានជួបតែសុខដុមរមនា និងជោគជ័យគ្រប់ភារកិច្ច។ យើងខ្ញុំសង្ឃឹមថាយុវជន យុវនារីខ្មែរនឹងខិតខំសិក្សាស្រាវជ្រាវ ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពលក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

# មាតិកា

**សេចក្តីផ្តើម**..........................................................................................................**១**

## ជំពូកទី១

## សញ្ញាណទូទៅនៃការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា

**១.១. ប្រវត្ត**..........................................................................................................**៣**
**១.២. និយមន័យ**..........................................................................................................**៤**
**១.៣. ទម្រង់ក្រុមហ៊ុន** ..........................................................................................................**៥**
១.៣.១. ក្រុមហ៊ុនសហកម្មសិទ្ធិ ..........................................................................................................**៥**
១.៣.២. ក្រុមហ៊ុនមូលធន .......................................................................................................... **៧**
**១.៤. បុគ្គលភាពគតិយុត្តនៃក្រុមហ៊ុន** ..........................................................................................................**៩**
១.៤.១ ការសម្គាល់ក្រុមហ៊ុន ..........................................................................................................**៩**
១.៤.១.១. ឈ្មោះក្រុមហ៊ុន..........................................................................................................**៩**
១.៤.១.២. ការជ្រើសរើសនាមករណ៍របស់ក្រុមហ៊ុន..........................................................................................................**១០**
**១.៥.អត្តិភាពក្រុមហ៊ុន**.......................................................................................... ..............**១១**
**១.៦ កិច្ចសន្យាក្រុមហ៊ុន**.......................................................................................... .......**១២**
១.៦.១ ធាតុផ្សំពិសេសនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន.......................................................................................... ..**១២**
១.៦.២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាក្រុមហ៊ុន ..........................................................................................................**១៥**
១.៦.៣. លក្ខខណ្ឌរំលាយកិច្ចសន្យាក្រុមហ៊ុន..........................................................................................................**១៦**

## ជំពូកទី២

## នីតិវិធី និងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ

**២.១. ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**..........................................................................................................**១៨**
២.១.១. លក្ខណៈទូទៅ ..........................................................................................................**១៨**

២.១.១.១. កម្មវត្ថុ..........១៩
២.១.១.២. អំពីនាមករណ៍..........១៩
២.១.១.៣. អំពីសហកម្មសិទ្ធិករ..........២០
២.១.១.៤. អំពីដើមទុន..........២០
២.១.២. លក្ខណ្ឌទម្រង់..........២១
២.១.២.១. កិច្ចសន្យា និងការផ្សព្វផ្សាយជាសាធារណៈ..........២១
២.១.២.២. លក្ខន្តិកៈក្រុមហ៊ុន..........២២
**២.២. ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត..........២៦**
២.២.១. លក្ខណ្ឌទូទៅ..........២៧
២.២.១.១. អំពីសហកម្មសិទ្ធិករ..........២៧
២.២.១.២. កម្មវត្ថុ..........២៨
២.២.១.៣. អំពីដើមទុន..........២៨
២.២.២. លក្ខណ្ឌទម្រង់..........២៨
២.២.២.១. កិច្ចសន្យា និងការផ្សព្វផ្សាយជាសាធារណៈ..........២៩
២.២.២.២. អ្នកគ្រប់គ្រង..........២៩
**២.៣ ការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ..........៣០**
២.៣.១ ការស្នើសុំអាជ្ញាប័ណ្ណ..........៣០
២.៣.២ ការចុះបញ្ជីក្រុមហ៊ុន..........៣១
២.៣.២.១. កម្រែនៃការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ..........៣២
២.៣.២.២. ឯកសារក្នុងការចុះបញ្ជីពាណិជ្ជកម្ម..........៣៣
២.៣.២.៣. ឯកសារក្នុងការចុះបញ្ជីពន្ធដា..........៣៣
២.៣.២.៤. របៀបនៃការចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន..........៣៤
**២.៥. គុណសម្បត្តិ និង គុណវិបត្តិចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ..........៣៧**

២.៥.១. គុណសម្បត្តិក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត......................................................................... ៣៧
២.៥.២. គុណវិបត្តិក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត .......................................................................... ៣៨
២.៥.៣. គុណសម្បត្តិក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ............................................................................... ៣៨
២.៥.៤. គុណវិបត្តិក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ............................................................................... ៣៨

**ជំពូកទី៣**

**នីតិវិធី និងការបង្កើតក្រុមហ៊ុនមូលធន**

**៣.១. ការបង្កើតក្រុមហ៊ុនមូលធន** ........................................................................................ ៤០
៣.១.១. លក្ខណៈគ្រឹះ ............................................................................................................ ៤១
៣.១.១.១. ការព្រមព្រៀង.................................................................................................... ៤១
៣.១.១.៣. សមត្ថភាពរបស់សមាជិក....................................................................................... ៤១
៣.១.១.៤. អំពីដើមទុន...................................................................................................... ៤២
៣.១.១.៥. អំពីនាមករណ៍.................................................................................................... ៤៣
៣.១.២. លក្ខណៈទម្រង់ និងការផ្សព្វផ្សាយជាសាធារណៈ ............................................................ ៤៣
៣.១.២.១. លក្ខន្តិកៈក្រុមហ៊ុន និងការតម្កល់.......................................................................... ៤៣
៣.១.២.២. លិខិតជាលាយលក្ខណ៍អក្សរ................................................................................. ៤៤
៣.១.២.៣. មហាសន្និបាតបង្កើតក្រុមហ៊ុន............................................................................... ៤៥
**៣.២. ការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីពាណិជ្ជកម្ម** ......................................................... ៤៦
**៣.៣. ការរំលាយក្រុមហ៊ុនមូលធន** ....................................................................................... ៤៧
៣.៣.១. មូលហេតុនៃការរំលាយក្រុមហ៊ុន.................................................................................. ៤៨
៣.៣.២. ការរំលាយដោយស្ម័គ្រចិត្ត .......................................................................................... ៤៨
៣.៣.៣. រំលាយដោយតុលាការ................................................................................................ ៤៨
៣.៣.៤. ការជម្រះបញ្ជី........................................................................................................... ៤៩
**៣.៤. គុណសម្បត្តិ និងគុណវិបត្តិនៃការបង្កើតក្រុមហ៊ុនមូលធន** ................................................ ៤៩

៣.៤.១. គុណសម្បត្តិ.......................................................................................................៤៩
៣.៤.២. គុណវិបត្តិ.........................................................................................................៥០
**សេចក្តីសន្និដ្ឋាន**...........................................................................................................**៥២**
**អនុសាសន៍**...................................................................................................................**៥៤**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បុគ្គលគ្រប់រូបតែងតែមានគម្រោងគិតទុកជាមុនអំពីអនាគតរបស់ខ្លួន ហើយបុគ្គលភាគច្រើនចង់ធ្វើជាមនុស្សដែលមានការរំពឹងលើខ្លួនឯង ត្រង់នេះគឺសំដៅទៅលើការប្រកបកិច្ចការរកស៊ី និងការធ្វើជំនួញ។ ពាណិជ្ជករដែលគ្រប់គ្រងពាណិជ្ជកម្មត្រូវតែជាបុគ្គលដែលមាន ធនធានចំណេះដឹង និងសមត្ថភាពតាមផ្លូវច្បាប់ ទើបមានសិទ្ធិប្រកបលើអាជីវកម្មនោះបាន។ ការប្រកបអាជីវកម្មដោយខ្លួនឯងគឺមានសេរីភាព គ្មានការគៀបសង្កត់ផ្លូវចិត្ត ផ្លូវការ ពីនរណាម្នាក់ឡើយ។ ប៉ុន្តែបុគ្គលមួយចំនួនទៀតមិនបានគិតដូចគ្នាទេ គេចង់ធ្វើការយកប្រាក់ខែពីថៅកែវិញងាយស្រួល និងមិនស្មុគស្មាញ។ ហើយវាពិតជាល្អ ប្រសិនបើមានបុគ្គលភាគច្រើនចង់ប្រកបអាជីវកម្មដោយខ្លួនឯងបែបនេះ ព្រោះថាវាជាផ្នែកមួយដែលជួយដល់សេដ្ឋកិច្ចជាតិផងដែរ។

បុគ្គលគ្រប់រូប មិនថារូបវន្តបុគ្គល ឬនីតិបុគ្គលទេ គឺសុទ្ធតែមានសិទ្ធិប្រកបអាជីវកម្មដោយខ្លួនឯងបាន ដោយពួកគេត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគោរពនូវវិធានគតិយុត្តមួយចំនួនដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធនៃវិស័យពាណិជ្ជកម្មដែលមានជាធរមាន ដូចជាច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ ២០០៧ និងសេចក្តីប្រកាសជាច្រើនទៀត។ ចំពោះរូបវន្តបុគ្គលណាដែលគ្មានលទ្ធភាពក្នុងការបង្កើត ឬដំណើរការអាជីវកម្មតែម្នាក់ឯង រូបវន្តបុគ្គលនោះអាចស្វែងរកដៃគូរដើម្បីដាក់ចូលនូវភាគហ៊ុនរួមគ្នាដើម្បីរកប្រាក់ចំណេញរួមគ្នាដោយបង្កើតជាប្រភេទក្រុមហ៊ុនមួយដែលមានទម្រង់ណាមួយដែលខ្លួនអាចគ្រប់គ្រង និងទទួលខុសត្រូវបាន។ ដោយហេតុថាការបង្កើតក្រុមហ៊ុនគឺត្រូវការត្រួតពិនិត្យមើលទៅលើច្រើនចំណុច និងត្រូវកំណត់ឱ្យបានថា អាជីវកររូបនោះ ចង់បើកប្រភេទក្រុមហ៊ុនបែបណា និងត្រូវបំពេញលក្ខន្តិកៈឱ្យបានត្រឹមត្រូវ ក៏ដូចជាការកំណត់សិទ្ធិកាតព្វកិច្ចយ៉ាងដូចម្តេចទើបមិនមានការបំពាននៅក្នុងកិច្ចសន្យា ក៏ដូចជានីតិវិធីនៃការបង្កើតក្រុមហ៊ុនត្រូវប្រព្រឹត្តទៅបែបណា។

ប្រជាពលរដ្ឋមួយចំនួនតូចពួកគាត់មិនសូវយល់ច្បាស់ទាក់ទងនឹងការបង្កើតក្រុមហ៊ុន ដោយសារចំណេះដឹងមានកម្រិត។ នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ មានចែងទាក់ទងនឹងការបង្កើតក្រុមហ៊ុន ដែលបទប្បញ្ញត្តិនេះដែរគឺទាក់ទងទៅនឹងប្រធានបទនៃការស្រាវជ្រាវមួយនេះ។ ការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជាគឺជាផ្នែកមួយនៃនីតិពាណិជ្ជកម្ម ដែលស្ថិតនៅក្នុងវិស័យឯកជន។ ការបង្កើតក្រុមហ៊ុនក្នុងស្រុកអាចជួយដល់សេដ្ឋកិច្ចជាតិ ជាពិសេសជួយទៅដល់អាជីវករ ក្នុងការគ្រប់គ្រងនូវអាជីវកម្មរបស់ខ្លួន ប្រសិនបើអាជីវករទាំងនោះបានបង្កើតស្របតាមច្បាប់ជាធរមាន ពួកគេនឹងទទួលបានការគាំពារពីច្បាប់ ការលើកទឹកចិត្តដោយរាជរដ្ឋាភិបានធ្វើអនុម័តច្បាប់ស្តីពីការបន្ធូរបន្ថយពន្ធដារ ដើម្បីលើទឹកចិត្តវិនិយោគគិន និងជួយស្វែងរកដំណោះស្រាយពេលជួបនូវបញ្ហា។ ការស្រាវជ្រាវនេះ មានគោលបំណងបង្ហាញអំពី នីតិវិធីនៃការ

បង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា អ្នកដែលអាចបង្កើតក្រុមហ៊ុនបាន ការចុះបញ្ជីក្រុមហ៊ុននៅក្នុងក្រសួងពាក់ព័ន្ធ គុណសម្បត្តិ និងគុណវិបត្តិនៃការបង្កើតក្រុមហ៊ុននីមួយៗ ការត្រួតពិនិត្យទៅលើលក្ខន្តិកៈនៃក្រុមហ៊ុន ក៏ដូចជាសិទ្ធិ និងករណីកិច្ចម្ចាស់ភាគហ៊ុនដោយផ្សាភ្ជាប់ទៅទ្រឹស្តី ទៅនឹងទិដ្ឋភាពបច្ចុប្បន្ន។ វិសាលភាពនៃការស្រាវជាវក្នុងសារណានេះ កម្រិតត្រឹមការបង្កើតក្រុមហ៊ុន នៃព្រះរាជាណាចក្រកម្ពុជា ការចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មកដូចជាក្រសួងពាក់ព័ន្ធ ការតាក់តែងលក្ខន្តិកៈក្រុមហ៊ុន ការរំលាយក្រុមហ៊ុន ដោយផ្អែកលើ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥ និង ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧ ក៏ដូចជាបទដ្ឋានគតិយុត្ត ប្រកាសដែលដែលពាក់ព័ន្ធដទៃទៀតដែលមានជាធរមាន និងសៀវភៅសាស្ត្រាចារ្យមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទមួយនេះផងដែរ។ ដើម្បីបកស្រាយទៅលើប្រធានបទ ការបង្កើតក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានកាន់តែច្បាស់លាស់គ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងបទដ្ឋានគតិយុត្តដូចដែលបានរៀបរាប់ខាងលើ ការស្រាវជ្រាវត្រូវបានបែងចែកដូចខាងក្រោម៖

ជំពូកទី១ ៖ សញ្ញាណទូទៅនៃការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា

ជំពូកទ២ ៖ នីតិវិធី និងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ

ជំពូកទី៣ ៖ នីតិវិធី និងការបង្កើតក្រុមហ៊ុនមូលធន

# ជំពូកទី១
# សញ្ញាណទូទៅនៃការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា

នៅក្នុងទំនាក់ទំនងធ្វើពាណិជ្ជកម្មសម្រាប់ជីវភាពរស់នៅសព្វថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ។ ច្បាប់នេះក៏មានអានុភាពផងដែរទៅលើការបង្កើតក្រុមហ៊ុន នេះមានន័យថាបើមានរូបវន្តបុគ្គល ឬនីតិបុគ្គលណាចង់បង្កើតក្រុមហ៊ុនមួយដោយស្របតាមច្បាប់ដែលមានចែង គឺត្រូវគោរពតាមគោលការណ៍ និងវិធានដែលមានចែងនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥។

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ គឺសុទ្ធតែអាចបង្កើតក្រុមហ៊ុនដែលអនុលោមតាមច្បាប់បានដើម្បីធ្វើអាជីវកម្មសម្រាប់ជីវភាពប្រចាំថ្ងៃរបស់ពួកគេបាន ដោយគ្រាន់តែត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន។ ដោយឃើញថាការបង្កើតក្រុមហ៊ុនត្រូវមាននីតិវិធីមួយចំនួនត្រូវបំពេញ និងមានលក្ខណៈស្មុគស្មាញ ដូច្នេះយើងធ្វើការលើកយកប្រធានបទមួយដែលនិយាយអំពី *"ការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជា"* មកធ្វើការសិក្សាស្រាវជ្រាវ សម្រាប់សារណាមួយនេះ។ ដើម្បីសិក្សាអំពីប្រធានបទ ការបង្កើតក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានស៊ីជម្រៅ យើងគួតែសិក្សាជាមូលដ្ឋានទៅលើប្រធាន ជាមុនសិនដែលការសិក្សានោះគឺជាចំណុចនៃសញ្ញាណទូទៅនៃការបង្កើតក្រុមហ៊ុន។ នៅក្នុងនោះយើងនឹងសិក្សាទៅលើចំណុចមួយចំនួនដូចជា៖ ប្រវត្តិ (១.១) និយមន័យ (១.២) ទម្រង់ក្រុមហ៊ុន (១.៣) បុគ្គលភាពគតិយុត្តនៃក្រុមហ៊ុន (១.៤) អត្ថិភាពក្រុមហ៊ុន(១.៥) និងកិច្ចសន្យាក្រុមហ៊ុន (១.៦)។

## ១.១. ប្រវត្តនៃការបង្កើតក្រុមហ៊ុន

ដើមឡើយ ក្រុមហ៊ុនពាណិជ្ជកម្មដែលចាប់បដិសន្ធិដំបូងនៅកម្ពុជា បានបង្កើតឡើងតាមបញ្ញត្តិនៃក្រមពាណិជ្ជកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៥០។ ថ្វីបើ ក្រមនេះត្រូវបានធ្វើវិសោធនកម្មជាច្រើនលើកច្រើនសារក៏ដោយ ក៏ទម្រង់ក្រុមហ៊ុននៅសម័យនោះនៅតែជាទម្រង់ក្រុមហ៊ុនតាមប្រព័ន្ធច្បាប់បារាំងដែរ។ ទម្រង់ក្រុមហ៊ុនទាំងនោះរួមមាន ក្រុមហ៊ុនអនាមិក ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនចម្រុះ ក្រុមហ៊ុនសមូហនាម ក្រុមហ៊ុនបុគ្គល និងសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។ សញ្ញាណក្រុមហ៊ុនទាំងអស់នេះ ត្រូវបានគេបោះបង់ចោលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥-១៩៧៨ ប៉ុន្តែ សញ្ញាណនេះមានសាជាថ្មីបន្ទាប់ពីការដួលរលំរបបនេះទៅ ក្រុមហ៊ុនសហគ្រាសថ្មីនោះបានស្តែងឡើង

ក្រោមរូបភាពជាក្រុមហ៊ុន ឬសហគ្រាសរដ្ឋ គឺ ភាគហ៊ុនទាំងអស់ ឬភាគច្រើនដាច់ខាតត្រូវបានកាន់កាប់ដោយរដ្ឋ។ ដោយហេតុថាមានការផ្លាស់ប្ដូរនូវរបបសេដ្ឋកិច្ចពិភពលោក ម្យ៉ាងដោយសារការបរាជ័យផ្នែកសេដ្ឋកិច្ចរបស់វា។

## ១.២. និយមន័យ

មុននឹងធ្វើការសិក្សាទៅលើប្រធានបទដែលនិយាយអំពី ការបង្កើតក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា គប្បីយល់នូវនិយមន័យនៃពាក្យថា "ក្រុមហ៊ុន" ជាមុនសិន៖

ពាក្យថា "ក្រុមហ៊ុន" មានន័យថា ក្រុមហ៊ុនគឺជាកិច្ចសន្យារវាងបុគ្គលពីរនាក់ ឬ ច្រើននាក់ ដែលព្រមព្រៀងគ្នាដាក់រួមនូវភាគទុនរៀងៗខ្លួន ដើម្បីផលចំណេញជាសាច់ប្រាក់ ដែលត្រូវចែកគ្នាសមាមាត្រទៅនឹងចំនួនភាគទុន។

ឬម្យ៉ាងទៀត ពាក្យថា "ក្រុមហ៊ុន" មានន័យថា ក្រុមហ៊ុនពាណិជ្ជកម្ម = ក្រុមហ៊ុន+ពាណិជ្ជកម្ម ឬពាណិជ្ជកិច្ច។ ក្រុមហ៊ុនត្រូវបានគេឱ្យនិយមន័យថាជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលព្រមព្រៀងគ្នាដាក់រួមនូវទ្រព្យសម្បត្តិ សេវា ចំណេះដឹង ឬសកម្មភាពផ្សេងៗ ដើម្បីប្រកបរបរអ្វីមួយក្នុងគោលបំណងរកផលចំណេញ ប៉ុន្តែ ក្រុមហ៊ុនក៏អាចផ្ដើមចេញពីឆន្ទៈរបស់ឯកបុគ្គលបានដែរគឺក្រុមហ៊ុនឯកបុគ្គល ឬក្រុមហ៊ុនឯកត្តនាម។[1]

រីឯពាក្យថាពាណិជ្ជកិច្ចត្រូវបានច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឱ្យនិយមន័យថា ជាសកម្មភាពទិញ លក់ទំនិញ ឬសេវាដែលត្រូវអនុវត្តជាប្រចាំក្នុងគោលបំណងដោះដូរ និងស្វែងរកផលចំណេញ។ ម្យ៉ាងទៀត នីតិបុគ្គល នៃនីតិឯកជន មានបេតិកភណ្ឌផ្ទាល់ខ្លួន និងមានសមត្ថភាពគតិយុត្តប្រព្រឹត្តក្នុងនាម និងដើម្បីផលប្រយោជន៍សមូហភាព។[2]

តាមរយៈការបកស្រាយខាងលើ ក្រុមហ៊ុនពាណិជ្ជកម្ម គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលព្រមព្រៀងគ្នាដាក់រួមនូវទ្រព្យសម្បត្តិ សេវា ចំណេះដឹង ឬសកម្មភាពផ្សេងៗ ដើម្បីប្រកបពាណិជ្ជកិច្ចក្នុងគោលបំណងរកផលចំណេញ។

[1] ឯកឧត្តមសាស្ត្រាចារ្យ កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥), ៣

[2] ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ២៦ មិថុនា ១៩៩៥, មាត្រា១

## ១.៣. ទម្រង់ក្រុមហ៊ុន

ការដែលធ្វើការសម្រេចចិត្តជ្រើសរើសថាត្រូវបង្កើតក្រុមហ៊ុនប្រភេទណា វាជារឿងសំខាន់បំផុតសម្រាប់ម្ចាស់ក្រុមហ៊ុនផ្ទាល់ ព្រោះថាការជ្រើសប្រភេទ ឬក៏ទម្រង់ក្រុមហ៊ុននេះគឺវាបញ្ជាក់អំពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនត្រឹមកម្រិតណា ហើយម្ចាស់ក្រុមហ៊ុនខ្លួនឯងអាចជ្រើសរើសទម្រង់ក្រុមហ៊ុនណាមួយដែលខ្លួនអាចគ្រប់គ្រងបានទៅតាមលទ្ធភាពរបស់ខ្លួន។ មូលហេតុនៃការជ្រើសរើសយកទម្រង់ណាមួយ គឺមានភាពទូលំទូលាយ ដោយសារគ្មានទម្រង់ណាមួយ ដែលសាកសមសំរាប់បុគ្គលគ្រប់គ្នាបានទេ។ នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ក្នុងនោះរួមមានទម្រង់ក្រុមហ៊ុនចំនួនពីរធំៗ គឺក្រុមហ៊ុនសហកម្មសិទ្ធិ និង ក្រុមហ៊ុនមូលធន ហើយនៅក្នុងទម្រង់នៃក្រុមហ៊ុនខាងលើនេះ មានប្រភេទក្រុមហ៊ុនតូចៗពីរ ផ្សេងគ្នាគ្នាទៀត។ ក្រុមហ៊ុនសហកម្មសិទ្ធិ មាន ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត រីឯក្រុមហ៊ុនមូលធនវិញមាន ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ហើយយើងមើលឃើញក្រុមហ៊ុនទម្រង់ផ្សេងទៀត ដូចជា សហគ្រាសឯបុគ្គលជាដើម តែយើងមិនធ្វើការផ្តោតទៅលើទម្រង់ក្រុមហ៊ុនមួយនេះទេ គឺយើងធ្វើការផ្តោតទៅលើទម្រង់ក្រុមហ៊ុនដែលមានចែងនៅក្នុងច្បាប់ពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ តែប៉ុណ្ណោះ ដូចដែលបានរៀបរាប់ខាងលើ។

### ១.៣.១. ក្រុមហ៊ុនសហកម្មសិទ្ធិ

ក្រុមហ៊ុនសហកម្មសិទ្ធិ គឺជាទម្រង់អាជីវកម្ម ដែលជាទីពេញនិយមរបស់អ្នកមានវិជ្ជាជីវៈដូចជាវេជ្ជបណ្ឌិត មេធាវី និងគណនេយ្យករ។ គេអាចប្រើឧបករណ៍រួមគ្នា ដែលសនាកម្មសិទ្ធិករមិនមានប្រាក់ទិញបាន។ ទម្រង់នេះក៏ជាប្រភេទដែលអាជីវកម្មតូចៗនិយមប្រើជាងគេដោយសារវាផ្តល់លទ្ធភាពឱ្យមានទុនចាប់ផ្តើម និងប្រមូលជំនាញពីមនុស្សច្រើននាក់បាន។ ដូចគ្នានឹងពាណិជ្ជករឯកជនដែរ សហកម្មសិទ្ធករតែងតែប្រមូលភាគទុន តាមរយៈកម្ចីពីធានាគារ និងទទួលខុសត្រូវចំពោះក្រុមហ៊ុន។ សមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានឋានៈជាពាណិជ្ជករ។ ចំពោះការទទួលខុសត្រូវគឺមិនមានកំណត់ទេ គឺសាមគ្គីគ្នាទូទាត់លើរាល់បំណុលរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនសហកម្មសិទ្ធិ មានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។[3]

[3] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១

### ១.៣.១.១. ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពបុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ។[4] សហកម្មសិទ្ធិទូទៅករត្រូវទទួលខុសត្រូវរួមគ្នា និងគ្មានកម្រិតចំពោះបំណុលក្រុមហ៊ុន សហកម្មសិទ្ធិករទូទៅម្នាក់ៗ មានសិទ្ធិស្មើគ្នាក្នុងការចាត់ចែងអាជីវកម្ម លើកលែងតែមានការបញ្ជាក់ផ្សេងក្នុងកិច្ចព្រមព្រៀងរបស់សហកម្មសិទ្ធិករ។ ក្នុងករណីដែលមានការផ្ទេរកម្មសិទ្ធិភាគហ៊ុន គឺត្រូវមានការព្រមព្រៀងជាឯកច្ឆ័ន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់។

### ១.៣.១.២. ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែលមានបុគ្គលម្នាក់ ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករនោះ។[5] ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិតអាចជាទឹកប្រាក់ ឬជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ។ សហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថា នឹងផ្តល់សេវានាពេលអនាគត។[6] សហកម្មសិទ្ធិករម្នាក់ៗ មានសិទ្ធិទទួលចំណែកនៃប្រាក់ចំណេញរបស់ខ្លួន។ ប៉ុន្តែប្រសិនបើការទទួលប្រាក់ចំណេញនោះ នៅតែធ្វើឱ្យមានឱនភាពដល់ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតដែលបានទទួលចំណែកនៃប្រាក់ចំណេញនោះ ត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញ ចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ដើម្បីទប់ទុលទៅនឹងឱនភាពភាគទុនរបស់ខ្លួន។[7] ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនេះ គឺមានលក្ខណៈពីរយ៉ាងនៃការទទួលខុសត្រូវ គឺគ្មានកម្រិតផង និងទទួលខុសត្រូវមានកម្រិតផង មានន័យថា នៅក្នុងក្រុមហ៊ុនតែមួយមានសហកម្មសិទ្ធិករខ្លះទទួលខុសត្រូវមានកម្រិត និងសហកម្មសិទ្ធិករខ្លះទទួលខុសត្រូវគ្មានកម្រិត។ សហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវទៅលើតែចំនួនទឹកប្រាក់ ឬតម្លៃនៃទ្រព្យសម្បត្តិ ដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុន

---

[4] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨

[5] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៦៤

[6] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧០

[7] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧១

ប៉ុណ្ណោះ។[8] ប៉ុន្តែបើយើងក្រឡេកទៅមើលមាត្រា ៧៤ ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មវិញ បានចែងថា "សហកម្មសិទ្ធិករទូទៅ មានសិទ្ធិនិងកាព្វកិច្ចដូចជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ"។ ដូច្នេះ មានន័យថាការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺមិនដូចគ្នានឹងសហកម្មសិទ្ធិករមានកម្រិតទេ។ ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនេះ គឺវាអាចឲ្យមនុស្សម្នាក់ ឬមនុស្សមួយក្រុម ដែលមានចំណេះដឹង មានជំនាញ ប៉ុន្តែ មិនមានដើមទុនគ្រប់គ្រាន់ អាចទៅសហការគ្នាជាមួយមនុស្សម្នាក់ ឬមួយក្រុមទៀត ដែលមិនមានជំនាញ ដែលមានដើមទុន ដើម្បីបង្កើតក្រុមហ៊ុនប្រកបអាជីវកម្មរួមគ្នា។ ឬមួយក៏ក្នុងករណី ដែលបានបង្កើតជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួចហើយ ឃើញថាការរកស៊ីក៏បានកាក់កប អាជីវកម្មមានសក្តានុពល ហើយចង់ពង្រីកអាជីវកម្មនេះថែមទៀត ប៉ុន្តែ ខ្វះទុនសមាជិកក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះអាចទៅស្វះស្វែងរកអ្នកមានទុនឲ្យមកចូលរួមសហការគ្នា ហើយប្តូរទម្រង់ក្រុមហ៊ុន បង្កើតទៅជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន។

### ១.៣.២. ក្រុមហ៊ុនមូលធន

ក្រុមហ៊ុនមូលធន គឺជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ឬសាជីវកម្ម ត្រូវបានគ្រប់គ្រងដោយអ្នកគ្រប់គ្រងនិងអភិបាល នឹងផ្តល់មូលនិធិដោយដើមទុនដែលផ្តល់ឱ្យដោយម្ចាស់ហ៊ុន។ វាអាចជាក្រុមហ៊ុនមានម្ចាស់តែម្នាក់ ឬច្រើននាក់។ ក្រុមហ៊ុនមួយនេះមានបុគ្គលភាពដាច់ដោយឡែកពីអ្នកដែលចូលភាគហ៊ុន ការទទួលខុសត្រូវមានកម្រិតនៃសមាជិកហ៊ុន ភាគហ៊ុនអាចផ្ទេរបានដោយសេរីពីម្ចាស់ហ៊ុនមួយទៅអ្នកផ្សេងទៀត លើកលែងតែក្រុមហ៊ុនមានឧបញ្ញាត្តិនៃការផ្ទេរនោះ។[9] ហ៊ុនផ្តល់នូវគម្រោងការងារសម្រាប់អាជីវកម្មដើម្បីធ្វើជាម្ចាស់ទ្រព្យសម្បត្តិ ចុះកិច្ចសន្យា និងភ្ជាប់កាព្វកិច្ចតាមផ្លូវច្បាប់ ដើម្បីជៀសវាងការដាក់ទ្រព្យសកម្មរបស់ម្ចាស់ហ៊ុនក្នុងភាពហានិភ័យ។ ក្រុមហ៊ុនត្រូវជាប់ពន្ធលើទ្រព្យសម្បត្តិប្រាក់ចំណូល ការលក់ និងពន្ធផ្សេងៗទៀតដែលអាចមាន។ ដោយសារតែក្រុមហ៊ុនមូលធនមានលក្ខណៈជានីតិបុគ្គល ដូច្នេះវាត្រូវទទួលខុសត្រូវលើបំណុលរបស់ខ្លួនទាំងអស់។ លើកលែងតែក្នុងករណីមានការក្លែងបន្លំ ឬការធ្វេសប្រហែស ម្ចាស់ហ៊ុន អភិបាល និងអ្នកគ្រប់គ្រង មិនទទួលខុសត្រូវដោយផ្ទាល់ចំពោះបំណុលទាំងនេះទេ។ ក្រុមហ៊ុនត្រូវបានបង្កើតឡើងតាមរយៈដំណើរការរួម ដែលតម្រូវឱ្យដាក់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនទៅកាន់ក្រសួងពាណិជ្ជកម្ម។ ម្ចាស់ហ៊ុនទទួលខុសត្រូវត្រឹមកម្រិតនៃចំនួនទឹកប្រាក់ ដែលនៅសល់នៃចារឹកលើប័ណ្ណនៃភាគហ៊ុនរបស់គេ។

[8] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧២

[9] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨៧

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺជាទម្រង់អាជីវកម្មតាមផ្លូវច្បាប់ ឬម្យ៉ាងទៀតគេអាចហៅថាជាបុគ្គលសិប្បនិម្មិត ឬ បុគ្គលតាមការសន្មត់របស់ច្បាប់ ដែលគេនិយមប្រើបំផុត។[10] នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើត ហៅថា "សាជីវកម្ម" វាមានលក្ខណៈផ្លូវច្បាប់ដាច់ដោយឡែក និងឯករាជ្យភាពអំពីម្ចាស់ហ៊ុនរបស់វានឹងអាចចុះកិច្ចសន្យា និងប្ដឹងគេ ឬគេប្ដឹងក្នុងនាមក្រុមហ៊ុន។ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត មានដំណើរការជានិរន្តន៍ មានន័យថា វានៅតែដំណើរការរហូតទោះបីមរណៈភាព ការដកខ្លួនចេញ ឬការចូលនិវត្តន៍ របស់ម្ចាស់ហ៊ុនរហូតដល់មានការរំលាយស្របតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ នៅក្នុងក្រុមហ៊ុននេះមានទម្រង់ក្រុមហ៊ុនពីរប្រភេទគឺ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និង ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

#### ១.៣.២.១. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត សមាជិកទាំងឡាយនៃក្រុមហ៊ុនត្រូវទទួលខុសត្រូវត្រឹមកម្រិតភាគទុនរបស់ខ្លួនដែលបានដាក់ចូលប៉ុណ្ណោះ ចំណុចដែលងាយក្នុងការកត់សម្គាល់នោះ គឺក្រុមហ៊ុននេះមានសមាជិកចាប់ពី ០២ (ពីរនាក់) រហូតដល់ ៣០ (សាមសិបនាក់)។ ប៉ុន្តែ បុគ្គលម្នាក់ក៏អាចបង្កើតបានដែរ ដោយច្បាប់បានឱ្យឈ្មោះថា សហគ្រាសឯកជនបុគ្គលទទួលខុសត្រូវមានកម្រិត។ សហគ្រាសនេះមានលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្ដីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុនប៉ុណ្ណោះ។ ក្រុមហ៊ុននេះមិនអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬមូលបត្រដទៃជាសាធារណៈឡើយ ប៉ុន្តែ គេអាចអនុញ្ញាតឱ្យធ្វើអនុប្បទានពីសមាជិកភាគហ៊ុនមួយទៅសមាជិកភាគហ៊ុនមួយទៀតបាន ឬសមាជិកគ្រួសារ ឬអ្នកគ្រប់គ្រងបាន។ ក្នុងករណីធ្វើអនុប្បទានទៅឱ្យតតិយជន គេត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃតាមសម្លេងភាគច្រើន។ ចំពោះក្រុមហ៊ុននេះដើម្បីទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺគិតចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ ដូចដែលបានកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។[11]

#### ១.៣.២.២. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុននេះមិនសូវមានលក្ខណៈខុសគ្នាពីក្រុមហ៊ុនឯក

[10] ក្រសួងពាណិជ្ជកម្ម, សៀវភៅ ស្ដីអំពីក្រុមហ៊ុមមហាជន ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសហកម្មសិទ្ធិ, (ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម), ១០

[11] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨៦

ជនទទួលខុសត្រូវមានកម្រិតទេ ប៉ុន្តែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥ ដើម្បីបោះចេញមូលប័ត្រលក់ជាសាធារណៈបាន។[12] ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុន ត្រូវបានកម្រិតចំនួនដើមទុននៃភាគហ៊ុនដែលពួកគេកាន់កាប់។ គោលបំណងនៃការអនុញ្ញាតឱ្យបោះប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងការកម្រិតការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុន ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងដាក់លាក់ក្នុងលក្ខន្តិកៈក្រុមហ៊ុន។

## **១.៤. បុគ្គលភាពគតិយុត្តនៃក្រុមហ៊ុន**

ដូចដែលបានឃើញហើយ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្នុងករណីដែលបានចុះបញ្ជីពាណិជ្ជកម្មរួច ក្រុមហ៊ុននេះបានក្លាយជានីតិបុគ្គល។ ប៉ុន្តែ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនមែនជានីតិបុគ្គលដាច់ដោយឡែកពីសមាជិកក្រុមហ៊ុនទេ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានបុគ្គលភាពជានីតិបុគ្គលក្នុងគោលបំណងមួយចំនួនតែប៉ុណ្ណោះ ដូចជាអាចធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ ធ្វើអាជីវកម្មក្នុងនាមខ្លួន មិនមែនក្នុងនាមសមាជិក អាចចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន និងអាចប្តឹង ឬត្រូវគេប្តឹងក្នុងនាមជាក្រុមហ៊ុន។[13] ប៉ុន្តែការទទួលខុសត្រូវមិនត្រូវបានញែកដាច់រវាងក្រុមហ៊ុន និងសមាជិកក្រុមហ៊ុនទេ។

ផ្ទុយទៅវិញ ក្រុមហ៊ុនមូលធនមានបុគ្គលភាពដាច់ដោយឡែកពីសមាជិក ឬ ម្ចាស់ភាគហ៊ុនដែលបង្កើតក្រុមហ៊ុននោះ សូម្បីតែក្រុមហ៊ុននោះមានសមាជិកតែម្នាក់ក៏ដោយ។ ភាពជានីតិបុគ្គលកើតមានចាប់ពីថ្ងៃដែលក្រុមហ៊ុននោះចុះបញ្ជីត្រឹមត្រូវជាមួយក្រសួងពាណិជ្ជកម្ម ។

### **១.៤.១ ការសម្គាល់ក្រុមហ៊ុន**

#### **១.៤.១.១ ឈ្មោះក្រុមហ៊ុន**

ដូចគ្នានឹងរូបវន្តបុគ្គលដែរ ក្រុមហ៊ុនក៏ត្រូវមានឈ្មោះ គេអាចហៅឈ្មោះនោះថាជា យីហោ ឬ នាមករណ៍ ក្រុមហ៊ុន។ វាអាចគេហៅតាមកម្មវត្ថុរបស់ក្រុមហ៊ុន ការដាក់ឈ្មោះក្រុមហ៊ុនគួរតែមានការប្រុងប្រយ័ត្នជាពិសេសផងដែរចំពោះការដាក់ឈ្មោះដែលច្រឡំនឹងសកម្មភាព ដែលត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ឬដែលត្រូវហាមឃាត់ ឬខ្លាចមានការដាក់ស្នួនជាដើម។[14] នាមករណ៍ក្រុមហ៊ុន អាចត្រូវបានគេដាក់ឈ្មោះតាម

---

[12] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨៧

[13] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១២

[14] ឯកឧត្តមសាស្ត្រាចារ្យ កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥), ១៥០

នណាម្នាក់ ឬច្រើននាក់ ឬយកឈ្មោះតាមប្រទេស។ យីហោ ឬ នាមករណ៍ ក្រុមហ៊ុន ទោះបីមានការដាក់ឈ្មោះបែបណាក៏ដោយ ក៏ត្រូវមានចែងនៅក្នុងលក្ខន្តិកៈឱ្យបានច្បាស់លាស់ផងដែរ។

### ១.៤.១.២. ការជ្រើសរើសនាមករណ៍របស់ក្រុមហ៊ុន

ការជ្រើសរើសនាមករណ៍គឺជាសេរីភាពរបស់អ្នកចូលហ៊ុនទាំងអស់គ្នា តែនៅក្នុងដែនកំណត់មួយដែលឈ្មោះនោះមិនប៉ះពាល់ដល់នរណាម្នាក់ ដែលជាបុព្វហេតុនាំឱ្យមានការប្ដឹងតវ៉ានៅពេលណាមួយ ក្នុងនោះគេត្រូវមានការប្រុងប្រយ័ត្នផងដែរចំពោះការដាក់ជាន់លើឈ្មោះដែលមានស្រាប់។ ហេតុនេះ វាទាមទារឱ្យមានការពិនិត្យ និងស្រាវជ្រាវតាមលទ្ធភាពដែលខ្លួនមាន។ ប៉ុន្តែបច្ចុប្បន្ន យើងឃើញថាចំណុចនេះវាលែងជាបញ្ហាធំសម្រាប់អាជីវករដែលចង់ចុះបញ្ជីក្រុមហ៊ុនទៀតហើយព្រោះថា អ្នកអាចស្នើសុំឆែកមើលឈ្មោះជាមុន ថាតើឈ្មោះនោះនៅទំនេរ ឬមិនទំនេរ ប្រសិនបើឈ្មោះនោះនៅទំនេរអ្នកអាចធ្វើការចុះបញ្ជីនូវឈ្មោះដែរអ្នកបានជ្រើសរើសនោះបាន ហើយចំពោះការឆែកនេះដែរគឺគ្រាន់តែធ្វើការវាយឈ្មោះក្រុមហ៊ុនដែលអ្នកចង់ដាក់នោះ ទៅក្នុងប្រព័ន្ធ នោះវានឹងបង្ហាញមកវិញភ្លាមៗថាឈ្មោះនោះត្រូវបានគេដាក់រួចហើយឬនៅ។

ក្រុមហ៊ុនពាណិជ្ជកម្ម ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ។ នាមករណ៍ជាភាសាខ្មែរត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងនាមករណ៍ជាភាសាដទៃទៀត។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតត្រូវមានសូរស័ព្ទដូចគ្នា។

ក្រុមហ៊ុនអាជីវកម្ម ត្រូវចារឹកនាមករណ៍ជាភាសាខ្មែរនៅផ្នែកខាងលើនៃត្រា សញ្ញាក្បាលលិខិត បែបបទឯកសារ ឬឯកសារដែលប្រើប្រាស់ជាសារធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មសាធារណៈដែលតាំងនៅលើដែនដីទឹក ឬដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[15]

ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ។ នាមករណ៍ជាភាសាខ្មែរត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងភាសាដទៃទៀតប្រសិនបើមាន។ ការបកប្រែន័យរបស់នាមករណ៍ក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតមានសូរសព្ទដូចគ្នា។[16]

---

[15] ក្រសួងពាណិជ្ជកម្ម, សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និង ការប្រកបអាជីវៈកម្មអនុលោមតាមច្បាប់,(ភ្នំពេញៈក្រសួងពាណិជ្ជកម្ម)

[16] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤-១

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយ ដោយពាក្យពេញថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬ អក្សរកាត់ថា "ឯ.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍ក្រុមហ៊ុន។[17] នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយ ដោយពាក្យពេញថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមាន កម្រិត" ឬ អក្សរកាត់ថា "ម.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍ក្រុមហ៊ុន។[18]

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយ ដោយពាក្យពេញថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" ឬ អក្សរកាត់ថា "ស.ទ" នៅខាងចុង ឬខាងក្រោមនាមករណ៍ក្រុមហ៊ុន។[19] នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយ ដោយពាក្យពេញថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ឬ អក្សរកាត់ថា "ស.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍ក្រុមហ៊ុន។[20]

## ១.៥.អត្ថិភាពក្រុមហ៊ុន

តាមធម្មតា គេធ្វើឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានអត្ថិភាពផ្លូវការតាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលជួនកាលហៅថា លិខិតបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ។ ទោះជាយ៉ាងនេះក្តី កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរមិនមែនជាកត្តាចាំបាច់ទេ។ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិ គឺស្តែងចេញពីអំពើរបស់បុគ្គលពីរ ឬច្រើននាក់ ដែលធ្វើអាជីវកម្មរួមគ្នា។ ដែលមានគោលបំណងស្វែងរក និងចែករំលែកប្រាក់ចំណេញដែលកើតឡើងពីសហគ្រាសរបស់ពួកគេ។ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិ រួមជាមួយសិទ្ធិ និងកាតព្វកិច្ចទាំងអស់ កើតឡើងនៅពេលសហគ្រាសត្រូវបានបង្កើត និងដំណើរការ។

កាលណាចុះបញ្ជីរួចហើយ ក្រុមហ៊ុនបន្តអត្ថិភាពរហូត ដោយមិនទាក់ទងនឹងការផ្លាស់ប្តូរសមាជិកភាពណាមួយឡើយ។ ក្រុមហ៊ុនបន្តអត្ថិភាពរហូត លើកលែងតែមានការជំរះបញ្ជីតាមផ្លូវច្បាប់ដើម្បីបញ្ចប់ជីវិតក្រុមហ៊ុន។ ការជំរះបញ្ជី មានន័យថា ការប្រមូលផ្តុំនូវដើមទុននិងទ្រព្យសកម្មរបស់ក្រុមហ៊ុន។ បន្ទាប់មកបែងចែកទ្រព្យទាំងនោះទៅឱ្យម្ចាស់បំណុល និង ម្ចាស់ហ៊ុន ដោយអនុលោមទៅតាមវិធានអាទិភាពហ្នឹងម៉ាត់មួយ។

---

[17] ប្រកាសស្តីពីការដាក់ពាក្យសុំសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន, លេខ ១៣៧, ប្រការ ២

[18] ប្រកាសស្តីពីការដាក់ពាក្យសុំសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន, លេខ ១៣៧, ប្រការ ៣

[19] ប្រកាសស្តីពីការដាក់ពាក្យសុំសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន, លេខ ១៣៧, ប្រការ ៤

[20] ប្រកាសស្តីពីការដាក់ពាក្យសុំសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន, លេខ ១៣៧, ប្រការ ៥

ម្ចាស់ហ៊ុន អាច និងតែងតែខាតបង់ទុនវិនិយោគ បើមិនទាំងអស់ទេ ក៏ខាតបង់ភាគច្រើនដែរក្នុងករណីជំរះបញ្ជីក្រុមហ៊ុន។

## ១.៦ កិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន គឺជាសំដៅទៅលើកិច្ចសន្យាដែលបង្កើតឡើងជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការ ដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន»។[21] ក្រុមហ៊ុនគឺជាក្រុមដែលត្រូវបានបង្កើតឡើងដោយការសន្យា ដែលភាគីនីមួយៗវិនិយោគទ្រព្យធនរៀងៗខ្លួន និងប្រកបកិច្ចការដោយសហការគ្នា។ ជាងនេះទៅទៀត ភាគីនីមួយៗអាចវិនិយោគនៅក្នុងកិច្ចសន្យាក្រុមហ៊ុនបានផងដែរក្រៅពីការដាក់ទ្រព្យធន នោះគឺភាគីអាចវិនិយោគពលកម្មរបស់ពួកគេដើម្បីធ្វើជាកម្មវត្ថុបានផងដែរ។ នៅក្នុងករណីដែលភាគីដែលយកទ្រព្យជាប្រាក់យកមកធ្វើជាកម្មវត្ថុនៃការវិនិយោគនោះ គឺត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់នោះប្រសិនណាជាមានការយឺតយ៉ាវក្នុងការបង់ប្រាក់ ដោយត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ និងបង់

ទៅលើការខូចខាតផ្សេងៗទៅលើក្រុមហ៊ុនដោយសារការយឺតយ៉ាវក្នុងការបង់ប្រាក់នោះផងដែរ។ នៅក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយនៅក្នុងកិច្ចសន្យាក្រុមហ៊ុននោះ ក្លាយទៅជាមោឃៈ ឬត្រូវលុបចោល ត្រូវចាត់ទុកថាក្រុមហ៊ុននោះត្រូវបានបង្កើតដោយភាគីដទៃទៀត ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនមិនអាចសម្រេចគោលបំណងបានដោយសារកង្វះភាគីនោះ ត្រូវចាត់ទុកថាក្រុមហ៊ុននោះពុំបានបង្កើតឡើយ។[22]

### ១.៦.១ ធាតុផ្សំពិសេសនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន

ដោយយោងតាមនិយមន័យនៃកិច្ចសន្យាក្រុមហ៊ុននៅក្នុងមាត្រា៦៩៩ ក្រមរដ្ឋប្បវេណី គេអាចទាញចេញជាធាតុផ្សំនៃការបង្កើតក្រុមហ៊ុននេះបានថាត្រូវតែ មានសមាជិក មានទ្រព្យសម្បត្តិ និងការចូលរួមលើលទ្ធផលនៃប្រតិបត្តិការក្រុមហ៊ុននោះ។ ក្រៅពីធាតុផ្សំទាំងនេះគឺនៅមានធាតុផ្សំនៃការបង្ហាញឆន្ទៈក្នុងការបង្កើតក្រុមហ៊ុនមួយទៀតផងដែរ។ ដូចនេះក្រុមហ៊ុនអាចកើតឡើងដោយសារមានធាតុ៤យ៉ាងដូចជា៖

#### ១.៦.១.១ សមាជិក

សមាជិកក្រុមហ៊ុន គឺជាអ្នកដែលបានចូលហ៊ុនក្នុងការបង្កើត។ ជាគោលការណ៍ ក្រុមហ៊ុនអាចកើតឡើងដោយសារតែមានការចូលពីសមាជិកយ៉ាងហោចណាស់ពីរនាក់ឡើងទៅ ហើយលក្ខខណ្ឌនេះក៏អាចត្រូវ

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៩៩

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៧០០

បំពេញដែរបើទោះបីថាសមាជិកមានពីរនាក់នោះគឺជាប្តីប្រពន្ធនឹងគ្នាក៏ដោយ។[23] ក៏ប៉ុន្តែប្រភេទក្រុមហ៊ុនមួយចំនួនដូចជា ក្រុមហ៊ុនឯកកម្មសិទ្ធ ឬសហគ្រាសឯកបុគ្គល ឬ ក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតជាដើម គឺគេបង្កើតក្រុមហ៊ុនដោយស្ថិតក្រោមរូបភាពជាលិខិតឯកតោភាគី ដែលមិនមែនជាកិច្ចសន្យាក្រុមហ៊ុននោះទេ។ នេះមានន័យថា តាមរយៈឆន្ទៈឯកតោភាគីរបស់តែបុគ្គលម្នាក់ ក៏ក្រុមហ៊ុនត្រូវបានបង្កើតឡើងដែរ។ ទោះបីជាក្រុមហ៊ុនកើតឡើងដោយកិច្ចសន្យា ឬ លិខិតឯកតោភាគីក្តី ក៏ត្រូវតែគោរពទៅតាមលក្ខខណ្ឌគតិយុត្តស្តីពីការចុះបញ្ជីពាណិជ្ជកម្ម និងវិធានពាណិជ្ជកម្ម និងក្រមរដ្ឋប្បវេណីផងដែរ។

**១.៦.១.២ ភាគទុន**

ភាគទុនត្រូវបានគេសិក្សាវិភាគទៅលើពីរវិធាន ដែលទាក់ទងទៅនឹងអនុភាពរបស់ភាគទុននោះ និងប្រភេទរបស់វាផងដែរ។

**ក. វិធានដែលមានអនុភាពចំពោះភាគទុន**

- ភាពចាំបាច់នៃភាគទុន៖ ភាពចាំបាច់នៃភាគទុននោះគឺ ត្រូវឱ្យមានការចូលហ៊ុនពីសមាជិក។ ការចូលហ៊ុននេះបានបង្ហាញពីឆន្ទៈរបស់សមាជិកហ៊ុនដែលមានបំណងបង្កើតក្រុមហ៊ុន និងជាការដែលធ្វើឱ្យក្រុមហ៊ុនដំណើរការទៅបាន។ ភាគទុនគឺជាទ្រព្យសម្បត្តិ ដែលសមាជិកម្នាក់ៗត្រូវផ្ទេរឱ្យក្រុមហ៊ុននូវកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់។
- លាភការនៃភាគទុន៖ ការទទួលបាននូវផលមកវិញនូវចំណែកដែលសមាជិណាមួយបានដាក់ទុនទៅនោះ គឺនឹងទទួលបានទៅតាមលទ្ធផលអាជីវកម្មក្រុមហ៊ុននោះផ្ទាល់។ គេវាយតម្លៃជាមុនទាំងចំពោះទ្រព្យធនដែលនាំទៅចូលហ៊ុន បើវាជាវត្ថុ និងទាំងចំពោះសិទ្ធិក្នុងក្រុមហ៊ុនដែលគេត្រូវផ្តល់ដើម្បីជាថ្នូរចំពោះភាគទុននោះ។
- កាតព្វកិច្ចនៃអ្នកចូលហ៊ុន៖ សមាជិកចូលហ៊ុនម្នាក់ត្រូវប្រគល់ទ្រព្យធនដែលបានសន្យាថាចូលហ៊ុនឱ្យទៅក្រុមហ៊ុន។ ទោះបីជាមានការរំលាយក្រុមហ៊ុន ឬបើទោះបីជាក្រោយការដាក់ឱ្យនៅការស្តារក្រុមហ៊ុន ឬជម្រះបញ្ជីតាមផ្លូវតុលាការក៏ដោយ ក៏កាតព្វកិច្ចរបស់អ្នកចូលហ៊ុនទាំងនោះនៅតែមានដែរ។ បើអ្នកចូលភាគហ៊ុនមិនបំពេញនូវកាតព្វកិច្ចក្នុងការប្រគល់ភាគទុនដោយស្ម័គ្រចិត្តទេ សមាជិកផ្សេងទៀត ឬម្ចាស់បំណុលក្រុមហ៊ុនអាចបង្ខំឱ្យគេធ្វើតាមផ្លូវតុលាការបាន។[24]

---

[23] ឯកឧត្តមសាស្ត្រាចារ្យ កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥), ៣៧

[24] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៩

**ខ. វិធាននៃការបែងចែកប្រភេទនៃភាគហ៊ុនទុន**

យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មាត្រា១៦ មាត្រា២០ និងមាត្រា២១ បានកំណត់ពីប្រភេទផ្សេងៗគ្នាទាំងបីនៃប្រភេទនៃភាគទុន ដូចជាភាគទុនជាសាច់ប្រាក់ ជាវត្ថុ និងជាសេវាដែលវាអាចជាចំណេះដឹង ឬជាបទពិសោធន៍។ ទោះជាបែបនេះក្តី មានតែភាគទុនដែលជាសាច់ប្រាក់ និងភាគទុនជាវត្ថុប៉ុណ្ណោះដែលអាចបង្កើតបានជាមូលធន ឬជាដើមទុនរបស់ក្រុមហ៊ុនបាន។

- ការបង់ភាគទុនជាសាច់ប្រាក់៖ សមាជិកក្រុមហ៊ុនជាកូនបំណុលក្រុមហ៊ុនចំពោះទឹកប្រាក់ដែលខ្លួនបានព្រមព្រៀងថានឹងបង់ទៅលើក្រុមហ៊ុន។[25] លើសពីនេះទៅទៀត គេអាចទទួលខុសត្រូវដោយជាយថាហេតុផងដែរ ចំពោះសំណងជួសជុលការខូចខាតព្យសនកម្មដែលបណ្តាលមកពីការយឺតយ៉ាវនោះ។
- ការបង់ភាគទុនជាវត្ថុ៖ ភាគទុនជាវត្ថុ ត្រូវបានគេយកមកវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលស្គាល់នូវការវាយតម្លៃនោះ។[26] ភាគទុនជាវត្ថុអាចជាអចលនទ្រព្យ មូលធនពាណិជ្ជកម្ម អាជ្ញាប័ណ្ណនៃការបង្កើតថ្មី។ល។

**១.៦.១.៣ ការទទួលខុសត្រូវលើលទ្ធផល**

ម្ចាស់ហ៊ុនដែលបានចូលរួមនៃការបង្កើតក្រុមហ៊ុននោះ សុទ្ធសឹងតែមានការទទួលបានមកវិញនូវប្រាក់ចំណេញ ក៏ដូចជាត្រូវរួមចំណែកក្នុងការខាតបង់ផងដែរ។

**ក. ការចូលរួមលើកម្រៃដែលចំណេញបាន**

ជារៀងរាល់ឆ្នាំសមាជិកទាំងឡាយត្រូវបានអញ្ជើញឱ្យសម្រេចលើចំណែកនៃកម្រៃដែលជាលទ្ធផលនៃប្រតិបត្តិការឆ្នាំកន្លងទៅ។ គេនឹងឃើញមានកម្រៃដែលទទួលបានពីការប្រតិបត្តិអាជីវកម្មនោះ ហើយកម្រៃនោះគឺការចំណេញជាប្រាក់កាស ឬជាវត្ថុដែលអាចបង្កើនដល់ធនធានរបស់សមាជិកទាំងអស់នៃក្រុមហ៊ុន។[27]

**ខ. ការចូលរួមលើការខាត់បង់**

ការចូលរួមលើការខាត់បង់ គឺជាការចូលរួមនៃសមាជិកហ៊ុនទាំងអស់ ហើយគ្មានការប៉ះពាល់ដល់អ្នកដែលក្រុមហ៊ុនខ្ចីប្រាក់យកមកធ្វើជាដើមទុនទេ។ សមាជិកណាដែលបានបង់ប្រាក់មានចំនួនច្រើនជាងចំនួននៃ

---

[25] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៧

[26] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២១

[27] ឯកឧត្តមសាស្ត្រាចារ្យ កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, (ភ្នំពេញ៖ បណ្ណាគារអង្គរ,២០១៥), ៥៤

ការខាត់បង់ គេអាចទាមទារឱ្យសមាជិកដទៃផ្សេងទៀតបង់សងមកខ្លួនវិញ។ ជាទូទៅសមាជិកម្នាក់ៗ ត្រូវចូលរួមក្នុងការខាតបង់ដែលសមាមាត្រនឹងចំណែកនៃភាគទុនរបស់ខ្លួនដែលបានដាក់ហ៊ុននៅក្នុងក្រុមហ៊ុននោះ។

#### **១.៦.១.៤. ឆន្ទៈក្នុងការបង្កើតក្រុមហ៊ុន**

សុពលភាពគ្រប់ក្រុមហ៊ុន ត្រូវចំណុះនឹងអត្ថិភាពនៃសារធាតុដែលជាប្រភេទចិត្តសាស្ត្រ គឺឆន្ទៈរួមគ្នាក្នុងការបង្កើតក្រុមហ៊ុន។ ឆន្ទៈនេះមិនមែនមានតែក្នុងពេលបង្កើតក្រុមហ៊ុននោះទេ ពោលគឺមានជាអត្ថិភាពជារៀងរហូតរួមទាំងក្នុងពេលប្រតិបត្តិការនៃក្រុមហ៊ុនផងដែរ។

### **១.៦.២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាក្រុមហ៊ុន**

លក្ខខណ្ឌសុពលភាព គឺជាការបំពេញនូវលក្ខខណ្ឌពីរគឺ លក្ខខណ្ឌដែលទាក់ទងទៅនឹងភាគី និង លក្ខខណ្ឌដែលទាក់ទង់ទៅនឹងខ្លឹមសារកិច្ចសន្យានោះ។

#### **១.៦.២.១. លក្ខខណ្ឌដែលទាក់ទងទៅនឹងភាគី**

ភាគីនៅក្នុងកិច្ចសន្យាគឺត្រូវមានសមត្ថភាពផ្នែកស្មារតី ការយល់ដឹង និងអាចវិនិច្ឆ័យបានចំពោះលទ្ធផលបាន ពោលគឺដែលមិនស្ថិតនៅក្នុងក្រុមដែលត្រូវបានច្បាប់កម្រិតសមត្ថភាពធ្វើសកម្មភាព។ ជនដែលត្រូវបានកម្រិតសមត្ថភាពមានបីប្រភេទ គឺអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។[28] លើសពីនេះទៅទៀត ភាគីក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្ហាញឆន្ទៈផងដែរ។ ពោលគឺជាសមត្ថភាពក្នុងការ សម្តែងឆន្ទៈដែលគ្មានវិការៈ។ ការសម្តែងឆន្ទៈដោយគ្មានវិការៈ គឺជាការសម្តែងចេញដោយគ្មានការភាន់ច្រឡំ គ្មានការឆបោក គ្មានការគម្រាមកំហែងយក គ្មានការបង្ហាញការមិនពិតរបស់ភាគីណាម្ខាង ឬ គ្មានការកេញយកចំណេញហួសហេតុជាដើម។[29]

#### **១.៦.២.២. លក្ខខណ្ឌដែលទាក់ទង់ទៅនឹងខ្លឹមសារកិច្ចសន្យា**

លក្ខខណ្ឌដែលទាក់ទងនឹងខ្លឹមសារនេះគឺត្រូវបានច្បាប់កំណត់ឱ្យមានការបំពេញធាតុចំនួនបួនគឺ ភាពច្បាស់លាស់ ដែលអាចឱ្យមានការកំណត់សម្គាល់បានថា នៃកិច្ចសន្យានោះជាអ្វីឱ្យប្រាកដ។ ធាតុបន្ទាប់ទៀតនេះគឺ ភាពស្របច្បាប់។ កិច្ចសន្យាមួយនឹងត្រូវចាត់ទុកជាមោឃៈប្រសិនបើខ្លឹមសារនៃកិច្ចសន្យានោះផ្ទុយពីបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។[30] ធាតុដែលត្រូវបំពេញដែរនោះគឺ ភាពសមស្របតាមស្ថានភាពសង្គម។

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា១៦

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៣៤៥

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៣៥៤ កថាខណ្ឌទី១ ចំណុច ក

ចំណុចនេះគឺសំដៅទៅលើ ភាពស្របទៅតាមសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម។[31] ធាតុចុងក្រោយ គឺលក្ខខណ្ឌដែលគ្មានការបង្ហាញឆន្ទៈមិនពិត។ លក្ខណ្ឌនេះសំដៅថា កិច្ចសន្យាមួយមិនអាចមានសុពលភាពនោះទេបើមានការបង្ហាញឆន្ទៈមិនពិត។ វាអាចមានជារូបភាពមួយដែលថា កិច្ចសន្យាមួយបានធ្វើឡើងដោយមានការឃុបឃិតគ្នាជាមួយភាគីម្ខាងទៀត នោះកិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ។[32] ជាក់ស្តែងទៅ កម្មវត្ថុនៅក្នុងកិច្ចសន្យាក្រុមហ៊ុនគឺមានគោលដៅក្នុងការប្រកបពាណិជ្ជកម្មដែលស្របទៅនឹងបទប្បញ្ញត្តិច្បាប់ និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អ។

**១.៦.៣. លក្ខខណ្ឌរំលាយកិច្ចសន្យាក្រុមហ៊ុន**[33]

កិច្ចសន្យាមួយអាចនឹងត្រូវបានរំលាយ ប្រសិនបើមានភាគីណាមួយមិនអនុវត្តនូវកិច្ចសន្យានោះ។ ដោយហេតុថាក្រុមហ៊ុនគឺបានបង្កើតដោយកិច្ចសន្យាក្រុមហ៊ុន ដូចនេះការរំលាយក្រុមហ៊ុនទៅវិញគឺត្រូវធ្វើតាមលក្ខខណ្ឌនៅក្នុងការរំលាយកិច្ចសន្យាក្រុមហ៊ុនដែលមានដូចខាងក្រោម៖

**ក. ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុក្រុមហ៊ុន ឬអលទ្ធភាពក្នុងការបំពេញកិច្ចការ**

ជាធម្មតា គេបង្កើតនូវកិច្ចសន្យាក្រុមហ៊ុនឡើងគឺដើម្បីសម្រេចនូវកម្មវត្ថុដែលមាននៅក្នុងកិច្ចសន្យានោះ។ ដូចនេះហើយការដែលគេបានសម្រេចនូវកិច្ចការដែលជាកម្មវត្ថុនោះហើយ គេក៏អាចយកមូលហេតុនេះមករំលាយនូវកិច្ចសន្យានេះបានដែរ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចសន្យាក៏អាចរំលាយបានដែរដរាបណាដែលក្រុមហ៊ុនមិនអាចសម្រេចនូវកម្មវត្ថុនៅក្នុងកិច្ចសន្យានោះបានដោយសារតែអលទ្ធភាព។

**ខ. ការព្រមព្រៀងដោយសមាជិកទាំងអស់**

យើងបានដឹងហើយការការបង្កើតកិច្ចសន្យាជាការព្រមព្រៀងគ្នា មានសំណើ ស្វីការ និងការបង្ហាញឆន្ទៈទៅគ្នាទៅវិញទៅមកពីបណ្តាសមាជិកទាំងអស់។ នៅពេលដែលចង់រំលាយកិច្ចសន្យាវិញក៏ដូចគ្នាដែរគឺសមាជិកទាំងអស់ព្រមព្រៀង និងឯកភាពគ្នាក្នុងការរំលាយកិច្ចសន្យាក្រុមហ៊ុននេះ។

**គ. នៅមានសមាជិកតែម្នាក់ក្នុងកិច្ចសន្យា**

ពិតណាស់ថាកិច្ចសន្យាត្រូវធ្វើឡើងចាប់ពីបុគ្គលពីនាក់ឡើងទៅ ដូចនេះហើយបើនៅក្នុងកិច្ចសន្យាមួយមានភាគីតែម្នាក់ កិច្ចសន្យានោះគឺចាត់ទុកថាត្រូវបានរំលាយ។

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥៤ កថាខណ្ឌទី១ ចំណុច ខ

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥៣

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៧១៣

**ឃ.អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុនត្រូវបានបញ្ចប់**

ជាលក្ខណនៃការរំលាយមួយដែលចេញមកពីការថែងច្បាស់លាស់របស់សមាជិកក្រុមហ៊ុន ថានឹងបញ្ចប់កិច្ចសន្យានោះនៅពេលណាមួយជាក់លាក់។ ដូចនេះហើយ នៅពេលដែលការកំណត់អត្ថិភាពរបស់ក្រុមហ៊ុននោះបានមកដល់គឺជាពេលដែលក្រុមហ៊ុនត្រូវរំលាយ។

# ជំពូកទី២

# នីតិវិធី និងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ

ក្រុមហ៊ុនសហកម្មសិទ្ធិជាទម្រង់អាជីវកម្ម ដែលជាទីពេញនិយមរបស់អ្នកដែលមានវិជ្ជាជីវៈ ដូចជា វេជ្ជបណ្ឌិត មេធាវី និងគណនេយ្យករ។ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ជាតាមធម្មតា គេអាចធ្វើឲ្យក្រុមហ៊ុនសហកម្មសិទ្ធិ មានអត្ថិភាពជាផ្លូវការ តាមកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សរ ដែលជូនកាលហៅថា លិខិតបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ។ ដោយហេតុថាក្រុមហ៊ុនសហកម្មសិទ្ធិនេះ ត្រូវបានបែងចែកជាពីរទម្រង់ក្រុមហ៊ុនទៀតនោះ ដូចនេះយើងពិតជាចង់ដឹង ថាតើក្រុមហ៊ុនទាំងពីរប្រភេទនោះមានលក្ខណៈដូចម្តេច ហើយត្រូវបានគេបង្កើតឡើងដោយរបៀបណា។ ដូចនេះហើយនៅខាងក្រោមនេះយើងនឹងធ្វើការសិក្សាទៅលើ៖ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ (២.១) ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត(២.២) ការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ (២.៣) ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ (២.៤) និង ចំណុច (២.៥) គឺនិយាយអំពី គុណសម្បត្តិ និង គុណវិបត្តិចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ។

## ២.១. ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួម ក្នុងគោលបំណងរកប្រាក់ចំណេញ។34 នេះបានន័យថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅកើតឡើងដំបូងបង្អស់ដោយសារកិច្ចសន្យា ដែលពួកគេបានព្រមព្រៀងគ្នារួចជាស្រេចទៅលើគោលការណ៍ជាសារវ័ន្តនៃកិច្ចសន្យាក្រុមហ៊ុន ។

### ២.១.១. លក្ខណៈទូទៅ

កិច្ចសន្យាក្រុមហ៊ុននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ នៅត្រង់ចំណុចនេះ មិនមានការកំណត់ណាមួយថាត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះទេ ប៉ុន្តែជាគោលការណ៍ គេតម្រូវឱ្យមានជាលាយលក្ខណ៍អក្សរដើម្បីជាប្រយោជន៍ធ្វើឱ្យមានការទុកចិត្តគ្នាទៅវិញទៅមក។ ខដែលមានចែងក្នុងកិច្ចសន្យានេះ គេអាចចែងបញ្ជាក់ពីចំណុចនៃការទាមទារទាំងឡាយដែលអ្នកចូលភាគហ៊ុនចង់បាន លើកលែងតែប្រការនោះផ្ទុយទៅនឹងគោលការណ៍ច្បាប់ ឬប្រឆាំងទៅនឹងភាពស្របច្បាប់។ កិច្ចសន្យាដែលបានចែងទាំងនោះ ត្រូវចុះហត្ថលេខារវាង

[34] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨

គ្រប់សមាជិកទាំងអស់របស់ក្រុមហ៊ុន។ បើគ្មានកិច្ចសន្យា ឬកិច្ចព្រមព្រៀងណាមួយផ្សេងទេ សហកម្មសិទ្ធិករទូទៅមានសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រង និងដឹកនាំក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។[35]

**២.១.១.១. កម្មវត្ថុ**

កម្មវត្ថុក្រុមហ៊ុនសហកម្មសិទ្ធិគឺជាសេចក្តីថ្លែងពីគោលបំណងទូទៅ និងទំហំនៃសកម្មភាពដែលក្រុមហ៊ុនសហកម្មសិទ្ធិត្រូវអនុវត្តន៍ដើម្បីឱ្យសំរេចគោលបំណងរបស់ខ្លួន។ គោលបំណងទូទៅរបស់ក្រុមហ៊ុនសហកម្មសិទ្ធិគឺស្វែងរកប្រាក់ចំណេញ។

កម្មវត្ថុដែលថ្លែងពីទំហំនៃសកម្មភាពរបស់ក្រុមហ៊ុនគឺ ការរាយនូវបញ្ជីសកម្មភាពដែលក្រុមហ៊ុនត្រូវធ្វើ។ ការរាយនូវបញ្ជីសកម្មភាពរបស់ក្រុមហ៊ុននេះធ្វើឡើងដើម្បីឱ្យមន្ត្រីចុះបញ្ជីដឹងថា សកម្មភាពណាខ្លះដែលត្រូវហាមឃាត់ និងសកម្មភាពណាទៀតដែលគ្មានការហាមឃាត់។ កាលណាក្រុមហ៊ុនសហកម្មសិទ្ធិចែងអំពីសកម្មភាពដែលច្បាប់ហាមឃាត់ មន្ត្រីចុះបញ្ជីអាចបដិសេដមិនចុះបញ្ជីឱ្យ។ ហើយចំពោះកម្មវត្ថុក្រុមហ៊ុននេះដែរ គេអាចដាក់ច្រើនជាងមួយក៏បានដែរ ដើម្បីជាផលប្រយោជន៍នៅថ្ងៃក្រោយ ប្រសិនក្រុមហ៊ុនចង់ធ្វើមុខរបបផ្សេងមួយទៀត។[36] ឧទាហរណ៍ ក្រុមហ៊ុនមួយមានគោលបំណងចំបងរបស់គេ គឺផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ផ្ទះបាយ ប៉ុន្តែបែរជារាយនៅក្នុងកម្មវត្ថុរបស់ខ្លួននូវបញ្ជីសកម្មភាព អាជីវកម្ម ភោជនីយដ្ឋាន បង្កើតភាពយន្ត លក់គ្រឿងសំណង់។ល។ ដោយហេតុដូច្នេះ នៅថ្ងៃខាងមុខប្រសិនបើក្រុមហ៊ុនចង់ផ្លាស់ប្តូរពី ក្រុមហ៊ុនផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ផ្ទះបាយ ទៅជាក្រុមហ៊ុនលក់គ្រឿងសំណង់វិញបាន ដោយហេតុថាខ្លួនបានរាយឈ្មោះប្រភេទក្រុមហ៊ុននេះនៅក្នុងកម្មវត្ថុបន្ទាប់បន្សំរបស់ខ្លួន។ កម្មវត្ថុរបស់ក្រុមហ៊ុនដែលមានភាពទូលំទូលាយពេក នឹងមិននាំឱ្យប៉ះពាល់ទៅដល់ទម្រង់ក្រុមហ៊ុនដទៃទៀតទេ ប៉ុន្តែវាអាចនាំមកនូវគ្រោះថ្នាក់ធំធេង ចំពោះសមាជិកទាំងឡាយនៃក្រុមហ៊ុននេះ ។ ព្រោះថា សមាជិកក្រុមហ៊ុនត្រូវទទួលខុសត្រូវដោយគ្មានកម្រិត និងដោយសាមគ្គីចំពោះបំណុលរបស់តតិយជន។[37]

**២.១.១.២. អំពីនាមករណ៍**

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងពីវិធានសំរាប់ដាក់ឈ្មោះក្រុមហ៊ុនសហកម្មសិទ្ធិដោយបានចែងថា នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើន

[35] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៣៧ វាក្យខ័ណ្ឌ១

[36] កុយ នាម, *ច្បាប់ក្រុមហ៊ុន*, ឆ្នាំ ២០១៦,១០៨

[37] ឯកឧត្តមសាស្ត្រាចារ្យ កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥), ១៩២

នាក់ហើយនៅខាងក្រោយ ឬនៅខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ"។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រើនាមករណ៍របស់ខ្លួននៅក្នុងពេលធ្វើពាណិជ្ជកិច្ច។[38]

ការដាក់ឈ្មោះក្រុមហ៊ុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមិនមែនជាការជ្រើសរើសរបស់សមាជិកក្រុមហ៊ុន។ ក្រុមហ៊ុនមិនអាចដាក់ឈ្មោះប្រឌិតបានទេ ដូចជាក្រុមហ៊ុនមិនអាចដាក់ឈ្មោះ ថា "អង្គរ" បានទេ។ តាមវិធានច្បាប់ខ្មែរ ការដាក់ឈ្មោះក្រុមហ៊ុនដោយយកឈ្មោះសហកម្មសិទ្ធិករទៅបញ្ចូល អាចធ្វើឱ្យតតីយជនសំគាល់បានថាក្រុមហ៊ុនមួយជាក្រុមហ៊ុនសហកម្មសិទ្ធិ ហើយអ្នកណាជាសហកម្មសិទ្ធិករ។ យ៉ាងហោចណាស់តតីយជនអាចដឹងថាអ្នកណាជាម្នាក់ក្នុងចំណោមសហកម្មសិទ្ធិករនោះទទួលខុសត្រូវជាសាមីភាព។ ប៉ុន្តែច្បាប់ស្តីពីសហគ្រាពាណិជ្ជកម្ម មិនបានពិន័យដល់អ្នកដែលដាក់ឈ្មោះក្រុមហ៊ុនក្រៅពីឈ្មោះសហកម្មសិទ្ធិករទេ។ ការពិន័យដែលអាចធ្វើបានប្រហែលជា ក្រសួងពាណិជ្ជកម្មបដិសេធការចុះបញ្ជីក្រុមហ៊ុន។ ប៉ុន្តែ ការពិន័យតាមមធ្យោបាយនេះអាចធ្វើចំពោះតែក្រុមហ៊ុនដែលចង់ចុះបញ្ជី តែមិនអាចធ្វើបានចំពោះសហកម្មសិទ្ធិដែលមិនចុះបញ្ជីនោះទេ។[39]

**២.១.១.៣.អំពីសហកម្មសិទ្ធិករ**

ក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវមានសហកម្មសិទ្ធិករយ៉ាងតិចពីរនាក់។

**២.១.១.៤.អំពីដើមទុន**

ដើមទុនក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមាន ភាគទុនជាសាច់ប្រាក់ និង ជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពទេ។[40] វិភាគទានជាភាគទុនរបស់សហកម្មសិទ្ធិករទាំងអស់នេះក្លាយទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុន។ ចំនួនភាគទុនកំណត់ជាក់លាក់ដោយកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិ ដែលសហកម្មសិទ្ធិករម្នាក់ៗ បានរួមចំណែកដើម្បីចាប់ផ្តើមនិងប្រកបពាណិជ្ជកិច្ចរបស់គេ សហកម្មសិទ្ធិកររួមចំណែកភាគទុនរបស់ខ្លួនជាសាច់ប្រាក់ វត្ថុ ចំណេះដឹង ឬជាសេវាកម្ម។ ភាគទុនទាំងនោះត្រូវគិតជាសាច់ប្រាក់ និងជារូបិយវត្ថុ។ សហកម្មសិទ្ធិករទូទៅម្នាក់ៗគឺជាកូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចំពោះរាល់អ្វីៗ ដែលខ្លួនបានសន្យាចូលរួមក្នុង

[38] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១៤

[39] កុយ នាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ ទំព័រ ១០៦

[40] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ២១

ក្រុមហ៊ុន។[41] សហកម្មសិទ្ធិករដែលបានសន្យាថា នឹងចូលរួមភាគទុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុន។ សហកម្មសិទ្ធិករមួយអាចមិនទាន់បានបង់ភាគទុនរបស់ខ្លួននៅពេលបង្កើតក្រុមហ៊ុន។ សហកម្មសិទ្ធិករនោះនៅជំពាក់ក្រុមហ៊ុននូវចំនួនប្រាក់ ឬវត្ថុមានតម្លៃដែលខ្លួនបានសន្យាចូលរួមក្នុងក្រុមហ៊ុន។ សកម្មសិទ្ធិករនោះត្រូវទទួលខុសត្រូវចំពោះការខាតបង់របស់ក្រុមហ៊ុន ថ្វីបើខ្លួនពុំទាន់បានបង់ភាគទុនចូលក្នុងក្រុមហ៊ុនក៏ដោយ។ គេមិនអាចប្រកែកថា ខ្លួនគេនៅមិនទាន់ក្លាយខ្លួនជាសហកម្មសិទ្ធិករនៃក្រុមហ៊ុននៅឡើយទេ លើកលែងតែកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិអនុញ្ញាតឱ្យភាគីនោះរួចផុតពីកាតព្វកិច្ចនោះ។[42] ភាគីដែលយឺតយ៉ាវក្នុងការបង់ភាគទានត្រូវទទួលខុសត្រូវក្នុងការបង់ចុងការប្រាក់សំរាប់រយៈពេលចាប់ពីពេលចុះកិច្ចសន្យារហូតដល់ថ្ងៃបង់ភាគទុនផងដែរ។

### ២.១.២. លក្ខណ្ឌទម្រង់

#### ២.១.២.១. កិច្ចសន្យា និងការផ្សព្វផ្សាយជាសាធារណៈ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើងនៅពេលភាគីទាំងអស់ចុះកិច្ចសន្យាជាមួយគ្នា។ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដោយគោរពតាមគោលការណ៍សុពលភាពនៃកិច្ចសន្យាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ប្រសិនបើកិច្ចសន្យាជាលាយលក្ខណ៍អក្សរសហកម្មសិទ្ធិទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។ កិច្ចសន្យា ឬលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចត្រូវគេធ្វើឡើងជាច្រើនច្បាប់តាមដែលអាចធ្វើទៅបាន។ ក្នុងចំនួននេះគេត្រូវ៖

- ដាក់តម្កល់នៅឯទីស្នាក់ការក្រុមហ៊ុន
- ដាក់តម្កល់នៅឯស្ថាប័នមានសមត្ថកិច្ច
- បំពេញតាមទម្រង់នានាដែលច្បាប់តម្រូវ
- ចែកជូនដល់សមាជិកក្រុមហ៊ុនទាំងអស់។

កិច្ចសន្យាតាក់តែងមានបញ្ជាក់ពីបំណងផ្សេងៗ របស់ក្រុមហ៊ុនដែលគេគួរតាក់តែងសរសេរក្នុងលក្ខណៈមួយងាយស្រួលទៅដល់លទ្ធភាពដែលអាចបត់បែនបាន។

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការអនុវត្តការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវ

[41] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១៧

[42] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១១-១៩

រក្សាទុកជាឯកសារនូវសេវភៅបញ្ជីនិងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។[43] ការផ្សាយជាសាធារណៈត្រូវធ្វើឡើង ដើម្បីជាប្រយោជន៍កុំឱ្យមានសមាជិកទាំងឡាយណាទាញយកផលប្រយោជន៍ នៅពេលក្រុមហ៊ុនត្រូវបានចាត់ទុកជាមោឃៈ។

### ២.១.២.២.លក្ខន្តិកៈក្រុមហ៊ុន

លក្ខន្តិកៈនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបង្កើតឡើងដោយមានភាគីទាំងអស់ចុះហត្ថលេខា។ ក្នុងការអនុវត្តជាក់ស្តែងក្រសួងពាណិជ្ជកម្មពុំមានទម្រង់ណាមួយសម្រាប់ឱ្យភាគីប្រើប្រាស់ទេ គឺភាគីជាអ្នកតាក់តែងវាដោយខ្លួនឯងដែលក្នុងនោះមានកំណត់ អំពីខចែងនានាដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ជាអាទិ៍។ ចំពោះការតាក់តែងលក្ខន្តិកៈក្រុមហ៊ុននេះគឺជាកិច្ចព្រមព្រៀងដែលកំណត់អំពីៈ

- នាមករណ៍
- ភាគទុនិក / សហកម្មសិទ្ធិករ
- គោលបំណងពាណិជ្ជកម្ម
- ដើមទុន និង ភាគទុន
- ការគ្រប់គ្រង
- ការតម្កល់ និងការផ្ទេរភាគហ៊ុន
- ការបែងចែកប្រាក់ចំណេញ
- ការទទួលខុសត្រូវរបស់ក្រុមហ៊ុន និងភាគី
- ការបញ្ចប់ ឬការរំលាយក្រុមហ៊ុន និងផ្សេងៗទៀត

**ក. អ្នកគ្រប់គ្រងក្រុមហ៊ុន**

សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ។[44]

ចំពោះអ្នកគ្រប់គ្រងក្រុមហ៊ុន អាចធ្វើការជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅក៏បាន ហើយការជ្រើសតាំងនោះគឺត្រូវមើលទៅលើសមត្ថភាពពិតប្រាកដក្នុងការដឹកនាំក្រុមហ៊ុនឱ្យមានការរីកចម្រើន។ គេមិនសូវ

[43] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១៥

[44] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៣៧

ជ្រើសរើសយកតតិយជនឱ្យធ្វើជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនទេ ដោយហេតុថា ក្រុមហ៊ុនជាក្រុមហ៊ុនដែលមានការទទួលខុសត្រូវដោយគ្មានកំណត់ និងដោយសាមគ្គី ហេតុនេះ គេមិនសូវមានភាពជឿរទុកចិត្តខ្លាំង ក្រៅពីសមាជិកភាគហ៊ុនដែលមានសមត្ថភាពនោះទេ។ ដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មាត្រា ៣៥ បានចែងថា សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬបុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅឱ្យគ្រប់គ្រងកិច្ចការជំនួសនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបាន។ អ្នកគ្រប់គ្រង អាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន ដរាបណាអ្នកគ្រប់គ្រង ត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែង ដោយសម្លេងភាគច្រើន ដោយធៀបនឹងវត្តមានសហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងមានចែងផ្សេងក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិ។

**ខ. ការតែងតាំងអ្នកគ្រប់គ្រង**

សហកម្មសិទ្ធិទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិទូទៅម្នាក់ ឬច្រើននាក់ ឬបុគ្គលដែលមិនមែនជាសហកម្មសិទ្ធិទូទៅឱ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះបាន។[45] អ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាព នៅក្នុងសិទ្ធិអំណាចខ្លួន ហើយការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវ ជាប់កាតព្វកិច្ចនឹងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។

អ្នកគ្រប់គ្រងត្រូវដកហូតចេញពីមុខតំណែង ដោយសំលែងភាគច្រើនធៀបនឹងវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយ ក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ អ្នកគ្រប់គ្រងអាចត្រូវបញ្ចប់ពីមុខតំណែងក្នុងករណី ដល់កាលកំណត់ ទទួលមរណៈភាព អសម្ថតភាព ត្រូវបានដកហូតមុខតំណែងដោយសារមានកំហុស និងការសុំលាលែងពីមុខងារ។

**គ. អំពីសហកម្មសិទ្ធិករ**

ជាទូទៅ សមាជិកទាំងអស់របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវទទួលខុសត្រូវដោយគ្មានការកំណត់ និងដោយសាមគ្គីភាពលើបំណុលទាំងអស់របស់ក្រុមហ៊ុន។

**ឃ. សិទ្ធិ និងភាពកិច្ចរបស់សហកម្មសិទ្ធិករ**

- **សិទ្ធិទទួលបានប្រាក់ចំណេញ**

ប្រាក់ចំណេញគឺគោលដៅចំបងនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ។ ហើយរបៀបបែងចែកប្រាក់ចំណេញត្រូវបែងចែកស្របតាមការព្រមព្រៀងគ្នារវាងសហកម្មសិទ្ធិករ។ បើកិច្ចសន្យាមិនបានចែងពីរបៀបបែង

[45] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៣៥

ចែកប្រាក់ចំណេញទេនោះ ច្បាប់សន្មត់ថា សហកម្មសិទ្ធិករទាំងអស់ត្រូវទទួលប្រាក់ចំណេញក្នុងចំណែកស្មើគ្នា នេះជាវិធានកំណត់ដោយច្បាប់។

សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិប្រាក់ចំណេញនិងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា។

ប្រសិនបើកិច្ចសន្យាមានចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬ ការខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងក្នុងករណីនេះត្រូវបានសន្មត់ជាមុន ដើម្បីអនុវត្តទៅលើតែករណីទាំងបីនោះ។[46]

ការបែងចែកប្រាក់ចំណេញតាមកិច្ចព្រមព្រៀងអាចធ្វើបានទៅតាមសមាមាត្រនៃភាគទុនដែលសហកម្មសិទ្ធិករបានចូលទៅក្នុងក្រុមហ៊ុន ឬតាមការបែងចែកតាមរូបមន្តណាផ្សេងទៀតដែលគេជ្រើសរើស។ នៅក្នុងកិច្ចសន្យាចំណុចដែលហាមមិនចង់ឱ្យកើតមាននោះគឺមិន ឱ្យសហកម្មសិទ្ធិករធ្វើកិច្ចសន្យាផ្តើតក្រុមហ៊ុនសហកម្មសិទ្ធិ ដែលដាក់កំហិតមិនឱ្យសហកម្មសិទ្ធិទទួលប្រាក់ចំណេញ។ គោលបំណងនេះគឺចង់ទប់ស្កាត់កិច្ចព្រមព្រៀងណាមួយដែលហាមប្រាមជាអចិន្ត្រៃយ៍ ដល់ការមិនបែងបែងចែកប្រាក់ចំណេញដល់សហកម្មសិទ្ធិករ ដូចជាករណីដែលសហកម្មសិទ្ធិករទាំងអស់ព្រមព្រៀងគ្នាមិនចែកប្រាក់ចំណេញ ដើម្បីទុកប្រាក់ចំណេញនោះនៅក្នុងក្រុមហ៊ុន ក្នុងផលប្រយោជន៍ប្រើប្រាស់បន្តនូវប្រាក់ចំណេញនោះ ដើម្បីពង្រឹងអាជីវកម្មរបស់ក្រុមហ៊ុន។ ដូចដែលមានចែងក្នុងមាត្រា ២៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានចែងថា "សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវមានសិទ្ធិទទួលប្រាក់ចំណេញ និងត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន។

ខទាំងឡាយនៃកិច្ចសន្យា ដែលដាក់សហកម្មសិទ្ធិករទូទៅពីសិទ្ធិទទួលប្រាក់ចំណេញត្រូវចាត់ទុកជាគ្មានប្រសិទ្ធិភាព។ បញ្ញត្តិនៃមាត្រា ២៣ នេះមានគោលដៅផងដែរ ដើម្បីរារាំងមិនឱ្យមានការគៀបសង្កត់ដល់សហកម្មសិទ្ធិករដែលមានចំណែកផលប្រយោជន៍ភាគតិច ពីសំណាក់សហកម្មសិទ្ធិករដែលមានផលប្រយោជន៍ភាគច្រើន ក្នុងការទទួលផលប្រយោជន៍ពីក្រុមហ៊ុន។ ប្រសិបើការសង្កត់សង្កិនទៅលើសហកម្មសិទ្ធិករទូទៅដែលមានភាគតិចនេះវាកើតឡើង វាងាយក្នុងការដែលសហកម្មសិទ្ធិករទូទៅដែលមានផលប្រយោជន៍ភាគតិចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធនេះ ងាយក្នុងការដកខ្លួនចេញពីក្រុមហ៊ុន ព្រោះជាទូទៅ សហកម្មសិទ្ធិករភាគតិចច្រើនតែពឹងផ្អែកលើប្រាក់ចំណេញជាប្រាក់ចំណូលរបស់ខ្លួន។ ចំពោះករណីនេះសហកម្មសិទ្ធិនោះមិនអាចទ្រាំនៅក្នុងក្រុមហ៊ុនលែងបាន ហើយសម្រេចចិត្តដកខ្លួនថយ សហកម្មសិទ្ធិករភាគតិចនោះមានជម្រើសពីរ

[46] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ២៤

ដើម្បីតតាំងនឹងសហកម្មសិទ្ធិករភាគច្រើន គឺ ការប្តឹងទៅតុលាការ ដើម្បីឱ្យតុលាការបង្គាប់ឱ្យក្រុមហ៊ុនសហកម្មសិទ្ធិបែងចែកប្រាក់ចំណេញ ឬ ការប្តឹងតុលាការសុំឱ្យរំលាយក្រុមហ៊ុន និងធ្វើការជម្រះបញ្ជី។

- **សិទ្ធិកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិក្រុមហ៊ុន**

សហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬ ពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ។[47]

សហកម្មសិទ្ធិករទូទៅជាម្ចាស់រួមលើទ្រព្យសម្បត្តិក្រុមហ៊ុន ដូច្នេះ សហកម្មសិទ្ធិករមានសិទ្ធិស្មើៗគ្នាក្នុងការកាន់កាប់ទ្រព្យនិងប្រើប្រាស់ទ្រព្យសម្បត្តិនោះក្នុងនាមនៃក្រុមហ៊ុន។ ប៉ុន្តែសហកម្មសិទ្ធិករមិនអាចប្រើប្រាស់ទ្រព្យសម្បត្តិនោះជាប្រយោជន៍ផ្ទាល់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀត។ សហកម្មសិទ្ធិករដែលយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅប្រើ ដោយគ្មានការយល់ព្រមពីសហកម្មសិទ្ធិដទៃទៀត មិនអាចទទួលផលកម្រៃដែលកើតចេញពីការប្រើប្រាស់នោះទេ។

- **សិទ្ធិទទួលព័ត៌មានពីអាជីវកម្ម**

សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព៌តមានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុទោះបីជាសហកម្មសិទ្ធិទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ។ នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬមិនត្រូវធ្វើឱ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្តសិទ្ធិដូចគ្នាឡើយ។[48]

សិទ្ធិទទួលព័ត៌មានអាជីវកម្មរួមមានសិទ្ធិត្រួតពិនិត្យបញ្ជី របាយការណ៍ ផែនការ និងសកម្មភាពរបស់ក្រុមហ៊ុន។ គេអាចពិនិត្យបញ្ជី និងឯកសារដទៃទៀតដោយខ្លួនឯងផ្ទាល់ ឬតែងតាំងអ្នកតំណាងម្នាក់ឱ្យពិនិត្យជំនួសក៏បាន។ សិទ្ធិទទួលព័ត៌មាននាំឱ្យមានកាតព្វកិច្ចត្រូវផ្តល់ព័ត៌មានដល់សហកម្មសិទ្ធិផងដែរ។ ក្រុមហ៊ុនត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន សហកម្មសិទ្ធិករអាចពិនិត្យមើលសៀវភៅបញ្ជី ឬកំណត់ហេតុទាំងអស់នេះបាននៅទីនោះ។

---

[47] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ២៥

[48] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៣៩

- **សិទ្ធិទទួលការទូទាត់សេវាកម្មដែលផ្តល់ឱ្យក្រុមហ៊ុន**

នៅក្នុងមាត្រា២៦នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានចែងថា "គ្មានសហកម្មសិទ្ធិករណាម្នាក់ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ"។ ថ្វីបើសហកម្មសិទ្ធិករគ្មានសិទ្ធិជាស្វ័យប្រវត្តិ ដើម្បីទទួលការទូទាត់សេវាកម្មដែលខ្លួនបំពេញចំពោះក្រុមហ៊ុន សហកម្មសិទ្ធិទាំងអស់អាចចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ដើម្បីអនុញ្ញាតឱ្យសហកម្មសិទ្ធិករដែលចំណាយពេលវេលារបស់ខ្លួនដើម្បីធ្វើការឱ្យក្រុមហ៊ុន បានទទួលការទូទាត់ចំពោះសេវាកម្មរបស់ខ្លួន។ កិច្ចសន្យាត្រូវចែងអំពីការទូទាត់ថ្លៃសេវាកម្មរបស់សហកម្មសិទ្ធិករម្នាក់ៗក្នុងនាមជានិយោជិតរបស់ក្រុមហ៊ុន ដែលនឹងត្រូវកំណត់ដោយកិច្ចសន្យាការងាររវាងក្រុមហ៊ុននិងសហកម្មសិទ្ធិករ។

- **ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ**

បុគ្គលណាមួយដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលដែលបុគ្គលនោះ បានផ្ទេរផលប្រយោជន៍របស់ខ្លួន ឬបានទទួលមរណៈភាព ឬត្រូវបានដាក់ក្រោមការត្រួតពិនិត្យអង្កេតពេលក្ស័យធន ឬបានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ ឬត្រូវបានបណ្តេញចេញពីក្រុមហ៊ុន ឬបានទទួលសាលក្រមតុលាការអនុញ្ញាតឲ្យដកខ្លួនចេញ ឬបញ្ជាឲ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ។[49]

ការណ៍ដែលបុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅបង្កឲ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ លើកលែងតែកិច្ចសន្យាក្រុមហ៊ុនបានចែងផ្សេងពីនេះ។ ក្រុមហ៊ុនអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆ័ន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់ទុក និងការចុះបញ្ជីដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។[50]

## ២.២. ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺជាក្រុមហ៊ុនដែលបង្កើតឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែលក្នុងនោះមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យធ្វើជាអ្នកគ្រប់គ្រងទទួលខុសត្រូវ និងមានកាតព្វកិច្ច ចាត់ចែងក្នុងក្រុមហ៊ុន ជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬច្រើននាក់ដែលមានកាតព្វកិច្ចបង់ភាគហ៊ុនចូលទៅក្នុងក្រុមហ៊ុននេះ។[51] ហើយមានម្ចាស់ហ៊ុនពីរប្រភេទ គឺ ប្រភេទទីមួយគឺ ជាម្ចាស់ហ៊ុន ដែល

---

[49] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៤៨

[50] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៤៩

[51] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៦៤

តាមច្បាប់ហៅថា "សហកម្មសិទ្ធិករទូទៅ" និងមួយទៀត គឺជា "សហកម្មសិទ្ធិករមានកម្រិត"។ សហកម្មសិទ្ធិករទូទៅ គឺជាអ្នកដាក់ទុនចូលក្នុងក្រុមហ៊ុនផង និងជាអ្នកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុនផង ប៉ុន្តែ ត្រូវមានការទទួលខុសត្រូវទៅលើបំណុលរបស់ក្រុមហ៊ុន ដោយគ្មានកម្រិត (គឺដូចជាករណីម្ចាស់ហ៊ុន ក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ)។ សហកម្មសិទ្ធិករមានកម្រិត ដាក់តែទុនចូលទៅក្នុងក្រុមហ៊ុនប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងកិច្ចការក្រុមហ៊ុនទេ ប៉ុន្តែ ការទទួលខុសត្រូវលើបំណុល គឺមានកម្រិតត្រឹមតែដើមទុន ដែលបានដាក់ចូលក្នុងក្រុមហ៊ុនប៉ុណ្ណោះ។ ក្នុងករណីក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលគេ ម្ចាស់ហ៊ុន ដែលជាសហកម្មសិទ្ធិករមានកម្រិត មិនមានកាតព្វកិច្ចចេញលុយពីហោប៉ៅខ្លួនឯង ឬក៏លក់ទ្រព្យខ្លួនឯង ដើម្បីសងបំណុលគេ ដូចជា សហកម្មសិទ្ធិករទូទៅទេ។ ម្យ៉ាងទៀត ដើមទុនដែលសហកម្មសិទ្ធិករមានកម្រិតអាចដាក់ចូលក្នុងក្រុមហ៊ុនបាន គឺអាចត្រឹមតែជាលុយ ឬទ្រព្យសម្បត្តិប៉ុណ្ណោះ មិនអាចដាក់ដើមទុនជាចំណេះដឹង ដូចសហកម្មសិទ្ធិករទូទៅទេ។

### ២.២.១. លក្ខណៈទូទៅ

បុគ្គលម្នាក់អាចជាសហកម្មសិទ្ធិករទូទៅផង និងសហកម្មសិទ្ធិករមានកម្រិតផង នៅក្នុងក្រុមហ៊ុន មានសិទ្ធិ និងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅ ដែលទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នានូវបំណុលទាំងឡាយចំពោះតតិយជន។[52] ក្រុមហ៊ុនសកម្មសិទ្ធិមានកម្រិត ចុះបញ្ជីពាណិជ្ជកម្ម ស្របទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។ បើមិនចឹងទេ ក្រុមហ៊ុននេះនឹងត្រូវចាត់ទុកថាជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ក្រុមហ៊ុសហកម្មសិទ្ធិមានកម្រិត អនុញ្ញាតឱ្យសមាជិកជាសហកម្មសិទ្ធិករមានកម្រិតទទួលយកភាគទុនថ្មីៗថែមទៀត។ ដោយសារថា ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនតម្រូវឱ្យសមាជិកដែលមានកម្រិតចាត់ចែងអាជីវកម្មបានទេ។ ហេតុនេះ វាមានលក្ខណៈងាយស្រួលដើម្បីទទួលសមាជិកថ្មីបន្ថែម ហើយក្រុមហសកម្មសិទ្ធិមានកម្រិតនេះ មិនត្រូវបានរំលាយដោយស្វ័យប្រវត្តិព្រោះតែមរណៈភាព ឬការដកខ្លួនរបស់សមាជិកភាគហ៊ុននោះទេ។

#### ២.២.១.១. អំពីសហកម្មសិទ្ធិករ

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចបង្កើតដោយមានសមាជិកយ៉ាងហោចណាស់ម្នាក់ ឬច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិមានកម្រិតម្នាក់ឬច្រើននាក់ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ដោយ

[52] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៧៤

នៅក្នុងក្រុមហ៊ុនសហកម្មមានកម្រិតនេះបែងចែកសហកម្មសិទ្ធិករជាពីរប្រភេទ ក្នុងនោះមានសហកម្មសិទ្ធិករមានកម្រិតដោយពួកគេបានវិនិយោគទុនក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ និងទទួលខុសត្រូវត្រឹមកម្រិតទុនដែលបានដាក់ចូលនោះ នឹងប្រភេទសហកម្មសិទ្ធិករទូទៅ ចំពោះសហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនមានកម្រិតនេះ មានសិទ្ធិដឹកនាំ គ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងទទួលខុសត្រូវដូចទៅនឹងសហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសកម្មសិទ្ធិទៅដែរ។

**២.២.១.២.កម្មវត្ថុ**

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ទោះបីជាមានកម្មវត្ថុណាមួយក៏ដោយ ក៏វាជាក្រុមហ៊ុនពាណិជ្ជកម្មដែរ ប៉ុន្តែវាជាបញ្ហាមួយដែលគេត្រូវយកចិត្តទុកដាក់ ដោយសារវាជាបញ្ហាដែលនាំមកនូវការពិភាក្សារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុនក្នុងការប្រគល់នូវការទទួលខុសត្រូវទាំងអស់របស់ក្រុមហ៊ុនទៅលើសហកម្មសិទ្ធិករទូទៅ។

**២.២.១.៣.អំពីដើមទុន**

ដើមទុនក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានកមពី សហកម្មសិទ្ធិករទូទៅបង់ភាគទុនរបស់ខ្លួន ដូចក្នុងករណីនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ អាចបង់ជាប្រាក់ វត្ថុ សេវាបច្ចុប្បន្ន ឬ អនាគត។ វត្ថុដែលបង់ចូលក្រុមហ៊ុនដូចជា ម៉ាស៊ីន ដីធ្លី ជាដើម ត្រូវគិតជាសាច់ប្រាក់ និង ដោយមានការយល់ព្រមលើតម្លៃសាច់ប្រាក់នោះដោយសហកម្មសិទ្ធិករទូទៅទាំងអស់។ ពេលខ្លះភាគទុនរបស់សហកម្មសិទ្ធិករទូទៅខ្លះកើតពីសេវាដែលខ្លួនបានបំរើឱ្យក្រុមហ៊ុន។ ចំណែកឯសហកម្មសិទ្ធិករមានកម្រិតវិញ ដោយសារពួកគេជាអ្នកវិនិយោគទុន ការបង់ភាគទុននៃសហកម្មសិទ្ធិករប្រភេទនេះអាចធ្វើបានចំពោះតែការបង់ភាគទុនជាសាច់ប្រាក់ ឬ ជាវត្ថុប៉ុណ្ណោះ។ ការបង់ជាវត្ថុត្រូវគណនាជាសាច់ប្រាក់ដូចក្នុងករណីសហកម្មសិទ្ធិករទូទៅដែរ។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ។ សហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត។[53]

**២.២.២. លក្ខណៈឧទ្រង់**

លក្ខខណ្ឌទម្រង់ គឺជារបៀប ឬទម្រង់ផ្សេងៗ ដែលបង្ហាញពីជំហាន ឬបច្ចេកទេស ជាបន្តបន្ទាប់ពណ៌នានៅក្នុងសេចក្តីលម្អិតប្រាប់អំពីភារកិច្ច ឬការងារជាក់លាក់ណាមួយ ហើយតើគេត្រូវដោះស្រាយការងារនោះដោយវិធីសាស្ត្រណា យ៉ាងដូចម្តេច។

[53] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៧០

**២.២.២.១. កិច្ចសន្យា និងការផ្សព្វផ្សាយជាសាធារណៈ**

កិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដូចគ្នាទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតកើតឡើងដោយកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ តែអត្ថិភាពនៃក្រុមហ៊ុននេះត្រូវប្រកាសជាសាធារណៈ តាមរយៈការចុះបញ្ជី ព្រោះដោយសារតែក្រុមហ៊ុននេះមានសហកម្មសិទ្ធិករខ្លះជាសហកម្មសិទ្ធិករដែលទទួលខុសត្រូវត្រឹមតែទុននិនិយោគរបស់ខ្លួន។ ការប្រកាសជាសាធារណៈនេះជាការដាស់តឿនឱ្យដឹងថាសហកម្មសិទ្ធិករណាមានការទទួលខុសត្រូវគ្មានកម្រិត និងសហកម្មសិទ្ធិណាខ្លះមានការទទួលខុសត្រូវមានកម្រិត។ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ ក្នុងករណីកិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ និងសហកម្មសិទ្ធិករមានកម្រិតយ៉ាងតិចណាស់ម្នាក់ ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។ កិច្ចសន្យា ឬលក្ខន្តិកៈរបស់ក្រុមហ៊ុនអាចត្រូវបានធ្វើឡើងជាច្រើនច្បាប់តាមដែលអាចធ្វើទៅបាន។ កិច្ចសន្យានេះគេអាចយកទៅៈ

- ដាក់តម្កល់នៅទីស្នាក់ការក្រុមហ៊ុន
- ដាក់តម្កល់នៅស្ថាប័នដែលមានសមត្ថកិច្ច
- ចែកជូនដល់សមាជិកក្រុមហ៊ុនទាំងអស់។

កិច្ចសន្យាតែងតែមានបញ្ជាក់ពីបំណងផ្សេងៗរបស់ក្រុមហ៊ុន ដែលគេគួរតែមានការតាក់តែងសរសេរក្នុងលក្ខណៈមួយដែលងាយស្រួលទៅដល់លទ្ធភាពដែលអាចបត់បែនបាន។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបានបង្កើតតាមកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម ស្របទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ ក្នុងករណីក្រុមហ៊ុនមិនបានចុះបញ្ជីទេ ក្រុមហ៊ុននោះត្រូវចាត់ទុកជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ក្នុងករណីនេះក្រុមហ៊ុនគ្មានបុគ្គភាពគតិយុត្តិទេ។ ការផ្សាយជាសាធារណៈត្រូវធ្វើឡើងដើម្បីជាប្រយោជន៍កុំឱ្យមានសមាជិកណាទាញយកផលប្រយោជន៍ នៅពេលក្រុមហ៊ុនត្រូវបានគេចាត់ទុកជាមោឃៈ។

**២.២.២.២. អ្នកគ្រប់គ្រង**

ក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺមានតែសហកម្មសិទ្ធិករទូទៅទេដែលមានសិទ្ធិក្នុងការចាត់ចែង និងដឹកនាំក្រុមហ៊ុន ហើយក៏ជាអ្នកទទួលខុសត្រូវទាំងស្រុង។ ដោយសារសហកម្មសិទ្ធិករមានកម្រិតគ្រាន់តែជាអ្នកវិនិយោគដើម្បីរកប្រាក់ចំណេញប៉ុណ្ណោះ គាត់មិនមានសិទ្ធិ ចូលរួមក្នុងការចាត់ចែងក្រុមហ៊ុនទេ។ ការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតសឹងតែជាភារកិច្ចផ្តាច់មុខរបស់សហកម្មសិទ្ធិករទូទៅ។ សហកម្មសិទ្ធិករមានកម្រិតដែលចូលរួមក្នុងតួនាទីគ្រប់គ្រងណាមួយដែលជាសមត្ថកិច្ចរបស់ហកម្មសិទ្ធិទូទៅត្រូវបាន

ចាត់ទុកថាបានបោះបង់ឋានៈជាអ្នកទទួលខុសត្រូវមានកម្រិតទាក់ទងនឹងកិច្ចការដែលគាត់បានធ្វើ។

សហកម្មសិទ្ធិករមានកម្រិតមិនអាចចូលរួមនៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ។ សហកម្មសិទ្ធិករមានកម្រិតអាចធ្វើការពិនិត្យរបាយការណ៍ និងការរីកចំរើនរបស់ក្រុមហ៊ុន និងអាចផ្តល់គំនិតក្នុងការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបានគ្រប់ដំណាក់កាល។ សហកម្មសិទ្ធិករមានកម្រិតមិនអនុញ្ញាតឱ្យចរចាក្នុងកិច្ចការពាណិជ្ជកម្មណាមួយក្នុងនាមនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ មិនអនុញ្ញាឱ្យធ្វើជាភ្នាក់ងារក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬ មិនអនុញ្ញាតឱ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុននោះឡើយ។ សហកម្មសិទ្ធិករមានកម្រិតដែលប្រព្រឹត្តអំពើទាំងនោះ ត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចរបស់ក្រុមហ៊ុនដែលកើតឡើងដោយសារការប្រព្រឹត្តទាំងនោះ។ សហកម្មសិទ្ធិករមានកម្រិតអាចអនុញ្ញាតឱ្យទទួលខុសត្រូវដូចសហកម្មសិទ្ធិករទូទៅដែរ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ប្រសិនបើសកម្មភាពទាំងឡាយដែលបានរៀបរាប់រួចហើយ ឬ សារៈសំខាន់នៃសកម្មភាពទាំងនោះស្របតាមដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយមានភស្តុតាងបញ្ជាក់ថាសហកម្មសិទ្ធិករមានកម្រិតធ្វើសកម្មភាពក្នុងនាមសហកម្មសិទ្ធិករទូទៅពិតប្រាកដមែន។[54] សហកម្មសិទ្ធិករមានកម្រិតមិនមានសិទ្ធិក្នុងការគ្រប់គ្រងក៏ពិតមែន ប៉ុន្តែសហកម្មសិទ្ធិករមានកម្រិតមានសិទ្ធិក្នុងការទទួលបាននូវព័ត៌មានទាក់ទងនិងការដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។

## ២.៣ ការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ

### ២.៣.១ ការស្នើសុំអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណគឺជាសិទ្ធិអនុញ្ញាតក្នុងការប្រកបអាជីវកម្មដែលចេញដោយក្រសួងផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មនោះ។ ការមិនមានអាជ្ញាប័ណ្ណដែលតម្រូវឱ្យមាន ក្រុមហ៊ុននឹងត្រូវប្រឈមមុខនឹង ការពិន័យ បញ្ហា ផ្សេងៗជាច្រើន ឬការត្រូវបិទអាជីវកម្មជាដើម។ ដូចនេះដើម្បីដំណើរការអាជីវកម្មមួយបាន អ្នកអាចនឹងតម្រូវឲ្យមានអាជ្ញាប័ណ្ណមួយចំនួន។ ទោះជាយ៉ាងណា អាជ្ញាប័ណ្ណត្រូវស្នើសុំបន្តជារៀងរាល់ឆ្នាំ។

ការស្នើសុំអាជ្ញាប័ណ្ណនេះអាចនឹងមានភាពលំបាកចំពោះក្រុមហ៊ុនដែលទើបតែបង្កើតថ្មី ហើយនីតិវិធីក្នុងការស្នើសុំគឺមានភាពខុសៗគ្នាទៅតាមក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនោះ។ ដូចនេះហើយ វិធីមួយដែលងាយស្រួលអាចឱ្យអ្នកទទួលបានព័ត៌មានអំពីការស្នើសុំអាជ្ញាប័ណ្ណនេះ គឺការចូលទៅមើលនៅក្នុងគេហទំព័ររបស់ក្រសួងមុខងារសាធារណៈwww.service.gov.kh ឬក្នុងកម្មវិធីទូរស័ព្ទ ដែលមានឈ្មោះថា "ច្រកទ្វារអេឡិច

[54] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៧៩

ត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ" ដែលជាថ្នាលបច្ចេកវិទ្យាព័ត៌មានមួយដែលបង្ហាញពីសេវាសាធារណៈទាំងអស់។ នៅទីនោះអ្នកអាចស្វែងរកព័ត៌មានដែលទាក់ទងទៅនឹងការស្នើសុំអាជ្ញាប័ណ្ណពីក្រសួងផ្សេងៗគ្នា។ ព័ត៌មានដែលមានបង្ហាញនោះមានដូចជា គោលបំណង មូលដ្ឋានគតិយុត្ត អ្នកដែលមានសិទ្ធិទទួលសេវា ស្តង់ដារសេវា ឯកសារតម្រូវដើម្បីទទួលបានសេវា និងនីតិវិធីក្នុងការផ្តល់សេវា។[55] ព័ត៌មានទាំងអស់នេះមានធាតុខុសៗគ្នាអាស្រ័យទៅលើការតម្រូវរបស់ក្រសួងនីមួយៗដែលអ្នកចង់ស្នើសុំនោះ។

### ២.៣.២ ការចុះបញ្ជីក្រុមហ៊ុន

ការបង្កើតក្រុមហ៊ុនមួយដោយស្របតាមនីតិវិធីច្បាប់ កិច្ចសំខាន់ដែលសហកម្មសិទ្ធិករត្រូវបំពេញនោះគឺត្រូវចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួននៅក្រសួងពាណិជ្ជកម្មឱ្យទាន់ពេលវេលាដែលបានកំណត់នៅក្នុងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដោយក្នុងនោះបានចែងថា គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើត និងថេរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។[56] តាមរយៈការចុះបញ្ជីពាណិជ្ជកម្មនេះ វាគឺជាវិធីមួយ ដែលបានផ្លាស់ប្តូរស្ថានភាពអាជីវកម្មរបស់អ្នក ពី "ក្រៅផ្លូវការ" ទៅជា "ផ្លូវការ"។ ពាក្យទាំងពីរនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ "ផ្លូវការ" មានន័យថា អាជីវកម្មរបស់អ្នកត្រូវបានប្រកាសស្របច្បាប់ និងទទួលស្គាល់ដោយស្ថាប័ននៃប្រទេសកម្ពុជា។ យ៉ាងតិចបំផុតដប់ប្រាំថ្ងៃ ( ១៥ថ្ងៃ ) មុនពេលចាប់ផ្តើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន[57] នឹងដោយយោងតាមប្រកាសលេខ ២១៣ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម បានចែងថា រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថានសាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុ មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្មពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ www.businessregistration.moc.gov.kh។[58] គួរបញ្ជាក់ផងដែរថាកាលណាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនបានចុះបញ្ជីពាណិជ្ជកម្មទេនោះក្រុមហ៊ុនបែបនេះ នឹងក្លាយជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅវិញ។ ក្នុងករណីនេះក្រុមនេះក្រុមហ៊ុនពុំទទួលបាននីតិបុគ្គលិកលក្ខណៈទេ។ ជាក់ស្តែង

[55] http://www.service.gov.kh/category/174

[56] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ២៦ មិថុនា ១៩៩៥, មាត្រា១៧ វាក្យខណ្ឌ ១

[57] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ២៦ មិថុនា ១៩៩៥, មាត្រា១៤ វាក្យខណ្ឌ ១

[58] ប្រកាសលេខ ២១៣ ព.ណ.ចបព. ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម មាត្រា ១

ចំពោះការចុះបញ្ជីនេះ អ្នកនឹងត្រូវផ្តល់ព័ត៌មានមួយចំនួនអំពីអាជីវកម្មរបស់អ្នកដើម្បីទទួលបានវិញ្ញាបនបត្រក្នុងការចុះបញ្ជីពាណិជ្ជកម្ម ។

ទោះបីជាយ៉ាងណាក្តី ដោយសារតែការចុះបញ្ជីក្រុមហ៊ុននេះមិនមែនត្រូវតែធ្វើឡើងនៅក្រសួងពាណិជ្ជកម្មតែប៉ុណ្ណោះទេ។ ការចុះបញ្ជីក្រុមហ៊ុនត្រូវធ្វើជាមួយនឹងក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាត្រូវចុះបញ្ជីជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ ប្រសិនបើក្រុមហ៊ុននោះទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ជាភាពងាយស្រួលនៃការចុះបញ្ជី នាពេលបច្ចុប្បន្ននេះ អ្នកអាចធ្វើការចុះបញ្ជីទាំងនេះបានតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានត្រឹមតែមួយប៉ុណ្ណោះ គឺតាមប្រព័ន្ធដែលមានឈ្មោះថា CamDX ឬ ហៅកាត់ថា Single Portal ដែលជាថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល។ ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គឺជានីតិវិធីនៃការចុះបញ្ជីអាជីវកម្មថ្មីដែលមានលក្ខណៈបង្រួបបង្រួម និងធ្វើឡើងតាមអនឡាញទាំងស្រុងដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យាព័ត៌មាន។ ដំណើការចុះបញ្ជីថ្មីនេះ ការចុះបញ្ជីអាជីវកម្មមួយចំណាយពេលយ៉ាងយូរត្រឹមតែ៨ថ្ងៃប៉ុណ្ណោះ ហើយបង់ថ្លៃសេវាតិចជាងមុន។

### ២.៣.២.១ កម្រៃនៃការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ

- កម្រៃនៃការចុះបញ្ជីនៃក្រសួងពាណិជ្ជកម្មចំពោះក្រុមហ៊ុនសហកម្មសិទ្ធិគឺ១.០១ លានរៀល។
- កម្រៃនៃការចុះបញ្ជិកាសេចក្តីជូនដំណឹងបើកសហគ្រាសនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ គឺ ១២០លានរៀល។
- កម្រៃនៃការបង់ពន្ធប៉ាតង់ និង កម្រៃចុះបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារគឺយកទៅតាមប្រភេទអ្នកជាប់ពន្ធ។
    - ការបង់ពន្ធប៉ាតង់សម្រាប់សកម្មភាពអាជីវកម្មមួយ
        - អ្នកជាប់ពន្ធតូច ៖ ២០០ ពាន់រៀល
        - អ្នកជាប់ពន្ធមធ្យម ៖ ៦០០០ ពាន់រៀល
        - អ្នកជាប់ពន្ធធំ ៖១.៥ លានរៀល សម្រាប់ក្រុមហ៊ុនដែលមានផលរបរធំជាង ៤ពាន់លានរៀល ឬមានផលរបរតូចជាងឬស្មើនឹង ១០ ពាន់លានរៀល និង ត្រូវបង់ ២.៥ លានរៀល សម្រាប់ក្រុមហ៊ុនដែលមានផលរបរធំជាង ១០ ពាន់លានរៀល។

- កម្រៃចុះបញ្ជីពន្ធដារ
    - អ្នកជាប់ពន្ធតូច ៖ ២០ ពាន់រៀល
    - អ្នកជាប់ពន្ធមធ្យម ៖ ៤០០ ពាន់រៀល
    - អ្នកជាប់ពន្ធធំ ៖ ៤០០ ពាន់រៀល

**២.៣.២.២ ឯកសារក្នុងការចុះបញ្ជីពាណិជ្ជកម្ម**

- ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម លិខិតធានាគារជាដើម។
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃខាងក្រោយពណ៌ស របស់អ្នកគ្រប់គ្រង់, សហកម្មសិទ្ធិករ(ករណីសហកម្មសិទ្ធិជារូបវន្តបុគ្គល) និង/ឬអ្នកតំណាង (ករណីសហកម្មសិទ្ធិករជានីតិបុគ្គល)។
- ឯកសារអត្តសញ្ញាណប័ណ្ណរបស់អ្នកគ្រប់គ្រង់, សហកម្មសិទ្ធិករ(ករណីសហកម្មសិទ្ធិជារូបវន្តបុគ្គល) និង/ឬអ្នកតំណាង (ករណីសហកម្មសិទ្ធិករជានីតិបុគ្គល)។
- កិច្ចសន្យាក្រុមហ៊ុន
- ឯកសារយោង(អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ករណីសហកម្មករសិទ្ធិជានីតិបុគ្គល
    - លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ
    - វិញ្ញាបនបត្រក្រុមហ៊ុនមេ
    - លក្ខន្តិកៈក្រុមហ៊ុនមេ
- លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ។

**២.៣.២.៣ ឯកសារក្នុងការចុះបញ្ជីពន្ធដារ**

- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលទ្រព្យរបស់សហគ្រាស
- ករណីក្រុមហ៊ុនទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

- ព័ត៌មានអំពីគណនីធនាគារ (ត្រូវផ្តល់ក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានការទទួល ការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល។ ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារត្រូវបានដកហូតដោយស្វ័យប្រវត្តិ)។

### ២.៣.២.៤ របៀបនៃការចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដើម្បីដំណើការការចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌បានអ្នកត្រូវចូលទៅកាន់ www.registrationservices.gov.kh រួចចុច " ចុះបញ្ជីអាជីវកម្ម" បន្ទាប់មកត្រូវធ្វើតាមជំហានធំៗទាំង៦ដូចខាងក្រោមនេះ៖[59]

ទី១៖ បង្កើតគណនីលើ CamDigiKey។

ទី២៖ Log In ដោយប្រើប្រាស់កម្មវិធី CamDigiKey។

ទី៣៖ បំពេញព័ត៌មាន និងឯកសារតម្រូវ។ នៅត្រង់ចំណុចនេះ គឺជាការបំពេញព័ត៌មាន និង ភ្ជាប់ឯកសារទៅលើទម្រង់បែបបទនៃការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីពន្ធដារ និង សេចក្តីប្រកាសជូនដំណឹងការបើកសហគ្រាស។

ទី៤៖ ធ្វើការទទូទាត់សងប្រាក់តាមមធ្យោបាយទូទាត់សងប្រាក់អនឡាញដែលមានស្រាប់។

ទី៥៖ ទទួលបានការសម្រេចក្នុងរយៈពេល ៨ ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ។ នៅត្រង់នេះអ្នកនឹងអាចត្រូវបានស្នើសុំឯកសារបន្ថែម ប្រសិនបើប្រព័ន្ធរកឃើញថាមានកំហុសណាមួយ។

ទី៦៖ ទាញយក និងបោះពុម្ពអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថលចំនួន ៥ និងប័ណ្ណពន្ធប៉ាតង់ ប្រសិនបើទទួលការអនុញ្ញាត។

## ២.៤. ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដូចខាងក្រោម៖

### ២.៤.១. មូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

- មូលហេតុដែលមានចែងក្នុងកិច្ចសន្យា
- គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់
- គ្មានលទ្ធភាពធ្វើអាជីវកម្ម

[59] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន*, (ភ្នំពេញ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២០), ១៦-១៧

- គ្មានការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ
- ការរំលាយដោយតុលាការ (តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់ )[60]។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដែលមានចែងក្នុងកិច្ចសន្យា (ដូចជា គោល-បំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត និងតាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ) និងដោយតុលាការស្របទៅតាមមូលហេតុច្បាប់។ នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន។ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ។[61] ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់សិទ្ធិតតិយជនដែលធ្វើពាណិជ្ជកម្មជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬមិនប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។[62]

### ២.៤.២. ការជម្រះបញ្ជី

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន។ សហ-កម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផង។ សហកម្មសិទ្ធិករទូទៅត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤ សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់

[60] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៥៣
[61] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៥៦
[62] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៥៧

ខ្លួននៅទីនោះ ឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម។[63]

នៅពេលធ្វើការរំលាយក្រុមហ៊ុន អ្នកជម្រះបញ្ជីមានសិទ្ធិក្នុងការកាន់កាប់ ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិក្រុមហ៊ុន ព្រមទាំងមានសិទ្ធិទាមទារពីសហកម្មសិទ្ធិករទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិ និងកាតព្វកិច្ចនៃក្រុមហ៊ុន។[64]អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ រួចទើបធ្វើការបែងចែកភាគទុន។ អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិដែលនៅសល់ឲ្យទៅសហកម្មសិទ្ធិករទាំងឡាយណាទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យានោះទេ។ ក្នុងករណីដែលទ្រព្យរបស់ក្រុមហ៊ុនមានទាំងទ្រព្យសម្បត្តិរបស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឲ្យតតិយជននោះវិញ។[65] ចាប់ពីពេលដែលបានជម្រះបញ្ជីរួច អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនរហូតដល់រយៈពេល ១០ ឆ្នាំ ឬសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះតម្រូវឲ្យទុកជាភស្តុតាង។[66]ការជម្រះបញ្ជីក្រុមហ៊ុនត្រូវបញ្ចប់ ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះនៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក។ ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។

### ២.៤.៣.ការបែងចែកទ្រព្យសម្បត្តិនៅពេលរំលាយ

ការបែងចែកទ្រព្យសម្បត្តិនៅពេលរំលាយជារឿងមួយដែលសំខាន់។ ទ្រព្យសម្បត្តិរួមមាន ទ្រព្យរូបី និងអរូបី។ គេអាចចែងពីខនៃការបែងចែកទ្រព្យសម្បត្តិដូចខាងក្រោម៖

នៅពេលចប់កិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនេះ ភាគីទាំងអស់ត្រូវជួយគ្នាដើម្បីគិតបញ្ជីទ្រព្យ និងបំណុលទាំងអស់។ ទ្រព្យសម្បត្តិក្រុមហ៊ុនរួមមានកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ត្រូវដាក់ឱ្យភាគីមុនគេ ហើយភាគីដែលឱ្យថ្លៃខ្ពស់ជាងគេបំផុតត្រូវអនុញ្ញាតឱ្យទិញទ្រព្យនោះ។ បើគ្មានភាគីណាទិញទេ ទ្រព្យទាំងនោះត្រូវលក់ឱ្យតតិយ-ជនណាដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេ។ ប្រាក់ដែលបានមកពីការលក់នេះត្រូវយកទៅសងបំណុល។ ប្រាក់ដែលនៅសល់ពីសំណងបំណុលត្រូវយកមកចែកក្នុងបណ្តាភាគីទាំងអស់។ នៅពេលក្រុមហ៊ុន

---

[63] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៥៩

[64] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៦០

[65] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៦១

[66] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៦២

សហកម្មសិទ្ធិត្រូវបានរំលាយចប់ហើយ ភាគីទាំងអស់ត្រូវបញ្ជាក់ប្រាប់គ្នាទៅវិញទៅមកឱ្យបានពេញលេញនិងត្រឹមត្រូវនូវវត្ថុទាំងអស់ដែលទាក់ទងនឹងក្រុមហ៊ុន ព្រមទាំងភាគហ៊ុននិងរបស់ប្រើប្រាស់ រួមទាំងការបានចំណេញនិងការកើនតម្លៃពីភាគហ៊ុន និងរបស់ប្រើប្រាស់ទាំងនោះ ដែលសល់នៅក្នុងសណ្ឋានជាសាច់ប្រាក់ ទំនិញ បំណុល ឬអ្វីផ្សេងទៀត ត្រូវយកមកចែកគ្នាទៅតាមសមាមាត្រនៃទុនដែលសហកម្មសិទ្ធិករបានចូលរួមក្នុងដើមទុនរបស់ក្រុមហ៊ុន។

### ២.៤.១. ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

មូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺដូចទៅនឹងករណីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។ សហកម្មសិទ្ធិករទូទៅមិនអាចបន្តទៀត និងជំនួសដោយសហកម្មសិទ្ធិករមានកម្រិត១២០ ថ្ងៃ ផ្នែករដ្ឋបាល។ គ្មានសហកម្មសិទ្ធិករទូទៅជំនួស១២០ថ្ងៃទេក្រុមហ៊ុនត្រូវបានបញ្ចប់។ កាលណាមកដល់វេលាកំណត់ ៩៩ ឆ្នាំ មិនបន្តទៀតនោះ ឬសហកម្មសិទ្ធិករទូទៅណាម្នាក់ទទួលមរណៈភាព នាំឱ្យក្រុមហ៊ុនត្រូវបានបញ្ចប់ដូចគ្នា។ ចំពោះសហកម្មសិទ្ធិករមានកម្រិតណាម្នាក់ទទួលមរណៈភាព ឬបាត់បង់សមត្ថភាព ធនក្ស័យមិនបណ្តាលឲ្យរំលាយក្រុមហ៊ុនទេ ព្រោះសហកម្មសិទ្ធិករមានកម្រិតត្រូវបានគេចាត់ទុកត្រឹមជាអ្នកវិនិយោគទុនប៉ុណ្ណោះ។ ចំពោះការជម្រះបញ្ជីក៏ដូចគ្នានឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ។

## ២.៥. គុណសម្បត្តិ និង គុណវិបត្តិចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ

### ២.៥.១. គុណសម្បត្តិក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

- ការទទួលខុសត្រូវលើបំណុលដោយមានកម្រិត៖ ក្នុងករណីក្រុមហ៊ុនមិនមានលុយសងបំណុលគេ ម្ចាស់ហ៊ុន ដែលជាសហកម្មសិទ្ធិករមានកម្រិត មិនមានកាតព្វកិច្ចសងជាលុយផ្ទាល់ខ្លួន ឬក៏ត្រូវលក់ទ្រព្យខ្លួនឯង ដើម្បីសងបំណុលគេ ដូចជា សហកម្មសិទ្ធិករទូទៅទេ។ ពោលគឺពួកគេមានការទទួលខុសត្រូវក្នុងកម្រិតត្រឹមតែដើមទុន ដែលបានដាក់ចូលក្នុងក្រុមហ៊ុនប៉ុណ្ណោះ។
- ផលប្រយោជន៍របស់ម្ចាស់ហ៊ុន៖ ម្ចាស់ហ៊ុនដែលជាសហកម្មសិទ្ធិករមានកម្រិតអាចឃើញពីផលប្រយោជន៍របស់ខ្លួន គឺនៅពេលដែលពួកគេមើលទៅឃើញថា អាជីវកម្មមួយមានសក្តានុពល ក្នុងការរកប្រាក់ចំណេញ គាត់អាចចូលរួមជាដើមទុន ដោយមិនចាំបាច់មានជំនាញ ហើយការទទួលខុសត្រូវរបស់គេ គឺកម្រិតត្រឹមតែដើមទុនដែលគាត់ចូលរួម ដោយមិនប៉ះពាល់ដល់ទ្រព្យផ្ទាល់ខ្លួន។

### ២.៥.២. គុណវិបត្តិក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

- សិទ្ធិចាត់ចែងក្រុមហ៊ុន៖ សហកម្មសិទ្ធិករមានកម្រិតដាក់តែទុនចូលទៅក្នុងក្រុមហ៊ុនប៉ុណ្ណោះ ដោយមិនមានសិទ្ធិគ្រប់គ្រង ឬចាត់ចែងកិច្ចការក្រុមហ៊ុនទេ ហើយត្រូវពឹងទៅលើម្ចាស់ហ៊ុន ដែលជាសហកម្មសិទ្ធិករទូទៅ។
- ការដាក់ដើមទុន៖ ប្រសិនបើគ្មានការព្រមព្រៀងដោយសំឡេងភាគច្រើនដាច់ខាតពីម្ចាស់ហ៊ុនទាំងអស់ទេ សហកម្មសិទ្ធិករមានកម្រិតដែលបានដាក់ហ៊ុនចូលទៅក្នុងក្រុមហ៊ុនគឺមិនអាចដកចេញមកវិញបានទេ។ ដូចនេះប្រសិនបើ ក្រុមហ៊ុនមានការខាតបង់ដែលធ្វើឱ្យ ក្រុមហ៊ុនត្រូវក្ស័យធន នោះដើមទុន និងទ្រព្យសម្បត្តិទាំងអស់ត្រូវយកទៅសងបំណុលគេអស់ហើយ ម្ចាស់ហ៊ុនជាសហកម្មសិទ្ធិករមានកម្រិតក៏មិនអាចទាមទារឲ្យក្រុមហ៊ុនសងដើមទុនរបស់ខ្លួនមកវិញបានដែរ។

### ២.៥.៣. គុណសម្បត្តិក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

- ដើមទុន៖ ក្រុមហ៊ុនសហកម្មសិទ្ធិ អាចចាប់ផ្តើមដំណើរការបានដោយមិនទាមទារដើមទុនច្រើន ហើយមានគ្នាតែពីរបីនាក់រួមគ្នា ដោយផ្តល់ជា កម្លាំង ពេលវេលា ជំនាញ និងដើមទុនម្នាក់បន្តិចៗ ល្មមអាចចូលគ្នា ដើម្បីទិញ ឬជួលទីតាំង និងសម្ភារៈសំខាន់ៗចាំបាច់។
- ឯកសារ៖ ដំណើរការបង្កើតជាក្រុមហ៊ុនសហកម្មសិទ្ធិ ដើម្បីប្រកបអាជីវកម្មបាន មិនតម្រូវឲ្យមានឯកសារច្បាប់អ្វីស្មុគស្មាញច្រើន។

### ២.៥.៤. គុណវិបត្តិក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

- ការទទួលខុសត្រូវលើបំណុល៖ ក្នុងករណីមានវិវាទរឿងមិនសងបំណុល ម្ចាស់បំណុលអាចប្តឹងទាមទារបំណុលទាំងអស់ពីម្ចាស់ហ៊ុនណាមួយតែម្នាក់ក៏បាន។ ដូចនេះ បើមានម្ចាស់ហ៊ុនណាម្នាក់ដែលត្រូវម្ចាស់បំណុលប្តឹង គឺត្រូវតែសងបំណុលទាំងអស់តាមបណ្តឹង ពោលគឺសងទាំងចំណែកបំណុលខ្លួនឯង និងចំណែកបំណុលរបស់ម្ចាស់ហ៊ុនផ្សេងទៀត រួចហើយគាត់អាចទៅទាមទារគិតគូរទូទាត់ជាមួយម្ចាស់ហ៊ុនផ្សេងទៀតតាមក្រោយ។
- ការទទួលខុសត្រូវលើបំណុលដោយគ្មានកម្រិត៖ នៅករណីដែល ក្រុមហ៊ុនរកស៊ីខាតបង់ ជំពាក់បំណុលគេច្រើន ហើយក្រុមហ៊ុនមិនមានលទ្ធភាពសង នោះម្ចាស់ភាគហ៊ុនត្រូវចេញលុយសងដោយជាលុយផ្ទាល់ខ្លួន ឬត្រូវលក់ទ្រព្យខ្លួនឯង ដើម្បីសងបំណុលគេ។ លើសពីនេះទៅទៀត ការបង្កើតក្រុមហ៊ុនប្រភេទនេះ អ្នកដែលចូលហ៊ុន ចាំបាច់ត្រូវតែមានជំនឿទុកចិត្តគ្នាខ្លាំង ពីព្រោះ ក្នុងករណីមាន

បញ្ហាជាប់បំណុល បើសិនជាមានម្ចាស់ភាគហ៊ុនណាមួយមិនព្រមសង ម្ចាស់ភាគហ៊ុនមួយទៀតមានកាតព្វកិច្ចសងបំណុលជំនួស។

# ជំពូកទី៣
# នីតិវិធី និងការបង្កើតក្រុមហ៊ុនមូលធន

ការដែលនាំឱ្យមានការបង្កើតក្រុមហ៊ុនមូលធនគឺមានមូលហេតុជាច្រើន ដោយសារតម្រូវការរបស់រូបវន្តបុគ្គលក៏ដូចជានីតិបុគ្គល ហើយតម្រូវការទីមួយនោះគឺផ្នែកហិរញ្ញវត្ថុ មានន័យថាអ្នកដែលបង្កើតក្រុមហ៊ុនទាំងនោះ បង្កើតក្រុមហ៊ុនឡើងក្នុងគោលបំណងស្វែងរកផលចំណេញ ឬប្រាក់ចំណេញ ដើម្បីយកមកផ្គត់ផ្គង់ជីវភាពក្នុងក្រុមហ៊ុន។ ជាដំបូងបង្អស់គេត្រូវសិក្សាបញ្ហាជាច្រើនមុននឹងសម្រេចចិត្តបង្កើតក្រុមហ៊ុន។ នៅក្នុងនោះការសិក្សាពីបញ្ហាច្បាប់ពិតជាសំខាន់ណាស់ដើម្បីឱ្យក្រុមហ៊ុនអាចដំណើរការបានដោយស្របតាមបទបញ្ញត្តិច្បាប់។ ដោយនៅក្នុងជំពូកនេះដែរយើងនឹងសិក្សាទៅលើ ការបង្កើតក្រុមហ៊ុនមូលធន (៣.១) ការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីពាណិជ្ជកម្ម (៣.២) ការរំលាយក្រុមហ៊ុនមូលធន (៣.៣) និង ចំណុច (៣.៤) និយាយអំពី គុណសម្បត្តិ និងគុណវិបត្តិនៃការបង្កើតក្រុមហ៊ុនមូល

## ៣.១. ការបង្កើតក្រុមហ៊ុនមូលធន

ការបង្កើតក្រុមហ៊ុនមូលធន ជាគោលការណ៍ត្រូវបានគេធ្វើឡើងតាមពីររបៀប ទីមួយធ្វើតាមការអំពាវនាវឱ្យមានការចូលរួមពីមហាជន និងការបង្កើតឡើងតាមវិធីទីពីរគឺ មិនមានការអំពាវនាវឱ្យមានការចូលរួមពីមហាជនទេ។[67] បើនិយាយពីលក្ខណៈរួមវិញ ក្រុមហ៊ុនមូលធន (ទោះជាក្រុមហ៊ុនឯកជនក៏ដោយ ឬជាក្រុមហ៊ុនមហាជនក៏ដោយ) ដើម្បីអាចបង្កើតឡើងបាន ត្រូវតែមានមូលធនយ៉ាងតិចបំផុត ៤លានរៀល (ប្រហែលជា ១ពាន់ដុល្លារ អាមេរិក)។ នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈក្រុមហ៊ុនឱ្យទៅ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។[68] មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យនូវនាមករណ៍ដែលបានដាក់ស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធនូវនាមករណ៍ណា ដែលមើលទៅឃើញថាប្រហាក់ប្រហែលគ្នាធ្វើឱ្យមានការភាន់ច្រឡំទៅនឹងនាមករណ៍របស់ក្រុមហ៊ុនមួយទៀត ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនរួចហើយ ឬដែលមិនសមរម្យ។ សេចក្តីសម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជ

[67] ឯកឧត្តម កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥), ២២៨

[68] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩១

កម្មដែលពាក់ព័ន្ធ នៅនឹងនាមករណ៍ក្រុមហ៊ុន គឺជាសេចក្ដីសម្រេចចុងក្រោយ។[69] ការបង្កើតក្រុមហ៊ុនមូលធន ត្រូវបង្កើតឡើងតាមលក្ខណៈគ្រឹះ និងលក្ខណៈទម្រង់។

### ៣.១.១. លក្ខណៈគ្រឹះ

#### ៣.១.១.១. ការព្រមព្រៀង

ក្រុមហ៊ុនមួយត្រូវបានកើតឡើងត្រូវឈរលើគោលការណ៍នៃការព្រមព្រៀង ជាកត្តាមួយដែលសំខាន់ ព្រោះមុននឹងឈានដល់ការព្រមព្រៀងនេះសមាជិកហ៊ុននីមួយៗត្រូវឆ្លងកាត់ការចរចារ និងពិភាក្សាចំពោះមុខគ្នា ដើម្បីស្វែងយល់ពីខ្លឹមសារនៃអត្ថបទ និងបែបបទនៃការបង្កើតក្រុមហ៊ុននោះ។ ការព្រមព្រៀងរវាងសមាជិក ទាំងឡាយត្រូវតែមានដោយពិតប្រាកដចំពោះគ្នា។ ក្រុមហ៊ុនមូលធន ត្រូវបង្កើតឡើងដោយការព្រមព្រៀងជាលាយលក្ខអក្សរ លក្ខន្តិៈអាចធ្វើឡើងតាមរូបភាពជាលិខិតឯកជន ឬជាលិខិតសារការី។ គ្រប់ទំព័រលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬហត្ថលេខាសង្ខេបដោយ សមាជិកទាំងអស់របស់ក្រុមហ៊ុននោះ។[70]

សរុបមកវិញ សមាជិកភាគហ៊ុនទាំងអស់ត្រូវឈរលើគោលការណ៍គ្រឹះមួយ និងប្រកបដោយឆន្ទៈពិតប្រាកដរវាងគ្នានៅក្នុងកិច្ចសន្យានៃការព្រមព្រៀងនោះ។

#### ៣.១.១.២. កម្មវត្ថុ

ការបង្កើតក្រុមហ៊ុនត្រូវមានកម្មវត្ថុជាចម្បងមួយ។ ក្រុមហ៊ុនមូលធន បង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ហើយកម្មវត្ថុនោះត្រូវតែស្របច្បាប់និងត្រូវចុះបញ្ជីនូវកម្មវត្ថុរបស់ក្រុមហ៊ុន ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបានច្បាប់ហាមឃាត់ក្នុងករណីមួយចំនួន។ ចំពោះកម្មវត្ថុនេះផងដែរ គឺមិនត្រូវមានការបំពានទៅដល់សណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់ជាតិ និងផលប្រយោជន៍សមាជិកហ៊ុននោះឡើយ។

#### ៣.១.១.៣. សមត្ថភាពរបស់សមាជិក

នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើនដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ ដូច្នេះវាមិនទាមទារឱ្យសមាជិកហ៊ុនត្រូវតែជាពាណិជ្ជករនោះទេ។ រូបវន្តបុគ្គលដែលមានសមត្ថភាពខាងផ្នែករដ្ឋប្បវេណី អាចចូលជាសមាជិកភាគហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបាន។ អនីតិជនដែលទទួលបានអត្តាធិនភាព ក៏អាចចូលរួមដោយដាក់ភាគហ៊ុនដោយសេរីបាននៅក្នុងក្រុមហ៊ុន។ មិនតែ

[69] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៩២ កថាខណ្ឌ២

[70] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៩៥

ប៉ុណ្ណោះ អនីតិជននិងជនដែលការពារដោយច្បាប់ នៅតែអាចចូលហ៊ុនបាន តែវាត្រូវធ្វើឡើងតាមរយៈវិធានរដ្ឋប្បវេណីដែលចែងអំពីតួនាទីអាណាព្យាបាលទូទៅ ដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការធ្វើតំណាង។[71] ក្រុមហ៊ុនអាចត្រូវបានបង្កើតរវាងសមាជិកនានា ហើយពួកគេទទួលខុសត្រូវតែក្នុងកម្រិតនៃភាគទុនរបស់ខ្លួនប៉ុណ្ណោះ។ ទម្រង់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចមានចំនួនសមាជិកយ៉ាងតិច ២ (ពីរ) នាក់ និងមានចំនួនយ៉ាងច្រើន ៣០ (សាមសិប)នាក់។

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមានលក្ខណៈខុសគ្នាពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រង់ចំនួននៃម្ចាស់ភាគហ៊ុន ដោយសមាជិកនៃម្ចាស់ភាគហ៊ុនយ៉ាងតិចចាប់ពី ២រូប ឡើងទៅដោយមិនកំណត់ចំនួនអតិបរិមាឡើយរូបវន្តបុគ្គល អាចចូលជាសមាជិកដើម្បីធ្វើជាម្ចាស់ភាគហ៊ុនគឺបែងចែកទៅតាមសមាមាត្រនៃម្ចាស់ភាគហ៊ុនអាស្រ័យទៅលើដើមទុនតិច ឬច្រើនរបស់ម្ចាស់ភាគហ៊ុននីមួយ។

### ៣.១.១.៤. អំពីដើមទុន

ម្ចាស់ភាគហ៊ុនទាំងអស់ត្រូវចូលហ៊ុនគ្នាជាសាច់ប្រាក់ រាល់ដើមទុនរបស់ម្ចាស់ហ៊ុនម្នាក់ៗ នៅក្នុងក្រុមហ៊ុនត្រូវប្រកាសជារូបិយវត្ថុជាតិ ម្ចាស់ភាគហ៊ុនមិនអាចក្លាយជាម្ចាស់ហ៊ុន ដោយដាក់ហ៊ុនជាសេវា ឬចំណេះដឹង និងបច្ចេកទេស មកចូលហ៊ុនបានទេ ដែលផ្ទុយពីក្រុមហ៊ុនសហកម្មសិទ្ធិដោយក្រុមហ៊ុនសហកម្មសិទ្ធិ កិច្ចសន្យាអាចបង្កើតឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរហើយចំពោះភាគហ៊ុនអាចចូលហ៊ុនគ្នា ដោយយក ថវិកា ចំណេះដឹង បច្ចេកទេស និងសេវា។ តែចំពោះអចលនវត្ថុ ក្រុមហ៊ុនមមូលធន អាចកំណត់យកមកដាក់ចូលហ៊ុនបានអាស្រ័យទៅលើការព្រមព្រៀង ឬលក្ខន្តិកៈរបស់ក្រុមហ៊ុន ដោយអចលនវត្ថុនោះត្រូវបានវាយតម្លៃដោយក្រុមហ៊ុនអចលនទ្រព្យស្របច្បាប់ ហើយគិតជាតម្លៃសាច់ប្រាក់ដូចម្ចាស់ភាគហ៊ុនដទៃទៀតដែល។

ភាគហ៊ុន ជាសិទ្ធិដើម្បីទទួលនូវសមាមាត្រនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន និងសមាមាត្រនៃដើមទុនរបស់ក្រុមហ៊ុន នៅពេលដែលគេជម្រះបញ្ជីក្រុមហ៊ុន។ តាមន័យនេះ ភាគហ៊ុនផ្តល់ឱ្យម្ចាស់របស់វានូវផលប្រយោជន៍ពីរយ៉ាងនៅក្នុងក្រុមហ៊ុន គឺទីមួយ សិទ្ធិដើម្បីមានចំណែកនៅក្នុងចំណូលដែលក្រុមហ៊ុនរកបានទៅតាមចំនួនវិនិយោគរបស់ម្ចាស់ហ៊ុន និងទីពីរ គឺជាសិទ្ធិចូលរួមនៅក្នុងទ្រព្យដែលនៅសល់របស់ក្រុមហ៊ុននៅពេលរំលាយ។[72]

ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេ នោះក្រុមហ៊ុនត្រូវមាន

---

[71]គង់ សាផន, *នីតិពាណិជ្ជកម្ម*, (ភ្នំពេញៈ អ៊ីម៉េក ព្រីនធីង, ២០១២), ១៩៨

[72] កុយ នាម, *ច្បាប់ក្រុមហ៊ុន*, ឆ្នាំ២០១៦, ៣១៩

ប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នា និងរួមបញ្ចូលនូវសិទ្ធិ៖

- ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន។
- ក្នុងការទទួលនូវរាល់ភាគលាភ ដែលបានប្រកាសដោយក្រុមហ៊ុន។
- ក្នុងការទទួលនូវទ្រព្យ ដែលនៅសេសសល់របស់ក្រុមហ៊ុន នៅពេលមានការរំលាយ។[73]

#### ៣.១.១.៥. អំពីនាមករណ៍

នាមករណ៍ក្រុមហ៊ុនមូលធន ដូចដែលបានរៀបរាប់ពីខាងដើមរួចមកហើយថាឈ្មោះក្រុមហ៊ុនត្រូវដាក់ឱ្យស្របតាមច្បាប់ដែលមានជាធរមាន និងគោរពតាមចំណុចតម្រូវមួយចំនួន ។ ដោយក្នុងនោះច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥ បានចែងថា ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន នៅពេលដាក់ឈ្មោះក្រុមហ៊ុននៅពីក្រោយ ឬពីក្រោម ឈ្មោះក្រុមហ៊ុននោះត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត" ប្រសិនក្រុមហ៊ុននោះទទួលខុសត្រូវត្រឹមកម្រិតភាគទុនដែលបានដាក់។

### ៣.១.២. លក្ខណៈទម្រង់ និងការផ្សព្វផ្សាយជាសាធារណៈ

ក្រោយពីបំពេញលក្ខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុនមូលធនរួចរាល់ហើយ កិច្ចបន្ទាប់ក្រុមហ៊ុន ត្រូវរៀបចំលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនជាលក្ខណៈទម្រង់ និងធ្វើការផ្សព្វផ្សាយជាសាធារណៈស្ដីពីការបង្កើតក្រុមហ៊ុនដើម្បីឱ្យសាធារណៈជនបានដឹងឮ ចំពោះលក្ខណៈទម្រង់នេះផងដែរគឺជាលក្ខណៈមួយដែលធ្វើឡើងជាលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងដោយមានការព្រមព្រៀងពីសំណាក់សមាជិកភាគហ៊ុនដោយធ្វើឡើងជាលិខិតជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាលើលិខិតនោះគ្រប់ទំព័រ ដោយសមាជិកទាំងអស់ដើម្បីសម្រេចជាផ្លូវការ និងស្របតាមច្បាប់ជាធរមាន។

#### ៣.១.២.១. លក្ខន្តិកៈក្រុមហ៊ុន និងការតម្កល់

បន្ទាប់ពីបានគិតគូពីបញ្ហានានាក្នុងការបង្កើតក្រុមហ៊ុនរួចមកហើយ ភាគីទាំងអស់ត្រូវរៀបចំលក្ខន្តិកៈក្រុមហ៊ុនវិញម្ដង។ លក្ខន្តិកៈ របស់ក្រុមហ៊ុនត្រូវចែងអំពី៖

- នាមករណ៍ក្រុមហ៊ុន៖ នាមករណ៍ត្រូវសរសេរជាភាសាខ្មែរ ហើយត្រូវចាប់ផ្ដើមដោយនាមវត្ថុ ឬសត្វ ឬកន្លែង ឬនាមប្រឌិតផ្សេងៗ និងបញ្ចប់ដោយទម្រង់នៃក្រុមហ៊ុន។
- ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន៖ ទីស្នាក់ការក្រុមហ៊ុន។
- កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន៖ កម្មវត្ថុអាចមានមួយ ឬច្រើនដែលស្របទៅតាមបញ្ញត្តិច្បាប់។

[73] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១៤៤

- ដើមទុនៈ ប្រកាសជារូបិយវត្ថុជាតិ។
- ចំណាត់ភាគហ៊ុន ប្រភេទភាគហ៊ុន ព្រមទាំងចំណែកភាគហ៊ុន។
- អត្តសញ្ញាណ និងអាសយដ្ឋានរបស់ម្ចាស់ក្រុមហ៊ុន និងអ្នកគ្រប់គ្រងក្រុមហ៊ុន
- ចំនួនអ្នកដឹកនាំៈ អភិបាលក្រុមហ៊ុនក្រុមប្រឹក្សាភិបាល។[74]

ក្រៅពីនេះ គេក៏អាចដាក់នៅចំណុចផ្សេងៗទៀតដែលទាក់ទងដល់ដំណើរការក្រុមហ៊ុន ដូចជាៈ ការដកហូតដំណែងអភិបាល ការផ្ទេរសិទ្ធិ តួនាទី មុខងារ ភារកិច្ច។ល។ លើសពីនេះទៀត គេក៏អាចចែងអំពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុននៅក្នុងនោះផងដែរ។ ក្រុមហ៊ុនបានទទួលនីតិបុគ្គលិកលក្ខណៈ ពោលគឺទទួលបានសិទ្ធិ និងកាតព្វកិច្ច ដូចរូបវន្តបុគ្គលដែរចាប់ពីកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម។ វាខុសពីរូបវន្តបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងបាន ក្រុមហ៊ុនមិនអាចធ្វើសកម្មភាពដោយខ្លួនឯងបានឡើយ គឺក្រុមហ៊ុនត្រូវការភ្នាក់ងារ ឬ អ្នកតំណាងដែលជារូបវន្តបុគ្គលដើម្បីបំពេញសកម្មភាពទាំងអស់របស់ក្រុមហ៊ុន។ ដូច្នេះវាមានភាពចាំបាច់ដែលត្រូវមានលក្ខន្តិកៈដែលជាមាត្រដ្ឋាន ដើម្បីការពារផលប្រយោជន៍ក្រុមហ៊ុន ម្ចាស់ភាគហ៊ុន អភិបាល មន្ត្រី និង បុគ្គលិករបស់ក្រុមហ៊ុន និង ដើម្បីការពារសិទ្ធិ និងប្រយោជន៍របស់បុគ្គលពាក់ព័ន្ធផ្សេងទៀតផងដែរ។ ច្បាប់ស្តីពីសហគ្រាពាណិជ្ជកម្ម មាត្រា ១០៣ បានចែងថាក្រុមហ៊ុន មិនត្រូវប្រកបពាណិជ្ជកម្មណាមួយ ឬអនុវត្តសិទ្ធិណាមួយដែលលក្ខន្តិកៈរបស់ខ្លួនបានហាមឃាត់ ឬ មិនត្រូវអនុវត្តសិទ្ធិណាមួយ ដែលផ្ទុយពីលក្ខខន្តិកៈរបស់ខ្លួនឡើយ។ ការចុះហត្ថលេខាលើលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុនដើម្បីជាសក្ខីភាពមួយដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងការទទួលស្គាល់ដោយសមាជិកភាគហ៊ុនជាផ្លូវការ។

រាល់ទម្រង់ឯកសារ និងលិខិតទាំងអស់ដែលទាក់ទងនឹងការបង្កើតក្រុមហ៊ុនត្រូវយកទៅតម្កល់ទុកនៅនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ដោយស្ថាមនិកក្រុមហ៊ុននៅពេលដែលដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញលិខិតបញ្ជាក់មួយជាសម្គាល់ក្រោយពីបានទទួលយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោយពីបានទទួលសោហុយនៃការតម្កល់។

### ៣.១.២.២.លិខិតជាលាយលក្ខអក្សរ

លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមួយដែលបានតាក់តែងឡើង គឺជាកិច្ចសន្យាក្រុមហ៊ុនរបស់ក្រុមហ៊ុន លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះត្រូវបានចាត់ទុកជាឯកសារលាយលក្ខណ៍អក្សរដែលមាន

[74] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៩៣

ទម្រង់ជា លិខិតយថាភូត ដែលស្របទៅនឹងទ្រង់ទ្រាយរបស់ក្រុមហ៊ុន។ ចំពោះលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគឺមិនដូចគ្នានោះទេ ដោយលក្ខន្តិកៈ គឺជាឯកសារមូលដ្ឋានដែលត្រូវតម្កល់នៅក្រសួងពាណិជ្ជកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម។ បទបញ្ជាផ្ទៃក្នុង គឺជាវិធានដាក់កម្រិតដល់អាជីវកម្ម ឬកិច្ចការរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ខ្លួនមិនចាំបាច់មានបទបញ្ជាផ្ទៃក្នុងមួយដែលធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុននិងអភិបាលក្រុមហ៊ុន។[75]

**៣.១.២.៣. មហាសន្និបាតបង្កើតក្រុមហ៊ុន**

វាអាចដោយសារថា ស្ថាបនិកក្រុមហ៊ុនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការជាវភាគហ៊ុនទាំងអស់ដោយខ្លួនឯងបាន ហេតុនេះគេត្រូវអំពាវនាវឱ្យមានការចូលរួមជាសាធារណៈ ក្នុងការចុះឈ្មោះជាវភាគហ៊ុន និងសិទ្ធិចូលជាសមាជិកក្រុមហ៊ុន។ នៅពេលដែលចុះបញ្ជីឈ្មោះជាវភាគហ៊ុនអស់ហើយ មាហាសន្និបាតក្រុមហ៊ុនក៏ចាប់កើតមានឡើង។ មាហាសន្និបាតកើតឡើង ក្រុមហ៊ុនចាប់ផ្ដើម ដោយសារថាភាគហ៊ុនទាំងអស់ត្រូវបានជាវរួចអស់ ហើយប័ណ្ណភាគហ៊ុនទាំងអស់ត្រូវបានប្រគល់ជូនទៅតាមកម្រិតដែលបានទាមទារ។ ក្រោយពីក្រុមហ៊ុនបង្កើតឡើងជាស្ថាពររួច គេត្រូវផ្សព្វផ្សាយជាសាធារណៈ។[76]

**ក. អភិបាល**

អភិបាល គឺជាអ្នកដឹកនាំ និងជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនមូលធន ឬអាចនិយាយបានម្យ៉ាងទៀតបានថាជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនដែលមានភារកិច្ចក្នុងការគ្រប់គ្រងសកម្មភាព និងកំណត់ទិសដៅនានានៅក្នុងក្រុមហ៊ុន និងបំពេញតួនាទីក្នុងនាមជាក្រុមហ៊ុន។[77] រាល់សកម្មភាពគ្រប់គ្រងគឺត្រូវធ្វើឡើងជាប្រយោជន៍នៃក្រុមហ៊ុន។ ដូចនេះហើយ ទើបបានជាការជ្រើសរើសតែងតាំងអភិបាលត្រូវតែមានភាពយកចិត្តទុកដាក់ជាខ្លាំងដើម្បីឱ្យក្រុមហ៊ុនដំណើរការទៅដោយជោគជ័យ។

- **ការតែងតាំងអភិបាល**

អភិបាលត្រូវតែជារូបវន្តបុគ្គល[78] អាចជាម្ចាស់ហ៊ុន ឬជាអ្នកក្រៅដែលក្រុមហ៊ុនជួលឱ្យធ្វើការជំនួសម្ចាស់ហ៊ុន[79] ក្រុមហ៊ុនមូលធនអាចមានអភិបាល ១ (មួយ)នាក់ ឬលើសពីមួយនាក់[80] ចំពោះចំនួននេះវាអាច

---

[75] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១០២

[76] ឯកឧត្តមសាស្ត្រាចារ្យ កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥), ២៤៨

[77] អ៊ុង ជាហ្វា និង សុខដូរ, សៀវភៅសារណាបញ្ចប់ការសិក្សា ប្រធានបទស្ដីពី "*តួនាទីអភិបាលក្នុងក្រុមហ៊ុនមូលធន*" ឆ្នាំ ២០១៨, ៥

[78] កុយ នាម, *ច្បាប់ក្រុមហ៊ុន*, ឆ្នាំ ២០១៦, ៣៩៩

[79] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១២០

[80] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១១៨

ត្រូវបានប្រែប្រួលទៅតាមការរីកចម្រើននៃក្រុមហ៊ុន ហើយអភិបាលនេះផងដែរត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅប៉ុន្តែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលយ៉ាងតិច បីនាក់ឡើងទៅ ហើយអភិបាលត្រូវបានជ្រើសតាំងដោយមហាសន្និបាតបង្កើតក្រុមហ៊ុន ឬមហាសន្និបាតសាមញ្ញ។ អាណត្តិអភិបាលគឺមានរយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចត្រូវផ្លាស់ប្តូរបានក្នុងចំនួន ១/៣ នៃចំនួនសរុបជារៀងរាល់ឆ្នាំតាមរយៈមហាសន្និបាតនៃម្ចាស់ភាគហ៊ុន។ ក្នុងករណីដែលលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងមិនបានចែងអំពីអាណត្តិរបស់អភិបាលទេ។ អភិបាលម្នាក់ត្រូវមានអាណត្តិ ២ឆ្នាំ ហើយអាចនឹងត្រូវជ្រើសរើសឡើងវិញបាន ក៏ដូចជាដកហូតមុខងារទៅវិញបានដោយមហាសន្និបាតសាមញ្ញ ឬមហាសន្និបាតបង្កើតក្រុមហ៊ុន។ ប៉ុន្តែត្រូវចាំថា អាណត្តិរបស់អភិបាលទាំងឡាយមិនត្រូវបានបញ្ចប់ក្នុងឆ្នាំជាមួយគ្នាបានឡើយ។[81]

- **ការបោះឆ្នោតតែងតាំងអភិបាល**

អភិបាលត្រូវបានជ្រើសរើសដោយម្ចាស់ហ៊ុននៅក្នុងមហាសន្និបាតម្ចាស់ហ៊ុន។[82] សេចក្តីសម្រេចសាមញ្ញនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត សេចក្តីសម្រេចសាមញ្ញគឺជា សេចក្តីសម្រេចដែលមានសម្លេងឆ្នោតភាគច្រើនដាច់ខាតដែលបានចូលរួមក្នុងការបោះឆ្នោត។

## ៣.២. ការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីពាណិជ្ជកម្ម

នេះជាដំណាក់កាលទីពីរក្នុងការបង្កើតក្រុមហ៊ុនមួយ។ មិនខុសអ្វីពីក្រុមហ៊ុនសហកម្មសិទ្ធិទេ ដើម្បីឱ្យក្រុមហ៊ុនមានបុគ្គលភាពគតិយុត្តត្រឹមត្រូវ ច្បាប់តម្រូវឱ្យក្រុមហ៊ុនធ្វើការស្នើសុំអាជ្ញាប័ណ្ណ និងចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួនឱ្យបានត្រឹមត្រូវ។ នីតិវិធីនៃការស្នើសុំអាជ្ញាប័ណ្ណ និងការចុះបញ្ជីក្រុមហ៊ុន គឺមានភាពដូចគ្នាទៅក្រុមហ៊ុនសហកម្មសិទ្ធិដែរ ដោយត្រូវស្នើសុំអាជ្ញាប័ណ្ណពីក្រសួងដែលពាក់ព័ន្ធទៅនឹងអាជីវកម្មរបស់ក្រុមហ៊ុន ហើយអាចទទួលបានព័ត៌មានបានក្នុងគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ:www.service.gov.kh ឬក្នុងកម្មវិធីទូរស័ព្ទ ដែលមានឈ្មោះថា "ច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ" ដែលជាថ្នាលបច្ចេក-វិទ្យាព័ត៌មានមួយដែលបង្ហាញពីសេវាសាធារណៈទាំងអស់។ ចំណែកឯការចុះបញ្ជីក្រុមហ៊ុនវិញ គឺអាចចុះបានតាមរយៈប្រព័ន្ធ CamDX ឬ ហៅកាត់ថា Single Portal ហើយមាននីតិវិធីនៃការចុះបញ្ជីក៏ដូចគ្នាជាមួយនឹងក្រុមហ៊ុនសហកម្មសិទ្ធិដែរ ដែលគ្រាន់តែចូលទៅក្នុងគេហទំព័រនេះ "www.registrationservices.gov.kh" ហើយជ្រើសយកការចុះបញ្ជី បន្ទាប់មកបំពេញព័ត៌មាន និងឯកសារតម្រូវ ធ្វើការទូទាត់បង់កម្រៃ និងរង់ចាំការអនុម័តសម្រេចក្នុងរយៈពេល៨ថ្ងៃ។ ទោះជាយ៉ាងណាក្តី កម្រៃ និង ឯកសារតម្រូវក្នុងការចុះបញ្ជីពាណិជ្ជកម្ម គឺ

[81] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១២២

[82] ប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ, លេខ ០១១/១៨ គ.ម.ក./ប្រ.ក, ប្រការ១៣

មិនដូចគ្នាទេ។ កម្រៃក្នុងការចុះបញ្ជីនៃក្រសួងពាណិជ្ជកម្មគឺ ២.០២ លានរៀល ហើយឯកសារតម្រូវក្នុងការចុះបញ្ជីពាណិជ្ជកម្មមានដូចខាងក្រោម។

- គោត្តនាម និងនាមនៃសមាជិកក្រុមហ៊ុន អាស័យដ្ឋាន និងសញ្ជាតិ។
- ការប្រកាសដោយសុទ្ធិចិត្តរបស់អ្នកសុំចុះបញ្ជីថាគ្មានទោសក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ។
- ដើមទុនរបស់ក្រុមហ៊ុន ចំណែកភាគទុនរបស់សមាជិកម្នាក់ៗ ជាសាច់ប្រាក់ ឬវត្ថុដែលវាយតម្លៃជាទឹកប្រាក់។
- លិខិតបញ្ជាក់ពីប្រាក់ដើមទុនតម្កល់នៅធានាគារដែលចេញលិខិត។
- លក្ខន្តិកៈរបស់ក្រុមហ៊ុន។
- កម្មវត្ថុនៃក្រុមហ៊ុន។
- ផ្លាកសញ្ញាក្រុមហ៊ុន។
- អាសយដ្ឋាននៃក្រុមហ៊ុនដើម បើក្រុមហ៊ុនដែលសុំចុះបញ្ជីនេះជាសាខា ឬជាភ្នាក់ងាររបស់ក្រុមហ៊ុន។
- រយៈពេលនៃក្រុមហ៊ុន (អាយុរបស់ក្រុមហ៊ុន)។
- អត្តសញ្ញាណនៃអ្នកតំណាងពេញសិទ្ធិ ដែលរ៉ាប់រងក្នុងការចុះបញ្ជី។
- ក្នុងករណីចាំបាច់លិខិតអនុញ្ញាឱ្យប្រកបមុខរបរ ចំពោះមុខរបរណា ឬចំពោះកម្មវត្ថុ ពាណិជ្ជកម្មណាដែលតម្រូវឱ្យមានសេចក្ដីអនុញ្ញាត។[83]

## ៣.៣. ការរំលាយក្រុមហ៊ុនមូលធន

បុគ្គលគ្រប់រូបតែងតែមានការប្រែប្រួលនូវចិត្តគំនិត ការគិត ទៅតាមបរិបទ និងពេលវេលា ដែលគ្មាននរណាម្នាក់អាចហាមឃាត់បាន។ ដូចគ្នានឹងក្រុមហ៊ុនដែរ ក្រុមហ៊ុនត្រូវបានរំលាយដោយមូលហេតុមួយចំនួនដូចជាការមកដល់ពេលវេលា ការលំបាកដែលធ្វើឱ្យក្រុមហ៊ុនមិចអាចធ្វើអាជីវកម្មបាន ឬមានការខាតបង់ដែលក្រុមហ៊ុនមិនអាចគ្រប់គ្រងបាន មានការមិនចុះសម្រុងគ្នាជាដើមដែលជាមូលហេតុនាំឱ្យក្រុមហ៊ុនមានការរំលាយ។ ការរំលាយក្រុមហ៊ុនគឺជាដំណើការបញ្ចប់អត្ថិភាពនៃក្រុមហ៊ុន ដោយឆន្ទៈរបស់ម្ចាស់ហ៊ុន និងការរំលាយដោយអំណាចតុលាការ។

[83] ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ២៦ មិថុនា ១៩៩៥, មាត្រា ១៧ កថាខណ្ឌទី២

### ៣.៣.១. មូលហេតុនៃការរំលាយក្រុមហ៊ុន

ក្រុមហ៊ុនមូលធនត្រូវបានរំលាយដោយមូលហេតុមួយចំនួន ហើយការរំលាយនេះ គឺជាការបញ្ចប់អត្តភាពរបស់ក្រុមហ៊ុនក្នុងនាមជានីតិបុគ្គល។

- ការមកដល់នៃពេលវេលា
- ការបញ្ចប់កិច្ចការស្នូលរបស់ក្រុមហ៊ុន ឬម្យ៉ាងទៀតដោយសារអលទ្ធភាពក្នុងការបំពេញកិច្ចការស្នូលនោះ។
- ធនក្ស័យ
- ការមិនអនុវត្តនូវលក្ខន្តិកៈដែលបានកំណត់
- ការរំលាយដោយស្ម័គ្រចិត្តដោយមហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន
- រំលាយតាមរយៈផ្លូវតុលាការ។

### ៣.៣.២. ការរំលាយដោយស្ម័គ្រចិត្ត

អភិបាល ឬ ម្ចាស់ហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត។ ការរំលាយក្រុមហ៊ុន ដែលមានការសម្រេចជាឯកច្ឆ័ន្ទ ដោយមានការព្រមព្រៀងគ្នាពីសមាជិកទាំងអស់របស់ក្រុមហ៊ុន នឹងត្រូវបានច្បាប់ទទួលស្គាល់ នូវសុពលភាព ហើយវាគឺជាកត្តានៃការរំលាយក្រុមហ៊ុនផងដែរ ក្នុងករណីដែលមិនមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗ របស់ក្រុមហ៊ុន អាចទាមទារឱ្យរំលាយក្រុមហ៊ុនបាន។ វាកាន់តែបញ្ជាក់ឱ្យកាន់តែច្បាស់នូវចេតនារបស់ច្បាប់ សម្រាប់រំលាយក្រុមហ៊ុន ដោយបានគោរពទៅលើជំហរ និងការសម្រេចចិត្តរបស់សមាជិកហ៊ុន។ ប៉ុន្តែ វាមិនមែនមានន័យថាឱ្យតែមានការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ គឺគ្រប់គ្រាន់សម្រាប់ធ្វើការរំលាយក្រុមហ៊ុនឡើយ វាអាចមកពីកម្មវត្ថុជាដើម។

### ៣.៣.៣. រំលាយដោយតុលាការ

ច្បាប់ស្ដីពីសហគ្រាពាណិជ្ជកម្ម មិនបានចែងពីការរំលាយក្រុមហ៊ុនដោយតុលាការទេ។ ប៉ុន្តែក្រមរដ្ឋប្បវេណីបានចែងពីការរំលាយនីតិបុគ្គលដោយតុលាការ។ តុលាការអាចបញ្ជាឱ្យរំលាយក្រុមហ៊ុនមួយតាមរយៈបណ្ដឹងនៃម្ចាស់ភាគហ៊ុន អភិបាល ឬក្រសួងមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន ដោយផ្អែកទៅលើមូលហេតុ ក្រុមហ៊ុនបានជួបការលំបាកក្នុងកិច្ចការអាជីវកម្ម ដែលមានការខូចខាតមិនអាចស្ដារឡើងវិញបាន និងទំនាក់ទំនងមានការបែកបាក់ ការគ្រប់គ្រង ឬការចាត់ចែងទ្រព្យសម្បត្តិមិនត្រឹមត្រូវ ដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ក្រុមហ៊ុន។ ករណីដែលក្រុមហ៊ុនបង្កើតលក្ខន្តិកៈក្រុមហ៊ុនដោយការបោកបន្លំ ដោយមានបណ្ដឹងពី

ម្ចាស់ភាគហ៊ុន ក៏ដូចជាម្ចាស់បំណុល។ មួយវិញទៀតគឺមកពីការក្ស័យធន ការក្ស័យធននេះគឺសំដៅដល់ស្ថានភាពរបស់ពាណិជ្ជករ ឬនីតិបុគ្គលមិនមានលទ្ធភាពទូទាត់បំណុលបានហើយត្រូវបានប្រកាសដោយតុលាការ។

### ៣.៣.៤.ការជម្រះបញ្ជី

ការជម្រះបញ្ជីក្រុមហ៊ុន គឺជានីតិវិធីចុងក្រោយនៃការទូទាត់ក្នុងការរំលាយក្រុមហ៊ុន ហើយនៅពេលដែលក្រុមហ៊ុនធ្វើការរំលាយ សិទ្ធិក្នុងការកាន់កាប់ ប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី។ ក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិ និង/ឬ បំណុលអាចរំលាយបានតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុន នៃប្រភេទនីមួយៗ ក្នុងករណីក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ត្រូវជម្រះបញ្ជី និងរំលាយតាមតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុនប្រភេទនីមួយៗ ដោយមិនគិតថាម្ចាស់ហ៊ុននោះមានសិទ្ធិឬគ្មានសិទ្ធិក្នុងការបោះឆ្នោតទេប្រសិនបើ៖

- ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលបែងចែកទ្រព្យសម្បត្តិ និង ទូទាត់បំណុលរបស់ក្រុមហ៊ុន តាមសេចក្តីសម្រេចពិសេស ឬសេចក្តីសម្រេចសាមញ្ញ។
- ក្រុមហ៊ុនបានបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈ នៃការរំលាយក្រុមហ៊ុន ទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។
- ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់ចំនួន ឬការបញ្ឈប់សកម្មភាពទាំងស្រុងរបស់ក្រុមហ៊ុន នោះក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិនិងសិទ្ធិទៅឱ្យម្ចាស់ហ៊ុន។

## ៣.៤. គុណសម្បត្តិ និងគុណវិបត្តិនៃការបង្កើតក្រុមហ៊ុនមូលធន

ដោយសារតែប្រភេទក្រុមហ៊ុននៅក្នុងក្រុមហ៊ុនមូលធនមានភាពស្រដៀងគ្នាច្រើន (ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងមហាជនទទួលខុសត្រូវមានកម្រិត) នោះយើងខ្ញុំសូមបែងចែកចំណុចនៃគុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោម៖

### ៣.៤.១. គុណសម្បត្តិ

- ការលក់មូលបត្រ៖ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចបោះមូលបត្រលក់ជាសាធារណៈបាន។
- ការកម្រិតម្ចាស់ហ៊ុនចូលរួម៖ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមិនមានការកំណត់ចំនួនម្ចាស់ហ៊ុនអតិបរមាទេ។

- អាយុកាលរបស់ក្រុមហ៊ុន៖ ក្រុមហ៊ុនមូលធនអាចដំណើរការបានជានិរន្តរ៍ ដោយគ្មានពេលកំណត់ លើកលែងតែត្រូវរំលាយក្នុងករណីក្ស័យធន ឬក្នុងករណីផ្សេងទៀត ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។
- ការទទួលខុសត្រូវលើបំណុល៖ ម្ចាស់ហ៊ុននៃក្រុមហ៊ុនមូលធន ត្រូវទទួលខុសត្រូវលើបំណុលត្រឹមកម្រិតនៃចំណែកដើមទុន ដែលបានចូលហ៊ុនប៉ុណ្ណោះ។ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ត្រូវចែកដាច់ពីទ្រព្យសម្បត្តិបុគ្គលរបស់ម្ចាស់ហ៊ុន។
- ភាពងាយស្រួលក្នុងការបង្កើតក្រុមហ៊ុន៖ ក្រុមហ៊ុនមូលធនជាប្រភេទក្រុមហ៊ុន ដែលអាចផ្តល់ភាពងាយស្រួលក្នុងការបង្កើតអាជីវកម្មក្នុងទ្រង់ទ្រាយធំ ហើយងាយស្រួលក្នុងការស្វែងរកទុនបន្ថែម ដើម្បីពង្រីកអាជីវកម្ម។
- ការដាក់ដើមទុន៖ នៅក្នុងក្រុមហ៊ុនមូលធន អ្នកអាចបោះទុនវិនិយោគ និងការដកទុនចេញមកវិញបានយ៉ាងងាយស្រួល។

### ៣.៤.២. គុណវិបត្តិ

- ការលក់មូលបត្រ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនអាចមូលបត្រលក់ជាសាធារណៈបានទេ។
- ការកម្រិតម្ចាស់ហ៊ុនចូលរួម៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចមានម្ចាស់ហ៊ុនជាអតិបរមាត្រឹម ៣០នាក់។
- ដើមទុន៖ ក្រុមហ៊ុនមូលធនត្រូវការយ៉ាងតិច ៤លានរៀលទើបអាចបង្កើតបាន។
- ឯកសារច្បាប់៖ ត្រូវតម្រូវឱ្យមានសំណុំឯកសារច្បាប់ច្រើនត្រូវបំពេញ នេះព្រោះថានៅពេលបង្កើតក្រុមហ៊ុន ច្បាប់តម្រូវឲ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនព្រម ទាំងត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង និងនីតិវិធីក្នុងការចេញសេចក្តីសម្រេចច្បាស់លាស់។ ការរៀបចំសំណុំឯកសារច្បាប់ទាំងនេះពេលខ្លះចាំបាច់ត្រូវការរកមេធាវី ឬអ្នកជំនាញឲ្យជួយ ដែលត្រូវចំណាយពេលវេលា និងចំណាយលុយច្រើន។
- ការកំណត់កាតព្វកិច្ច៖ មិនថានៅមុនពេលបង្កើតទេ ទោះនៅក្នុងដំណើរការក្រុមហ៊ុនហើយក៏ដោយ ក៏ច្បាប់តម្រូវឲ្យមានកាតព្វកិច្ចច្រើនចំពោះក្រុមហ៊ុននេះផងដែរ ដូចជា ត្រូវមានមហាសន្និបាតម្ចាស់ហ៊ុនជារៀងរាល់ឆ្នាំ ហើយក្នុងមហាសន្និបាតនេះ ក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវមានរបាយការណ៍សវនករ ដើម្បីបង្ហាញម្ចាស់ហ៊ុន។

សរុបជាមកវិញមិនថាអ្វីក៏ដោយគឺតែងតែមាន គុណសម្បត្តិ និងគុណវិបត្តិមកជាមួយគ្នាតែគ្រាន់តែថាវាធំ ឬតូច តិច ឬច្រើនតែប៉ុណ្ណោះ ដូចគ្នានឹងប្រធានបទដែលនិយាយអំពី ការបង្កើតក្រុមហ៊ុន វាក៏មានគុណសម្បត្តិ និងគុណវិបត្តិរបស់វាដែរ។ បើយើងក្រលែកមើលស្ថានភាពបច្ចុប្បន្នវិញយើងឃើញថា គុណសម្បត្តិនៃការបង្កើតក្រុមហ៊ុនវាអាចជួយទៅដល់ ការកើនឡើងនូវចំណូលជាតិ ដោយសារ ការបង់ពន្ធដារ និងពន្ធគយដែលធ្វើឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន។ បើចំពោះវិស័យការងារវិញ គឺថាបង្កើតការងារដល់ប្រជាពលរដ្ឋដែលមានជំនាញ និងមានជំនាញសម្បូរ្ណមដែលរដ្ឋទទួលយកបានករណីក្រុមហ៊ុននោះបានចុះបញ្ជីត្រឹមត្រូវទៅតាមច្បាប់កំណត់។ ប្រសិនបើយើងក្រឡេងមើលផ្នែកអវិជ្ជមាននៃការបង្កើតក្រុមហ៊ុនវិញ វាអាចមានការបំពានទៅលើសិទ្ធិនៃការប្រកួតប្រជែងគ្នា ពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ដែលជាវិស័យប្រហាក់ប្រហែលគ្នា (ទម្លាក់តម្លៃ បន្ថយ បន្ថែមគុណភាពលើសពីកម្រិតមួយដែលក្រុមហ៊ុនប្រកួតប្រជែងផ្សេងទៀតមិនអាចធ្វើបាន) និងមានការកាត់បន្ថយបុគ្គលិកនៅពេលក្រុមហ៊ុនជួបវិបត្តិ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវរួចមក យើងបានសង្កេតឃើញថា ការបង្កើតក្រុមហ៊ុននៅកម្ពុជា គឺចាប់ផ្តើមតាំងពីយូរមកហើយ រហូតមកដល់ពេលបច្ចុប្បន្ន ទម្រង់ក្រុមហ៊ុនពាណិជ្ជកម្មត្រូវបានគេបែងចែកជាពីរធំៗ គឺ ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន។ ដោយក្នុងនោះ ក្រុមហ៊ុនសហកម្មសិទ្ធិ មានក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ចំណែកឯក្រុមហ៊ុនមូលធនវិញក៏ត្រូវបានចែងចែកជាពីរទៅទៀត គឺក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ទោះបីជាបែបនេះក្តី នីតិវិធីនៃការបង្កើតគឺ ឈរលើគោលការណ៍មិនខុសគ្នាទេ។ ពោលគឺ គេត្រូវមានការគិតគូក្នុងការបង្កើតក្រុមហ៊ុនអ្វីមួយ បន្ទាប់ពីបានការព្រមព្រៀងគ្នាតាមរយៈកិច្ចសន្យាក្រុមហ៊ុនរួចហើយគេនឹងតាក់តែងលក្ខន្តិកៈ ក្រុមហ៊ុនមួយដែលត្រឹមត្រូវតាមបទបញ្ញត្តិច្បាប់ និងធ្វើការស្នើសុំអាជ្ញាប័ណ្ណពីក្រសួងដែលពាក់ព័ន្ធនឹងអាជីវកម្មក្រុមហ៊ុននោះ និងបន្តដល់ការចុះបញ្ជីអាជីវកម្មដើម្បីឱ្យក្រុមហ៊ុនមានបុគ្គលភាពគតិយុត្តត្រឹមត្រូវ និង ស្របតាមការកំណត់របស់ច្បាប់។ យើងក៏ត្រូវស្គាល់ច្បាស់ពីទម្រង់នៃក្រុមហ៊ុននីមួយៗឱ្យបានច្បាស់ផងដែរមុននឹងសម្រេចចិត្ត។ សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺមានលក្ខខណ្ឌជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬក៏ជាកិច្ចសន្យាផ្ទាល់មាត់។ ក្រុមហ៊ុនត្រូវមាន ម្ចាស់ភាគហ៊ុនចាប់ពី២នាក់ឡើង ហើយភាគទុនអាចជា សាច់លុយ, ទ្រព្យសម្បត្តិ, ឬក៏ជាចំណេះដឹងក៏បាន ហើយមិនទាមទារដើមទុនច្រើនក្នុងការបង្កើតដែរ។ ក៏ប៉ុន្តែ ចំពោះការទទួលខុសត្រូវលើបំណុលវិញ គឺជាការទទួលខុសត្រូវដោយគ្មានកម្រិត។ ក្រុមហ៊ុនប្រភេទនេះមិនតម្រូវឱ្យមានឯកសារច្បាប់អ្វីដែលស្មុគស្មាញច្រើនទេ។ ចំណែកឯក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ គឺត្រូវមានម្ចាស់ហ៊ុនពីរប្រភេទ ដែលតាមច្បាប់ហៅថា "សហកម្មសិទ្ធិករទូទៅ" ដែលជាអ្នកដាក់ទុន,អ្នកចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ហើយមានការទទួលខុសត្រូវគ្មានកម្រិត និងមួយប្រភេទទៀតគឺជា "សហកម្មសិទ្ធិករមានកម្រិត" ដែលជាអ្នកដាក់ទុន តែមិនមានសិទ្ធិចាត់ចែងកិច្ចការក្រុមហ៊ុនទេ ហើយមានការទទួលខុសត្រូវលើបំណុលដោយគ្មានកម្រិត។ ចំពោះ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញ គឺមិនសូវមានភាពខុសគ្នាប៉ុន្មានទេ។ ការទទួលខុសត្រូវលើបំណុលសម្រាប់ក្រុមហ៊ុនទាំងពីរនេះគឺជាការទទួលខុសត្រូវគ្មានកម្រិត។ មួយវិញទៀត ដោយសារតែក្រុមហ៊ុននេះមានទ្រង់ទ្រាយធំ ដូច្នេះហើយក៏តម្រូវឱ្យមានការសិក្សាឱ្យបានល្អិតល្អន់ជាពិសេសចំពោះបញ្ហាផ្នែកច្បាប់ ដោយហេតុថាតម្រូវឱ្យមានឯកសារច្បាប់ជាច្រើននិងស្មុគស្មាញផងដែរ។ នៅមានចំណុចខ្លះដែលខុសគ្នាដែរ គឺត្រង់ថាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចមានម្ចាស់ហ៊ុនយ៉ាងច្រើនបំផុតត្រឹម ៣០នាក់ និង មិនអាចបោះ

មូលបត្រលក់ជាសាធារណៈបានទេ។ ចំណែកក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញ មិនមានការកំណត់ចំនួនម្ចាស់ហ៊ុនអតិបរមានោះទេ តែអាចបោះមូលបត្រលក់ជាសាធារណៈបាន។ ទោះបីយ៉ាងណាទម្រង់នីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិផ្សេងៗគ្នា។

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ ស្តីពី " ការបង្កើតក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា " យើងសូមផ្តល់ជាអនុសាសន៍ក្នុងន័យកែលម្អ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍក្នុងវិស័យពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាបឋមយើងខ្ញុំ សូមឱ្យក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធដ៏ទៃទៀតមានវិធានការយ៉ាងតឹងរឹងចំពោះក្រុមហ៊ុនដែលមិនចុះបញ្ជីស្របតាមវិធានគតិយុត្តដែលមានចែង។

យើងក៏សូមសំណូមពរទៅដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលបានបង្កើតមុខរបបរកស៊ីសូមធ្វើការចុះបញ្ជីឱ្យបានត្រឹមត្រូវដើម្បីជាប្រយោជន៍រួម ក៏ដូចជាផលប្រយោជន៍ផ្ទាល់ខ្លួន ផ្តល់នូវភាពប្រាកដប្រជា និងការការពារដោយច្បាប់ នៅក្នុងអំឡុងពេលប្រតិបត្តិការសកម្មភាពអាជីវកម្ម ក្រុមហ៊ុនមានសិទ្ធិអាចកាន់កាប់នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន ធ្វើការប្រតិបត្តិការសកម្មភាពអាជីវកម្ម និងប្តឹងទាមទារសំណងក្នុងនាមក្រុមហ៊ុនដោយខ្លួនឯងបាន។ មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុនក៏មានលទ្ធភាពអាចបង្កើត និងទទួលបាននូវកេរ្តិ៍ឈ្មោះ និងជំនឿទុកចិត្តពីអ្នកប្រើប្រាស់ អតិថិជន និងដៃគូសហការដទៃទៀត។ ផ្ទុយទៅវិញសម្រាប់ការខកខានមិនបានចុះបញ្ជីក្រុមហ៊ុនម្ចាស់អាជីវកម្មអាចត្រូវបានសន្មតថាកំពុងតែធ្វើអាជីវកម្មខុសច្បាប់ ឬសកម្មភាពអាជីកម្មដែលមិនទទួលស្គាល់ដោយច្បាប់។ ជាផលវិបាក ម្ចាស់អាជីវកម្មត្រូវបញ្ឈប់សកម្មភាពអាជីវកម្មរបស់ខ្លួនជាបន្ទាន់ ហើយ/ឬ នឹងប្រឈមនិងការពិន័យ ដោយអនុលោមតាម មាត្រា ៤០ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ មិនត្រឹមតែប៉ុណ្ណោះ ម្ចាស់អាជីវកម្មអាចប្រឈមមុខទៅនឹងការប្តឹង ឬការដាក់វិធានការវិន័យចំពោះសកម្មភាពអាជីវកម្មខុសច្បាប់ ដែលការទទួលខុសត្រូវនេះអាចនាំឱ្យមានការបាត់បង់នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់អាជីវកម្ម។

ជាចុងក្រោយយើងខ្ញុំមានតែធ្វើការលើកទឹកចិត្តឱ្យមានការបង្កើតក្រុមហ៊ុនឱ្យបានកាន់តែច្រើន ហើយក៏ស្នើសុំទៅដល់ក្រសួងពាក់ព័ន្ធ ក៏ដូចជាម្ចាស់ក្រុមហ៊ុនដែលបានបង្កើតក្រុមហ៊ុនរួចហើយតែមិនទាន់ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម សូមរួសរាន់ធ្វើការបំពេញនូវកាតព្វកិច្ចដែលខ្លួនត្រូវធ្វើនោះឱ្យបានល្អ។ យ៉ាងណាមិញ យើងខ្ញុំពិតជាមានសេចក្តីរីករាយជាក្រៃលែង ដែលនាពេលបច្ចុប្បន្ននេះ ការចុះបញ្ជីមានភាពងាយស្រួលជាងមុនដោយរាជរដ្ឋាភិបាលសហការជាមួយក្រសួងពាក់ព័ន្ធនានាជាពិសេសក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារជាដើម បានបង្កើតថ្នាលបច្ចេកវិទ្យាមួយដែលអាចឱ្យក្រុមហ៊ុនចុះបញ្ជីបានដោយងាយស្រួល និងចំណាយពេលតិច និងមិនមានភាពស្មុគស្មាញដូចមុន។ តទៅមុខទៀតយើងខ្ញុំសង្ឃឹមថា ការស្នើសុំអាជ្ញាប័ណ្ណនៅតាមក្រសួងនានាក៏អាចធ្វើការស្នើតាមប្រព័ន្ធបច្ចេកវិទ្យាតែមួយផងដែរ ដើម្បីឱ្យមានភាពងាយស្រួលដល់ក្រុមហ៊ុននិងអាជីវកម្មទាំងឡាយដែលមានកាព្វកិច្ចក្នុងការស្នើសុំនោះ។

# ឯកសារយោង


## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧។

២. ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤, ២៦ មិថុនា ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

៣. ព្រះរាជក្រមលេខ ស/រកម/១១៩៩/១២, ១៨ សីហា ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

៤. ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥។

៥. ច្បាប់ក្ស័យធន, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ឆ្នាំ២០០៧។

៦. ប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស,លេខ០០៩ សហវ.ប្រក,១២ មករា ២០២១។

៧. ប្រកាសស្តីពី បែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូ និងកែប្រែរបស់សហគ្រាស និងក្រុមហ៊ុន, លេខ១៤២ ព.ណ.ចបព.ប្រក, ០៣ មិថុនា ២០១៥។

៨. ប្រកាសស្តីពី ការចុះឈ្មោះនៅក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម, លេខ ២១៤ ព.ណ.ចបព.ប្រក, ២៤ មិថុនា ២០១៦។

៩. ប្រកាសស្តីពី វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់, លេខ ១៩៣ សហវ. ប្រក, ២៦ មិនា ២០២១។

១០. ប្រកាសស្តីពីការដាក់ពាក្យសុំសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន, លេខ ១៣៧។

១១. ប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ,លេខ ០១១/១៨ គ.ម.ក./ប្រ.ក, ១៩ ធ្នូ ២០១៨។

១២. អនុក្រឹត្យស្តីពី ការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, លេខ ៨៤ អនក្រ. បក ចុះថ្ងៃទី ១០ មិថុនា ឆ្នាំ ២០២០។

## ខ.សៀវភៅ និងឯកសារផ្សេងៗ

១. កុយ នាម ច្បាប់ក្រុមហ៊ុន,២០១៦, ច្បាប់ក្រុមហ៊ុន, ភ្នំពេញ។

២. ឯកឧត្តម កៅ មុយថង,២០១៥, *ច្បាប់ពាណិជ្ជកម្ម*, ភ្នំពេញៈ បណ្ណាគារអង្គរ។

៣.គង់ សាផន, *នីតិពាណិជ្ជកម្ម*, ២០១២, ភ្នំពេញៈ អ៊ីម៉េក ព្រីនធីង។

៤. មេធាវី អ៊ីវ ប៉ូលី, ២០១១, *កិច្ចសន្យា*, សាកលវិទ្យាល័យ បញ្ញាសាស្ត្រ។

៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០២០, *សៀវភៅដំណើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,* ភ្នំពេញ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤. ក្រសួងពាណិជ្ជកម្ម, *សៀវភៅណែនាំស្តីពីការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់,* ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម។

៥. ក្រសួងពាណិជ្ជកម្ម, *សៀវភៅ ស្តីអំពីក្រុមហ៊ុមហាជន ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសហកម្មសិទ្ធិ,* ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម។

## គ.គេហទំព័រ

១. ក្រសួងពាណិជ្ជកម្ម, គេហទំព័រចុះបញ្ជីពាណិជ្ជកម្ម, https://www.businessregistration.moc.gov.kh/ (ចូលទស្សនាថ្ងៃទី ៣០ កក្កដា ២០២១)។

២. IP LAW In CAMBODIA, *នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម,* http://iplawseihaincambodia.blogspot.com/2014/05/blog-post.html?m=1 (ចូលទស្សនាថ្ងៃទី ៥ មិថុនា ២០២១)។

៣. LOCAWIZE, *ដំណើរការនៃការចុះបញ្ជីក្រុមហ៊ុន* https://locawize.com/km/company-registration-km/company-registration-process/ (ចូលទស្សនាថ្ងៃទី ៥ មិថុនា ២០២១)។

៤. ព្រឹត្តិប័ត្រច្បាប់កម្ពុជា, *លក្ខន្តិកៈក្រុមហ៊ុន,* http://khmerlawjournal-kh.blogspot.com/2014/10/blog-post.html?m=1 (ចូលទស្សនាថ្ងៃទី ៣០ មិថុនា ២០២១)។

៦. ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, *កិច្ចសន្យាក្រុមហ៊ុន,* https://ciclg.com/kh/article/185 (ចូលទស្សនាថ្ងៃទី ៥ ឧសភា ២០២១)

៧. Anna & Associates Law office, *ការចុះបញ្ជីក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម,* http://www.anna-associates.com/blog/1621479177373
(ចូលទស្សនាថ្ងៃ ទី៥ ឧសភា ២០២១)។

៨. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, គេហទំព័រចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, www.registrationservices.gov.kh. (ចូលទស្សនាថ្ងៃទី ៥ កក្កដា ២០២១)។

៩. RFI, *គុណសម្បត្តិនិងគុណវិបត្តនៃការបង្កើតក្រុមហ៊ុន,* https://www.rfi.fr/km/different-types-of-companies-in-cambodian-law (ចូលទស្សនាថ្ងៃទី ២០ កក្កដា ២០២១)។

១០. ក្រសួងមុខងារសាធារណៈ, ព័ត៌មានអំពី អាជ្ញាប័ណ្ណ, http://www.service.gov.kh/category/174 (ចូលទស្សនាថ្ងៃទី ៥ កក្កដា២០២១) ។

១១. មេធាវី អ៊ុំ ប៉ូលី, *នីតិក្រុមហ៊ុន*, (ភ្នំពេញ៖ សមាគមន៍ច្បាប់ខ្មែរ ២០០៨), អាចរកបាននៅ https://drive.google.com/file/d/0B7OmNithn8yCY0d0cnowMU96am8/view?resourcekey=0-XZB3T2S-g8_5ugAx7SL-yg (ថតចម្លងថ្ងៃទី ៣០ កក្កដា ២០២១)។

## ឃ.សារណាបញ្ចប់ការសិក្សា

១. កែវចាន់ណាលីន និង វងចាំ លីស៊ាង,សៀវភៅសារណាបញ្ចប់ការសិក្សា ប្រធានបទស្តីពី "កិច្ចសន្យាក្រុមហ៊ុន" ឆ្នាំ២០១៩។

២. អ៊ុង ជាហ្វា និង សុខដួរ, សៀវភៅសារណាបញ្ចប់ការសិក្សា ប្រធានបទស្តីពី "តួនាទីអភិបាលក្នុងក្រុមហ៊ុនមូលធន" ឆ្នាំ ២០១៨។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
DEPARTMENT OF BUSINESS REGISTRATION

# ច្បាប់

ស្តីពី

## វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

(២៦-០៦-១៩៩៥)

និង

# ច្បាប់

## វិសោធនកម្មមាត្រា

១០, ១១, ១៤, ១៦, ១៧, ២១, ២៤, ២៥, ២៦, ២៨, ២៩, ៣០, ៣១, ៣២, ៣៣, ៣៤, ៣៥, ៣៦, ៣៧, ៣៨, ៤០, ៤២, ៤៤ ក្នុងជំពូកទី២ មាត្រា៥៤, ៥៧, ៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩, ៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពី "វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម"

(១៨-១១-១៩៩៩)

# LAW

ON

## COMMERCIAL RULES AND REGISTER

(26/06/1995)

*AND*

# LAW

ON

## THE AMENDMENTS OF ARTICLES

10, 11, 14, 16, 17, 21, 24, 25, 26, 28, 29, 30, 31, 32, 33, 34, 35, 36, 37, 38, 40, 42, AND 44 OF CHAPTER II, ARTICLES 54, 57 AND 58 OF CHAPTER IV AND ARTICLES 59 AND 60 OF CHAPTER V OF THE LAW ON " COMMERCIAL RULES AND REGISTER "

(18/11/1999)

Scanned by CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រម

នស/រកម/០៦៩៥/០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រម

នស/រកម/១១៩៩/១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មិនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១. ១២. ១៣. ១៨. ២២. ២៤. ២៦. ២៨. ៣០. ៣៤. ៥១. ៩០. ៩៣. និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា

ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រី និង អំពី រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម

# ប្រកាសអោយប្រើ

ច្បាប់ស្ដីពីវិសោធនកម្ម មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និង ដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម ទំរង់ និង គតិ នៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

ស្តីពី

## វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

(២៦.០៦.១៩៩៥)

និង

# ច្បាប់

ស្តីពី

## វិសោធនកម្មមាត្រា

១០, ១១, ១៤, ១៦, ១៧, ២១, ២២, ២៥, ២៦, ២៨, ២៩, ៣០, ៣១, ៣២, ៣៣, ៣៤, ៣៥, ៣៦, ៣៧, ៣៨, ៤០, ៤២, ៤៤ ក្នុងជំពូកទី២ មាត្រា៥៤, ៥៧, ៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩, ៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពី "វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម"

(១៨.១១.១៩៩៧)

# ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ :

ពាណិជ្ជករ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបរខ្លួនជាប្រចាំ ។

ពាណិជ្ជកិច្ច ជាសកម្មភាពទិញ លក់ទំនិញ ឬ សេវាដែលត្រូវបានអនុវត្តជាប្រចាំ ក្នុងគោលដៅធ្វើការដោះដូរ និង ស្វែងរកចំណេញ ។

មាត្រា ២ :

ច្បាប់នេះចាត់ទុកថាជាពាណិជ្ជកិច្ច រាល់សកម្មភាពដែលមានចែងជាអាទិ៍ដូចខាងក្រោម:

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងក្នុងវិស័យអចលនទ្រព្យ ។
- រាល់សកម្មភាពនៃ សហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកំរៃជើងសារ សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និងសេវាដ៏ទៃទៀត ។
- ប្រតិបត្តិការនៃធនាគារប្តូររូបិយវត្ថុ ។
- ការផ្តល់សេវាអន្តរការ សេវាទីភ្នាក់ងារ ការិយាល័យសំរបសំរួលកិច្ចការ សេវាវប្បធម៌ និង ការចាត់ចែងទូវទស្សនីយភាពជាសាធារណៈ ។
- ប្រតិបត្តិការនៃ សហគ្រាសសំណង់ ការទិញ ឬការលក់នាវាដឹកជញ្ជូនក្នុងប្រទេស ឬ ក្រៅប្រទេស ការដឹកជញ្ជូន និង ការផ្ញើបញ្ជូនតាមផ្លូវគោក ផ្លូវទឹក ឬ ផ្លូវអាកាស ។
- ការធានារ៉ាប់រងគ្រប់ប្រភេទ ។
- អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើ និង រ៉ែ ។

## មាត្រា ៣ :

ច្បាប់នេះមិនចាត់ទុកថាជាពាណិជ្ជកិច្ចទេ រាល់សកម្មភាពដែលមានចែងជាអាទិ៍ដូចខាងក្រោម :

- ការផលិតដែលមិនមែនសំរាប់លក់ទៅវិញ
- ការផលិត ឬ សេវាទាំងឡាយ ដែលមានលក្ខណៈជាគ្រួសារ
- ការផលិតសិល្បៈសុទ្ធសាធ
- ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន ឬ ដោយសមាគមស្របច្បាប់ ។

## មាត្រា ៤ :

មិនចាត់ទុកថាជាពាណិជ្ជករទេ ផលិតករ សិប្បករ ឬ កសិករទាំងឡាយដែលធ្វើសកម្មភាពមានលក្ខណៈជាគ្រួសារ ។

## មាត្រា ៥ :

បុគ្គលដែលគ្រាន់តែជួយលក់ទំនិញរបស់សហព័ទ្ធខ្លួនដែលជាពាណិជ្ជករ មិនចាត់ទុកថា ជាពាណិជ្ជករឡើយ ។

និយោជិកដែលលក់តែទំនិញរបស់ម្ចាស់សហគ្រាសខ្លួនដែលជាពាណិជ្ជករ មិនចាត់ទុកថា ជាពាណិជ្ជករឡើយ ។

## មាត្រា ៦ :

សហព័ទ្ធនៃពាណិជ្ជករ ត្រូវចាត់ទុកថាជាពាណិជ្ជករដែរ បើសហព័ទ្ធនោះប្រកបរបរពាណិជ្ជកម្ម ដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្មដោយឡែក ។

ការយល់ព្រមពីសហព័ទ្ធ ត្រូវមានការចាំបាច់សំរាប់ពាណិជ្ជករនោះ ។

មាត្រា ៧ :

តាមន័យនៃច្បាប់នេះ អនីតិជនមិនអាចជាពាណិជ្ជករបានទេ លើកលែងតែអនីតិជននោះ រួចផុតពីអាណាព្យាបាល ។

មាត្រា ៨ :

សិទ្ធិ និង កាតព្វកិច្ចរបស់ពាណិជ្ជករ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់ពាណិជ្ជកម្ម លើកលែងតែមានភស្តុតាងផ្ទុយ ។

មាត្រា ៩ :

សមត្ថភាពប្រកបកិច្ចការពាណិជ្ជកម្ម អាចត្រូវបានចាត់ទុកជាបាត់បង់ ដោយមូលហេតុដូចតទៅ ៖

- ធនក្ស័យ
- សេចក្តីសំរេចរបស់តុលាការហាមឃាត់ការប្រកបកិច្ចការពាណិជ្ជកម្ម
- វិសមិត្តភាពក្នុងការងារពាណិជ្ជកម្ម និង ការងារសាធារណៈ ។

# ជំពូកទី ២

## ផ្នែកទី ១

## បញ្ជីពាណិជ្ជកម្ម និង ក្រុមហ៊ុន ការកាន់កាប់ និង កម្មវត្ថុនៃបញ្ជី

មាត្រា ១០.– ថ្មី

ការគ្រប់គ្រង និង កាន់កាប់ នូវបញ្ជីមួយចុះអត្តលេខនៃពាណិជ្ជករ និង ក្រុមហ៊ុនពាណិជ្ជកម្មដែលហៅថា "បញ្ជីពាណិជ្ជកម្ម" ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

មាត្រា ១១.– ថ្មី

ក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជូនច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និង រាល់ឯកសារដែលពាក់ព័ន្ធដល់ការចុះបញ្ជីពាណិជ្ជកម្មរើមមួយច្បាប់ ជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតម្កល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម ។

មាត្រា ១២ :

ពាណិជ្ជករ និង ក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួន សាខាបុត្រសម្ព័ន្ធ ឬ ទីភ្នាក់ងាររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីនេះ លើកលែងតែពាណិជ្ជករដែលមិនជាប់ពន្ធលើប្រាក់ចំណេញ ។

មាត្រា ១៣ :

ត្រូវកត់ចូលក្នុងបញ្ជីនេះ នូវនិទ្ទេសទាំងអស់ដែលទាក់ទងដល់ពាណិជ្ជករ និង ក្រុមហ៊ុន ដែលធ្វើពាណិជ្ជកិច្ច ។

## ផ្នែកទី ២

## ពាណិជ្ជករដែលមានគ្រឹះស្ថានដើមនៅកម្ពុជា

មាត្រា ១៤.– ថ្មី

យ៉ាងតិចបំផុតដប់ប្រាំថ្ងៃ ( ១៥ថ្ងៃ ) មុនពេលចាប់ផ្តើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នាកន្លែងដែលខ្លួនធ្វើអាជីវកម្ម។

ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម មាននៅតាមមន្ទីរពាណិជ្ជកម្ម ខេត្ត ក្រុង ឬ នៅទីកន្លែងផ្សេងទៀត តាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម ។

ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍

មួយធ្វើជាពីរច្បាប់ មានចុះហត្ថលេខា ឬ ស្នាមមេដៃរបស់សាមីខ្លួន ។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មបានផ្តល់អោយ ។ ប្រតិវេទន៍ត្រូវចែងអំពី ៖

១. នាមត្រកូល និង នាមខ្លួន របស់ពាណិជ្ជករ និង លេខ នៃលិខិតអត្តសញ្ញាណរបស់ខ្លួន ។

២. នាមប្រើប្រាស់ក្នុងពាណិជ្ជកម្ម ឬ រហស្សនាម ។

៣. ថ្ងៃ.ខែ.ឆ្នាំ និង ទីកន្លែងកំណើត ព្រមទាំងអាស័យដ្ឋានផ្ទាល់ខ្លួន ។

៤. សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀតត្រូវបញ្ជាក់អំពីបែបបទ និងថ្ងៃ.ខែ.ឆ្នាំដែលបានទទួលសញ្ជាតិនេះ

៥. កម្មវត្ថុពាណិជ្ជកម្ម ។

៦. ទីកន្លែងធ្វើអាជីវកម្ម និង អាស័យដ្ឋាន គ្រឹះស្ថាន ឬ សាខា នៃមូល.និធិពាណិជ្ជកម្ម ដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា ។

៧. ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន និង ហត្ថលេខាគំរូរបស់សាមីខ្លួន ព្រមទាំងស្នាមត្រាគំរូ ។

៨. លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិ ដែលទទួលរ៉ាប់រងក្នុងការសុំចុះបញ្ជីពាណិជ្ជកម្ម ។

៩. គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុន ឬ គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំកំពុងធ្វើអាជីវកម្មនៅក្នុងរង្វង់សមត្ថកិច្ចក្រសួងពាណិជ្ជកម្ម ។

១០.សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម ។

១១.ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឱ្យប្រកបមុខរបរ ចំពោះមុខរបរណា ឬ ចំពោះកម្មវត្ថុពាណិជ្ជកម្មណា ដែលតម្រូវឱ្យមានសេចក្តីអនុញ្ញាត ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិ-ជ្ជកម្ម ដោយប្រគល់ប្រតិវេទន៍នេះមួយច្បាប់ក្នុងចំណោមប្រតិវេទន៍

ទាំពីរច្បាប់ជូនដល់អ្នកស្នើសុំចុះឈ្មោះ ដោយបញ្ជាក់នៅខាងក្រោមថា " បានចម្លងចូលបញ្ជីរួចហើយ " ។

## មាត្រា ១៥ :

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម និង ក្រុមហ៊ុនផងដែរនូវ ៖

១. រាល់ការផ្លាស់ប្តូរ និងការកែប្រែទាក់ទងទៅនឹងហេតុការណ៍ទាំងឡាយ ដែលមាត្រាមុន បានអនុញ្ញាតឱ្យចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

២. សាលក្រម ឬសាលដីកាដែលសំរេចឱ្យពាណិជ្ជករលែងលះប្តី ប្រពន្ធ។

៣. ប្រកាសនីយប័ត្រតក្កកម្មដែលត្រូវបានធ្វើអាជីវកម្ម ឬ សញ្ញាផលិតកម្ម ឬ សញ្ញា ដែលពាណិជ្ជករប្រើប្រាស់ ។

៤. សាលក្រម ឬសាលដីកាតែងតាំងក្រុមប្រឹក្សាជំនួយអមពាណិជ្ជករ ឬ សាលក្រម ឬសាលដីការ ឬប្រកាសហាមឃាត់ពាណិជ្ជករ មិនឱ្យធ្វើពាណិជ្ជកម្មព្រមទាំងសាលក្រម ឬសាលដីកាលើកការហាមឃាត់ចេញ

៥. លិខិតបញ្ចាំ ឬ និក្ខេប (អ៊ីប៉ូតែក) លើទ្រព្យសំខាន់ៗសំរាប់អាជីវកម្ម

៦. សាលក្រមប្រកាសធនក្ស័យ ឬ ការជម្រះបញ្ជីតាមផ្លូវតុលាការ ។

៧. អនុប្បទានពាណិជ្ជមូលនិធិ ។

## មាត្រា ១៦.– ថ្មី

ការចុះនិទ្ទេសដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ជាភារកិច្ចផ្ទាល់ខ្លួនរបស់ពាណិជ្ជករ ។ ប៉ុន្តែចំពោះករណីដែលមានចែងនៅក្នុងចំណុច ២. ៤ និង ៦ នៃមាត្រា ១៥ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មអាចចុះសេចក្តីនោះជាបញ្ញត្តិក្នុងបញ្ជីពាណិជ្ជកម្ម ដែលសាមីពាណិជ្ជករបានចុះឈ្មោះ ។

# ផ្នែកទី ៣
## ក្រុមហ៊ុនដែលមានទីស្នាក់ការដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា

### មាត្រា ១៧.– ថ្មី

គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើត និង ថិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ។

ការចុះឈ្មោះនេះត្រូវធ្វើឡើងដោយបណ្ណាធិការ ឬ អភិបាលនៃសាមីក្រុមហ៊ុននៅក្នុង ខែ នៃការបង្កើតក្រុមហ៊ុន និង ដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

អ្នកស្នើសុំចុះឈ្មោះ ត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង ។

ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះ ត្រូវចែងអំពី ៖

១. នាមត្រកូល និង នាមខ្លួន រហស្សនាម របស់សមាជិកក្រុមហ៊ុន ថ្ងៃ.ខែ.ឆ្នាំ និង ទីកន្លែងកំណើត ស្ថានភាពគ្រួសារ និង សញ្ជាតិ ។

២. ផ្លាកសញ្ញារបស់ក្រុមហ៊ុន

៣. កម្មវត្ថុនៃក្រុមហ៊ុន

៤. ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម មានសាខា ឬ ទីភ្នាក់ងារ នៅព្រះរាជាណាចក្រកម្ពុជា ។

៥. នាមនៃសមាជិក ឬ តតិយជន ដែលមានការអនុញ្ញាតឱ្យគ្រប់គ្រង ចាត់ចែង ចុះចាត់ចែង និង ចុះហត្ថលេខា ជំនួសមុខក្រុមហ៊ុន ថ្ងៃ.ខែ.ឆ្នាំ និង ទីកន្លែងកំណើត នៃអ្នកទាំងនេះ ។

៦. ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និង ចំនួនទឹកប្រាក់ ឬ វត្ថុ

មានតំលៃ ដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុន ដោយភាគហ៊ុន ។

៧. ថ្ងៃ.ខែ.ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើម និង បញ្ចប់ ។

៨. ទ្រង់ទ្រាយក្រុមហ៊ុន ។

៩. ហត្ថលេខាគំរូរបស់សមាជិក ឬ តតិយជន ដូចមានចែងនៅចំណុច លេខ ៥ នៃមាត្រានេះ និង ស្លាកត្រាគំរូ របស់ក្រុមហ៊ុន ។

១០. លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ។

១១. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថាគ្មានជាប់ទោសពៃរ៍ក្នុង កិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ។

## មាត្រា ១៨ :

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មផងដែរនូវ ៖

១. រាល់ការផ្លាស់ ប្តូរកែប្រែ ទាក់ទងនឹងហេតុការណ៍ ដែលមាត្រាមុន បានបញ្ញត្តិឱ្យចុះសេចក្តីក្នុងបញ្ជីពាណិជ្ជកម្ម ។

២. នាមត្រកូល និងនាមខ្លួន ថ្ងៃ.ខែ.ឆ្នាំ និង ទីកន្លែងកំណើតនៃបណ្ណា. ធិការ អភិបាល ឬ នាយកដែលបានទទួលការតែងតាំងក្នុងអាយុកាល របស់ក្រុមហ៊ុន ។

៣. ប្រកាសនីយបត្រតក្កកម្មដែលត្រូវបានធ្វើអាជីវកម្ម និងសញ្ញាផលិតកម្ម ដែលក្រុមហ៊ុន ប្រើប្រាស់ ។

៤. សាលក្រម ឬ សាលដីកា ដែលប្រកាសរំលាយ ឬ ប្រកាសមោឃភាព នៃក្រុមហ៊ុន ។

៥. សាលក្រម ឬ សាលដីកាដែលប្រកាសធនក្ស័យ ឬ ការជំរះបញ្ជីតាម ផ្លូវតុលាការ របស់ក្រុមហ៊ុន ។

# ផ្នែកទី ៤

## ក្រុមហ៊ុនបរទេសដែលមានតែ សាខា ឬ ទីភ្នាក់ងារ នៅព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩ :**

ត្រូវចុះបញ្ជីពាណិជ្ជកម្មផងដែរ រាល់ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលមាន ត្រឹមតែសាខា ឬ ទីភ្នាក់ងារ នៅព្រះរាជាណាចក្រកម្ពុជា ។

ចំពោះការចុះបញ្ជីនេះ ត្រូវបំពេញទំរង់ការដូចចែងក្នុងមាត្រា ១៧ និង ១៨ នៃច្បាប់នេះ ។

**មាត្រា ២០ :**

រាល់ការកែប្រែ ឬ ការផ្លាស់ប្តូរ ដែលកើតមានឡើងចំពោះសាខា ឬ ទីភ្នាក់ងារ ត្រូវកត់ត្រាចូលក្នុងបញ្ជីពាណិជ្ជកម្ម តាមបញ្ញត្តិមាត្រា ១៨ នៃច្បាប់នេះ។

# ផ្នែកទី ៥

## បទបញ្ញត្តិរួម

**មាត្រា ២១.– ថ្មី**

ប្រតិវេទន៍ធ្វើឡើងជាបីច្បាប់ ត្រូវយកទៅដាក់ដោយអ្នកស្នើសុំ ឬ ដោយ អាណត្តិគាហករបស់សាមីជននោះ ក្នុងករណីនេះ អាណត្តិគាហក ត្រូវមានលិខិត ប្រគល់សិទ្ធិអំណាច ដែលត្រូវតម្កល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃ ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២២.– ថ្មី

បើប្រតិវេទន៍ ត្រូវបានយកទៅដាក់ផ្ទាល់ដោយអ្នកស្នើសុំនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវពិនិត្យពិច័យអត្តសញ្ញាណរបស់សាមីខ្លួនឱ្យបានច្បាស់លាស់ ។ បើសិនប្រតិវេទន៍នេះត្រូវបានយកទៅតម្កល់ទុកដោយអាណត្តិគាហក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវតំរូវឱ្យមានការបញ្ជាក់អំពីហត្ថលេខារបស់អាណត្តិទាយក ឬការបញ្ជាក់អំពីស្នាមមេដៃ បើអាណត្តិទាយកមិនចេះចុះហត្ថលេខា និង តម្រូវឱ្យបង្ហាញលិខិតបញ្ជាក់អត្តសញ្ញាណរបស់អ្នកស្នើសុំ ។

មាត្រា ២៣ :

និទ្ទេសទាំងឡាយដែលច្បាប់តម្រូវឱ្យធ្វើនោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរនៅលើប្រតិវេទន៍ដែលអាចអានបានដោយគ្មានបំព្រួញ គ្មានកោសលុប គ្មានជ្រៀតបន្ថែម ។ ការបន្ថែមពាក្យនៅលើរឹមទំព័រ ត្រូវមានចុះហត្ថលេខាសង្ខេបបញ្ជាក់ ហើយចំនួនពាក្យបន្ថែមនោះ ព្រមទាំងចំនួនពាក្យដែលលុបចោល ត្រូវតែរាប់ និង បញ្ជាក់ ។

មាត្រា ២៤ :

ប្រកាសនីយប័ត្រតក្កកម្មដែលត្រូវបានធ្វើអាជីវកម្ម និង សញ្ញាផលិតកម្មដែលបានតម្កល់ទុក ត្រូវបញ្ជាក់លេខ ថ្ងៃ.ខែ.ឆ្នាំ នៃការតម្កល់ទុក ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ច ។

មាត្រា.២៥.– ថ្មី

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្ទៀងផ្ទាត់មើលក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន អំពីបែបបទទាំងឡាយដែលបានបញ្ញត្តិ ។
មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវចុះនៅលើផ្នែកខាងលើនៃប្រតិវេទន៍នូវ ៖

១. ថ្ងៃ.ខែ.ឆ្នាំ. ម៉ោង នៃការតម្កល់ទុក និង ទីកន្លែងក្រសួងពាណិជ្ជកម្ម។
២. លេខរៀងរបស់ប្រតិវេទន៍តាមលំដាប់លេខជាបន្តបន្ទាប់ ក៏ប៉ុន្តែការចុះលេខនេះត្រូវចាប់ផ្តើមឡើងវិញចាប់ពីថ្ងៃទី ០១ មករា ជារៀងរាល់ឆ្នាំ។
៣. អត្តលេខសំគាល់ទៅតាមបែបផែននៃសកម្មភាពរបស់ពាណិជ្ជករ ដែលចុះក្នុងបញ្ជីកាតិ ដែលនឹងមានចែងខាងក្រោយ ។

ចំពោះអ្នកធ្វើប្រតិវេទន៍ណាដែលមិនបានផ្តល់ នូវរាល់ពត៌មានគ្រប់គ្រាន់ដល់ការចុះបញ្ជី នឹងត្រូវបានអនុញ្ញាតរយៈពេលពិសេសចំនួនដប់ប្រាំថ្ងៃ (១៥ថ្ងៃ) បន្ថែម។

## មាត្រា ២៦.– ថ្មី

ដោយបានឃើញប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងរាល់ឯកសារតម្កល់ទុក មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នឹងផ្តល់នូវវិញ្ញាបនប័ត្រចុះបញ្ជីហៅថា "សំរង់" ដែលមានចែងអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រនេះ ស្ថិតក្នុងលក្ខណៈជាបណ្តោះអាសន្នក្នុងថិរវេលាមួយខែ(១ខែ)គិតចាប់ពីកាលបរិច្ឆេទដែលបានផ្តល់ជូន។ ក្នុងថិរវេលានេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ មន្ត្រីចុះបញ្ជីពាណិជ្ជ. កម្មនៃក្រសួងពាណិជ្ជកម្ម អាចជំទាស់នឹងការចុះបញ្ជី និងលុបចោលអត្តលេខសំគាល់ដែលមានចុះក្នុងបញ្ជីហើយនោះ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មដែលផ្តល់នូវវិញ្ញាបនប័ត្រក្លែងបន្លំ ដែលបានធ្វើឡើងដោយដឹងហេតុផលសព្វគ្រប់ ត្រូវទទួលទោសតាមច្បាប់ ។

## មាត្រា ២៧ :

ប្រតិវេទន៍ទាំងឡាយណា ដែលបានធ្វើក្រោយការចុះអត្តលេខ ត្រូវស្រង់យកលេខប្រតិវេទន៍ដើម និង លេខបញ្ជីកាតិ ដែលបានផ្តល់ជូននៅពេលចុះអត្តលេខនោះ។

## មាត្រា ២៨.– ថ្មី

កាលណាបើពាណិជ្ជករណាម្នាក់ឈប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ឬ ទទួលមរណភាពដោយពុំបានធ្វើអនុប្បទានទ្រព្យមូលនិធិពាណិជ្ជកម្មរបស់ខ្លួន ឬ កាលណាបើក្រុមហ៊ុនណាមួយត្រូវរំលាយនោះ ត្រូវលុបឈ្មោះពាណិជ្ជករនោះ ឬ ក្រុមហ៊ុននោះចេញពីបញ្ជី ។

បើសិនជាគ្មានការសុំលុបឈ្មោះដោយពាណិជ្ជករ ឬ ដោយអ្នកទទួលមរតក ឬ ដោយអ្នកជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះ ត្រូវធ្វើឡើងដោយបញ្ញត្តិ តាមសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មនេះ ត្រូវចម្លងជូនទៅតុលាការពាណិជ្ជកម្មដើម្បីតម្កល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម។

## មាត្រា ២៩.– ថ្មី

ជនណាក៏ដោយអាចសុំឱ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឱ្យខ្លួននូវវិញ្ញាបនប័ត្របញ្ជាក់អំពីចំណារទាំងឡាយដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ បើគ្មានចុះបញ្ជីទេ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់ថា គ្មានចុះបញ្ជី ។

ការធ្វេសប្រហែស ឬ ការមិនព្រមចេញវិញ្ញាបនប័ត្រក្នុងរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃស្នើសុំ នឹងបណ្តាលឱ្យមានទណ្ឌកម្មតាមវិន័យចំពោះមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងមានការសងជំងឺចិត្តផង ។

សេចក្តីចម្លង ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឱ្យនោះ មិនត្រូវចែងសាលក្រមប្រកាសធនក្ស័យ ឬ ការជំរះបញ្ជីតាមផ្លូវតុលាការទេ បើក្រោយមកមាននីតិសម្បទាឡើងវិញ ។ សេចក្តីចម្លងក៏មិនត្រូវចុះផងដែរនូវសាលក្រម ឬ សាលដីកាហាមឃាត់ មិនឱ្យធ្វើពាណិជ្ជកម្ម ឬ សាលក្រមសាលដីកាតែងតាំងក្រុមប្រឹក្សាជំនួយ បើមានលើកការហាមឃាត់ចេញរួចហើយ ។

# ផ្នែកទី ៦
## អំពីបញ្ជីពាណិជ្ជកម្ម រូបភាព និង សមាសភាព

### មាត្រា ៣០ .– ថ្មី

បញ្ជីពាណិជ្ជកម្ម ដែលតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម មានពីរបែបគឺ ៖

១. បញ្ជីកាលប្បវត្តិ

២. បញ្ជីវិភាគ

### មាត្រា ៣១ .– ថ្មី

ប្រតិវេទន៍ ត្រូវចុះក្នុងគល់បញ្ជីកាលប្បវត្តិ តាមលំដាប់នៃការតម្កល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម និង តាមលេខ ដែលចុះ ។

ត្រូវប្រគល់ចុងសន្លឹកនៃប្រតិវេទន៍មួយសន្លឹក ដែលដាច់ចេញពីគល់បញ្ជី ហៅថា "សំរង់" ជាសំគាល់នៃការតម្កល់ទុកដោយមានចែងនិទ្ទេសដូចតទៅ ៖

១. លេខរៀងនៃប្រតិវេទន៍

២. ថ្ងៃ.ខែ.ឆ្នាំ ម៉ោង នៃការតម្កល់ទុក និងទីកន្លែងនៃក្រសួងពាណិជ្ជកម្ម

៣. នាមត្រកូល នាមខ្លួន ផ្លាកសញ្ញាក្រុមហ៊ុន និង លំនៅដ្ឋានអ្នកធ្វើប្រតិវេទន៍ ។

ចំណែកឯបញ្ជីវិភាគវិញ មានទ្រង់ទ្រាយជាតារាងដែលត្រូវចុះជាអាទ៍នូវលេខ. ថ្ងៃ.ខែ.ឆ្នាំ. ម៉ោង នៃការតម្កល់ទុក អក្ខលេខ នាមករណ៍ក្រុមហ៊ុន កម្មវត្ថុនៃក្រុមហ៊ុន ដើមទុននៃក្រុមហ៊ុន ។ គ្រឹះស្ថានពាណិជ្ជកម្មនីមួយៗដែលជាកម្មវត្ថុនៃការចុះអក្ខលេខសំគាល់ដោយឡែក ត្រូវបានចុះលើសន្លឹកមួយទាំងសងខាង ហើយនៅលើសន្លឹកនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចារលេខប្រតិវេទន៍ដើមនៃការសុំចុះបញ្ជីនោះ។

## មាត្រា ៣២.– ថ្មី

បើមានពាក្យសុំឱ្យចុះនិទ្ទេស ដែលបង្គឱ្យលុបចោលនិទ្ទេសដែលមានស្រាប់ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវគូសលុបនិទ្ទេសនេះដោយទឹកខ្មៅក្រហម ឬ លុបខ្វែងចំណាំតាមកម្មវិធីកុំព្យូទ័រ ដោយមានសរសេរបង្ហាញនៅលើរឹមទំព័រនូវសេចក្ដីយោងនៃនិទ្ទេសថ្មី និងលេខ ដែលក្រោមលេខនេះ ប្រតិវេទន៍ ឬ ពាក្យសុំចុះនិទ្ទេសនោះត្រូវបានចុះបញ្ជីដោយពិតប្រាកដ ។

## មាត្រា ៣៣.– ថ្មី

បើសិនមានការលុបឈ្មោះចេញពីបញ្ជី ការលុបនេះត្រូវធ្វើឡើងដោយគំនូសក្រហមពីរខ្វែងគ្នា ឬ លុបតាមវិធីកុំព្យូទ័រ ។

សេចក្ដីសំរេចលុបឈ្មោះបញ្ជីចេញពីបញ្ជីដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬ ពាក្យសុំឱ្យលុបឈ្មោះនោះ ត្រូវកំណត់សរសេរនៅលើរឹមទំព័រ ដោយទឹកខ្មៅក្រហមផងដែរ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មបញ្ជាក់និទ្ទេសនេះ ដោយចុះហត្ថលេខាសង្ខេប ។

## មាត្រា ៣៤.– ថ្មី

កាលបើនិទ្ទេសដែលមាននៅក្នុងប្រតិវេទន៍ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងបញ្ជីវិភាគ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវប្រគល់ជូនអ្នកដែលយកមកតម្កល់ទុកនូវប្រតិ-វេទន៍មួយច្បាប់ ដែលមានចុះហត្ថលេខាត្រឹមត្រូវ សំរាប់ប្រើប្រាស់ជាវិញ្ញាបនប័ត្រចុះឈ្មោះ ។

សន្លឹកប្រតិវេទន៍ទាំងអស់ដែលរក្សាទុកនៅទីកន្លែងចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ត្រូវមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចងក្រងតាមលេខរៀង យ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។

មាត្រា ៣៥.– ថ្មី

បញ្ជីកាលប្បវត្តិ និងបញ្ជីវិភាគ ត្រូវបានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាអ្នកបង់លេខ ចុះហត្ថលេខាសង្ខេប និង ពិនិត្យបញ្ជាក់ទៅពេលជាចំខែម្តងៗ ។ ការពិនិត្យបញ្ជាក់នេះ ត្រូវមានបោះត្រារបស់ក្រសួងពាណិជ្ជកម្ម និងចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

បើរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបញ្ជាក់ថា ប្រតិវេទន៍ណាមួយចូលក្នុងករណីដែលមានចែងក្នុងមាត្រា៤០ថ្មី និងមាត្រា៤១ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវប្តឹងអំពីរឿងនេះ ទៅព្រះរាជអាជ្ញាអមតុលាការមានសមត្ថកិច្ច ។

មាត្រា ៣៦.– ថ្មី

ការចុះឈ្មោះ ការលុបឈ្មោះ ឬការចេញវិញ្ញាបនប័ត្រផ្សេងៗជាភារៈផ្ទាល់របស់មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រទាំងនេះត្រូវចេញអោយអ្នកសុំពីសៀវភៅក្បាលបញ្ជីមានលេខ ។ អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬចេញវិញ្ញាបនប័ត្រផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រមូលដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម សំរាប់បង់ចូលថវិការដ្ឋ ។

មាត្រា ៣៧.– ថ្មី

សេចក្តីចម្លងនៃការចុះឈ្មោះក្នុងបញ្ជី ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម និង វិញ្ញាបនប័ត្របញ្ជាក់ពីការគ្មានចុះឈ្មោះ ចេញដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវផ្តល់ជូនដោយឥតគិតថ្លៃតាមពាក្យសុំរបស់អាជ្ញាធរ តុលាការ ឬ រដ្ឋបាលបានលុះត្រាតែមានចុះនិទ្ទេសពីកន្លែងអ្នកទទួលលិខិតនោះ ។

## មាត្រា ៣៨.– ថ្មី

រាល់ការចុះឈ្មោះក្នុងបញ្ជី និង លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវបានចុះផ្សាយដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្មក្នុងរាជកិច្ច ។
និទ្ទេសដែលត្រូវចុះផ្សាយមានដូចខាងក្រោមនេះ ៖

ក. ចំពោះពាណិជ្ជករ

១. លេខចុះបញ្ជី

២. នាមត្រកូល នាមខ្លួន រហស្សនាម ព្រមទាំងនាមសហព័ទ្ធ

៣. សកម្មភាព ទីកន្លែង ថ្ងៃ.ខែ.ឆ្នាំចាប់ផ្តើមសកម្មភាព

៤. ផ្លាកសញ្ញា ។

ខ. ចំពោះក្រុមហ៊ុន

១. លេខចុះបញ្ជី

២. នាមករណ៍

៣. ចំនួនដើមទុន

៤. ទីស្នាក់ការ

៥. សកម្មភាព និង ថ្ងៃ.ខែ.ឆ្នាំចាប់ផ្តើម

៦. ទ្រង់ទ្រាយក្រុមហ៊ុន ។

# ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៩ :**

រាល់ពាណិជ្ជករ ឬ រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ នឹងត្រូវប្តឹងទៅតុលាការអំពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់ ។

**មាត្រា ៤០.– ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំម៉ឺន (៥០.០០០) រៀល ទៅប្រាំសែន (៥០០.០០០) រៀល ចំពោះ ៖

១. រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ ។

២. រាល់ពាណិជ្ជករ ឬ រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក័យប័ត្រ លិខិតស្នាម កំណត់បញ្ជាទិញ តារាងតម្លៃ និង ឯកសារផ្សព្វផ្សាយអំពីទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម ដែលខ្លួនបានចុះឈ្មោះ និង លេខ ដែលខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

**មាត្រា ៤១ :**

ការដែលមិនបានបំពេញកាតព្វកិច្ចសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមការបញ្ញត្តិ អាចបណ្តាលឱ្យពាណិជ្ជករ ឬ អ្នកដឹកនាំក្រុមហ៊ុន មានទោសនិទ្ទនភាពសាមញ្ញ ក្នុងករណីធនក្ស័យ ។

## មាត្រា ៤២.– ថ្មី

រាល់ពាណិជ្ជករ ឬ រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានផ្តល់នូវពត៌មានមិនពិតដោយគំនិតអាក្រក់ដើម្បីនឹងសុំចុះលេខ ឬសុំចុះឈ្មោះ ក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីមួយលាន ( ១ ០០០ ០០០ ) រៀល ទៅដប់លាន ( ១០ ០០០ ០០០ ) រៀល ។

ក្នុងករណីដែលមានការផ្លាស់ប្តូរ កែប្រែពត៌មានដូចបានកំណត់ក្នុងមាត្រា១៥ ចំណុច១ ១៨ចំណុច១ និងមាត្រា២០ រាល់ពាណិជ្ជករ ឬ អ្នកដឹកនាំក្រុមហ៊ុនណា ដែលមិនបានបំពេញបែបបទនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) ក្រោយពីមានការផ្លាស់ប្តូរ កែប្រែនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំសែន (៥០០ ០០០) រៀល ទៅមួយលាន (១ ០០០ ០០០) រៀល ។

## មាត្រា ៤៣ :

រាល់ពាណិជ្ជករ ឬ រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលប្រើឯកសារក្លែងក្លាយដោយចេតនានៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំ ( ១ឆ្នាំ ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និង ពិន័យជាប្រាក់ពីមួយលាន ( ១ ០០០ ០០០ ) រៀល ទៅដប់លាន (១០ ០០០ ០០០ ) រៀល ។

## មាត្រា ៤៤.– ថ្មី

ក្នុងករណីមិនរាងចាល ការផ្តន្ទាទោសដូចមានក្នុងមាត្រា ៤០ថ្មី វាក្យខ័ណ្ឌទី១ នៃមាត្រា ៤២ថ្មី មាត្រា៤៣ ត្រូវអនុវត្តកំរិតអតិបរិមា ហើយបើមានបទល្មើសដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី២ នៃមាត្រា៤២ថ្មីមិនរាងចាលនោះ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុន ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីបីខែ(៣ខែ) ទៅមួយឆ្នាំ(១ឆ្នាំ)។

មាត្រា ៤៥ :

ជនណាដែលបានជីវិត ឬបានទទួលនូវរបស់ ឬប្រាក់ដោយប្រើអំណាចនៃមុខងាររបស់ខ្លួន ជននោះត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស ហើយនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៤៦ :

ប្រាក់ពិន័យទាំងឡាយដូចមានចែងក្នុងច្បាប់នេះ ត្រូវបង់ចូលថវិការដ្ឋ ។

# ជំពូកទី ៣

## ភាតព្វកិច្ចគណនេយ្យ

មាត្រា ៤៧ :

រាល់ពាណិជ្ជករ ឬ រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្ម មានកាតព្វកិច្ចកាន់កាប់គណនេយ្យមួយ នៅតាមវិធានគណនេយ្យ និង តាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការណែនាំផ្សេងៗទៀត ដែលទាក់ទងដល់ការអនុវត្តន៍។

រាល់ពាណិជ្ជករ ឬ រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលប្រព្រឹត្តល្មើសផ្ទុយនឹងបទបញ្ញាគណនេយ្យដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនេះ ត្រូវចោទប្រកាន់ និង ផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៤៨ :

គ្រប់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវបើកគណនីយ៉ាងហោចមួយ នៅធនាគារណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤៩ :

រាល់ពាណិជ្ជកិច្ចដែលធ្វើឡើងរវាងអាជីវករ និងអាជីវករ ត្រូវមានវិក័យប័ត្រយ៉ាងហោចណាស់ពីរច្បាប់ ។ ច្បាប់ដើមមួយសន្លឹកសំរាប់ផ្តល់ជូនអតិថិជន ហើយសន្លឹកផ្សេងទៀតត្រូវរក្សាទុកដោយអ្នកលក់ ។

ចំពោះការលក់ទំនិញ ឬការធ្វើសេវាឱ្យអ្នកប្រើប្រាស់ ពុំចាំបាច់ធ្វើវិក័យប័ត្រ ឬ សក្ខីប័ត្រទេ លើកលែងតែអតិថិជនទាមទារ ។

មាត្រា ៥០ :

ក្នុងវិក័យប័ត្រ ត្រូវមានចុះយ៉ាងហោចណាស់នូវនិទ្ទេស ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៥១ :

រាល់ពាណិជ្ជករ ត្រូវបិទតម្លៃ និងលក្ខខ័ណ្ឌនៃការលក់ផ្សេងៗដែលនៅជាធរមាន។ បែបបទនៃការបិទផ្សាយ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ៥២ :

រាល់ថ្លៃទាំងឡាយ ត្រូវតែកំណត់ជាប្រាក់រៀល លើកលែងតែក្នុងករណីដែលមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ។

មាត្រា ៥៣ :

រាល់ការទិញ ឬការលក់ រវាងពាណិជ្ជករ និងពាណិជ្ជករដែលមានទឹកប្រាក់ស្មើ ឬលើសពីដប់លាន (១០ ០០០ ០០០) រៀល ឬសមមូលជារូបិយប័ណ្ណបរទេស ត្រូវតែធ្វើការទូទាត់ដោយ មូលប្បទានប័ត្រ ឬ ដោយផលប័ត្រពាណិជ្ជកម្ម ។

# ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

### មាត្រា ៥៤.– ថ្មី

ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជា នៅពុំទាន់មានតុលាការពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មត្រូវរៀបចំថែរក្សាច្បាប់ចម្លងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និងច្បាប់ដើមនៃរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម រហូតដល់តុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើង ។

### មាត្រា ៥៥ :

ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជា នៅពុំទាន់មានតុលាការពាណិជ្ជកម្ម តុលាការនីតិសាមញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចលើរឿងក្តីពាណិជ្ជកម្មទាំងអស់ ។

### មាត្រា ៥៦ :

ក្រសួងនីមួយៗដែលពាក់ព័ន្ធ ត្រូវជំរុញរាល់ពាណិជ្ជករ ឬ រាល់ក្រុមហ៊ុនពាណិជ្ជកម្មឱ្យចាត់ចែងធ្វើពាក្យសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅពេលដែលច្បាប់នេះចូលជាធរមាន ។

### មាត្រា ៥៧.– ថ្មី ( មាត្រា ៥៨ ចាស់)

រាល់ពាណិជ្ជករ និងរាល់ក្រុមហ៊ុនពាណិជ្ជកម្មដែលបានធ្វើសកម្មភាពមុនការប្រកាសឱ្យប្រើច្បាប់នេះ ត្រូវប្តឹងសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេលប្រាំមួយខែ ( ៦ ខែ )។ បើមានការចាំបាច់ ក្រសួងពាណិជ្ជកម្ម

អាចសំរេចបន្តរយៈពេលនេះបានប្រាំមួយខែ ( ៦ ខែ ) ទៀត ។

មាត្រា ៥៨.– ថ្មី ( មាត្រា ៥៩ ចាស់ )

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

# ជំពូកទី ៥

## អវសានបញ្ញត្តិ

មាត្រា ៥៩.– ថ្មី ( មាត្រា ៦០ ចាស់ )

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

**ចម ប្រសិទ្ធ**

# ច្បាប់

# ស្តីពី

# សហគ្រាសពាណិជ្ជកម្ម

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះកំណត់ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។

**មាត្រា ២.-**

នៅក្នុងច្បាប់នេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-បុគ្គលមានន័យថារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

២-មន្ត្រីចុះបញ្ជីមានន័យថាអ្នកចុះបញ្ជី ដែលបានតែងតាំងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

៣-ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមានន័យថាការិយាល័យដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

៤-បុត្រសម្ព័ន្ធមានន័យថាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ" ។

ក-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិគឺក្រុមហ៊ុនសហកម្មសិទ្ធិមេនោះកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ ។

ខ-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនគឺក្រុមហ៊ុនមូលធនមេនោះត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ។

**មាត្រា ៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជី និងភ្នាក់ងារចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដ និងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់ភ្នាក់ងារចុះបញ្ជី ហើយភ្នាក់ងារចុះបញ្ជីនោះ ត្រូវតែជារូបវន្តបុគ្គល ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ ។ ភ្នាក់ងារចុះបញ្ជីមានសិទ្ធិទទួលលិខិតផ្លូវការ និងឯកសារទាំងឡាយ ព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី និងការផ្លាស់ប្តូរភ្នាក់ងារចុះបញ្ជីក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរ ។

ក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះ ត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ឯកសារទាំងឡាយនៃព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រគល់ឱ្យទៅភ្នាក់ងារចុះបញ្ជីនៅឯទីស្នាក់ការចុះបញ្ជី នៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់ ។

ឯកសារទាំងឡាយអាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករទូទៅបានក្នុង

ករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ឬ អាចប្រគល់ឱ្យទៅអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន ។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះ ត្រូវផ្ញើឱ្យ ទៅក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្មស្រាប់ ។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីត្រូវបានចាត់ទុកថាជាការបញ្ជូនទៅក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

**មាត្រា ៥.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ ។ នាមករណ៍ជាភាសាខ្មែរ ត្រូវដាក់នៅផ្នែកខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងភាសាដទៃទៀតប្រសិនបើមាន ។ ការបកប្រែន័យរបស់នាមករណ៍ក្រុមហ៊ុន ពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់ ។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរ នៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារ ឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់ និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ។

**មាត្រា ៦.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ដែលខកខានមិនបានបង់សោហ៊ុយ ប្រាក់ពិន័យ ការប្រាក់ដែលជំពាក់ក្រសួងពាណិជ្ជកម្ម ត្រូវហាមឃាត់ក្នុងការប្ដឹងផ្ដល់

ឬ ប្ដឹងតវ៉ាក្នុងរឿងក្ដីរដ្ឋប្បវេណីរហូតដល់បានសងគ្រប់នូវសោហ៊ុយ ប្រាក់ពិន័យ និងការប្រាក់នោះ ។

វាក្យខ័ណ្ឌនេះ មិនហាមឃាត់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនធ្វើការប្ដឹងតវ៉ាចំពោះការកំណត់សោហ៊ុយ ប្រាក់ពិន័យ ឬការប្រាក់ដែលខ្លួនត្រូវជំពាក់ឡើយ ។

ប្រសិនបើភាគីមួយប្ដឹងជំទាស់ថា ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនជំពាក់ក្រសួងពាណិជ្ជកម្មនូវសោហ៊ុយ ប្រាក់ពិន័យ ឬ ការប្រាក់ពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ត្រូវដាក់បង្កាន់ដៃទទួលប្រាក់របស់ក្រសួងពាណិជ្ជកម្មទៅឱ្យតុលាការពិនិត្យ ។ តុលាការត្រូវទទួលយកបង្កាន់ដៃនោះជាភស្ដុតាង រហូតដល់មានតឹកតាងផ្សេងៗទៀត ។

**មាត្រា ៧.–**

ក្រុមហ៊ុនដែលគ្រប់គ្រងដោយច្បាប់នេះ មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ២

## ក្រុមហ៊ុនសហកម្មសិទ្ធិ

## ផ្នែកទី ១

## ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### ក–ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**មាត្រា ៨.–**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬ ច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជ-កិច្ចរួម ក្នុងគោលបំណងរកប្រាក់ចំណេញ ។

**មាត្រា ៩.–**

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ប្រសិនបើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

**មាត្រា ១០.–**

ក្នុងករណីដែលកិច្ចសន្យានោះមិនច្បាស់លាស់ តុលាការត្រូវពិចារណានូវវិធានដូចខាងក្រោម ដើម្បីកំណត់ថាតើភាគីទាំងអស់មានគោលបំណងរួមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឬទេ :

ក-ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើន កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើបុគ្គលទាំងនោះចែករំលែកប្រាក់ចំណេញដែលបានមកដោយទ្រព្យទាំងនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ កើតឡើងដោយទ្រព្យសម្បត្តិរួមឬទេ ។

ខ-ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើនចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកិច្ច ថាតើបុគ្គលទាំងនោះ មានសិទ្ធិចូលរួមក្នុងទ្រព្យសម្បត្តិណាមួយដែលបង្កើតប្រាក់ចំណូលនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះកើតឡើងដោយទ្រព្យសម្បត្តិរួមនោះឬទេ ។

**មាត្រា ១១.–**

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យាត្រូវជាប់កាតព្វកិច្ចចាប់ពីពេលដែលកិច្ចសន្យានោះ ត្រូវបានធ្វើឡើងចប់សព្វគ្រប់លើកលែងតែកិច្ចសន្យាមានចែងផ្សេងពីនេះ ។

**មាត្រា ១២.–**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហ-កម្មសិទ្ធិករទូទៅម្នាក់ៗ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់ពី

ពេលដែលបានចុះបញ្ជី ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ហើយមានសិទ្ធិដូចតទៅ :

ក-ជាម្ចាស់លើចលននិងអចលនទ្រព្យក្នុងនាមក្រុមហ៊ុន ។

ខ-ធ្វើពាណិជ្ជកិច្ចក្នុងនាមក្រុមហ៊ុន ។

គ-ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន ។

ឃ-ប្តឹង ឬ ត្រូវគេប្តឹងក្នុងនាមក្រុមហ៊ុន ។

**មាត្រា ១៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរលុះត្រាតែ :

ក-ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១(ហាសិបមួយ)ភាគរយត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលមានសញ្ជាតិខ្មែរ ។

**មាត្រា ១៤.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ហើយនៅខាងក្រោយ ឬ ខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅក្នុងពេលធ្វើពាណិជ្ជកិច្ច ។

**មាត្រា ១៥.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ។

## ខ_ ទំនាក់ទំនងពីសហកម្មសិទ្ធិករទូទៅម្នាក់ ទៅសហកម្មសិទ្ធិករទូទៅម្នាក់ទៀត

**មាត្រា ១៦._**

សហកម្មសិទ្ធិករទូទៅម្នាក់ៗអាច :

ក-បង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬ ជាការសន្យាថានឹងផ្តល់នូវសេវានាពេលអនាគត ។

ខ-ដាក់ភាគទុនជាសេវាដែលជាចំណេះដឹង ឬ សកម្មភាពផ្សេងៗ ប៉ុន្តែមិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈ ។

**មាត្រា ១៧._**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាកូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចំពោះរាល់អ្វីៗដែលខ្លួនបានសន្យាចូលរួមទៅក្នុងក្រុមហ៊ុន ។

**មាត្រា ១៨._**

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិជាភាគទុន សហកម្មសិទ្ធិករទូទៅនោះត្រូវធ្វើការផ្ទេរសិទ្ធិពីម្ចាស់ ឬ ពីសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ១៩._**

នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិនបានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួល

ខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ ។

**មាត្រា ២០.-**

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ភាគទុនជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ ។

កិច្ចសន្យាជាលាយលក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើភាគទុនរបស់សហកម្ម-សិទ្ធិករទូទៅជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព ។

**មាត្រា ២១.-**

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមានទាំងភាគទុនជាសាច់ប្រាក់ និងជាវត្ថុ ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ ។

ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬ ភាគទុនជាសកម្មភាពទេ ។

**មាត្រា ២២.-**

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ ។

**មាត្រា ២៣.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវមានសិទ្ធិទទួលប្រាក់ចំណេញ និងត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីសិទ្ធិទទួលប្រាក់ចំណេញត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីការជាប់កាតព្វ-កិច្ចក្នុងការរួមចំណែកការខាតបង់ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាពចំពោះតតិយជនឡើយ ។

**មាត្រា ២៤.-**

សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិ ប្រាក់ចំណេញ និងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា ។

ប្រសិនបើកិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងក្នុងករណីនេះ ត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែករណីទាំងបីនោះ ។

**មាត្រា ២៥.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយ ដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវ-កម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬ ពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហ-កម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ ។

**មាត្រា ២៦.-**

គ្មានសហកម្មសិទ្ធិករទូទៅណាម្នាក់ ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជ-កិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

**មាត្រា ២៧.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ ។

**មាត្រា ២៨.-**

សហកម្មសិទ្ធិករទូទៅដែលប្រកបកិច្ចការពាណិជ្ជកម្មដោយស្មោះត្រង់ចំពោះ ក្រុមហ៊ុន មានសិទ្ធិទទួលនូវសំណងនៃការខូចខាតដែលខ្លួនបានធ្វើក្នុងនាមក្រុមហ៊ុន សហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិទទួលនូវសំណងនៃការខូចខាតចំពោះកិច្ចសន្យា ដែលខ្លួនបានធ្វើ និងការខាតបង់ទាំងឡាយដែលខ្លួនទទួលរងនៅក្នុងការប្រតិបត្តិ ពាណិជ្ជកិច្ចសម្រាប់ក្រុមហ៊ុននោះ ។

**មាត្រា ២៩.-**

មាត្រា ២៨ នៃច្បាប់នេះអនុវត្តនៅពេលដែល :

ក-សហកម្មសិទ្ធិករទូទៅ ក្នុងនាមខ្លួនឯងផ្ទាល់ និងក្រុមហ៊ុនសហកម្មសិទ្ធិ ទូទៅរួមគ្នា ជាម្ចាស់បំណុលនៃកូនបំណុលតែមួយ ។

ខ-បំណុលទាំងពីរនឹងត្រូវសង ។

គ-កូនបំណុលត្រូវសងទៅសហកម្មសិទ្ធិករទូទៅ ប៉ុន្តែមិនសងទៅក្រុមហ៊ុន សហកម្មសិទ្ធិទូទៅទេ ។ ក្នុងករណីនេះ ចំនួននៃប្រាក់សំណងដែលសហកម្មសិទ្ធិករទូទៅ ទទួល ត្រូវបែងចែកទៅតាមសមាមាត្រទៅនឹងបំណុលផ្ទាល់ខ្លួន និងបំណុលចំពោះ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

**មាត្រា ៣០.-**

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម- សិទ្ធិទូទៅបាន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះ ប្រើប្រាស់ក្នុងប្រយោជន៍របស់ក្រុម ហ៊ុន ។

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានក្នុងលក្ខណៈជាការប្រើប្រាស់ផ្ទាល់ខ្លួន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះមានការយល់ព្រមជាឯកច្ឆន្ទពីគ្រប់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ។

រាល់សហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងករណីមិនប៉ះពាល់ដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ដែលប្រើប្រាស់ទ្រព្យសម្បត្តិនោះ ។

## មាត្រា ៣១.-

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចក្លាយជាសហកម្មសិទ្ធិករទូទៅដោយគ្មានការយល់ព្រមជាឯកច្ឆន្ទ ពីគ្រប់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានឡើយ ។

សហកម្មសិទ្ធិករទូទៅម្នាក់ អាចប្រគល់សិទ្ធិឱ្យទៅបុគ្គលផ្សេង ដើម្បីទទួលប្រាក់កាសជំនួសខ្លួនបាន ដោយមិនចាំបាច់មានការយល់ព្រមពីសហកម្មសិទ្ធិករទូទៅដទៃទៀតឡើយ ។ ការប្រគល់សិទ្ធិបែបនេះ មិនធ្វើឱ្យអ្នកទទួលសិទ្ធិនោះក្លាយទៅជាសហកម្មសិទ្ធិករទូទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទេ ។

## មាត្រា ៣២.-

សហកម្មសិទ្ធិករទូទៅម្នាក់ អាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

## មាត្រា ៣៣.-

ភាគទុនជាទ្រព្យ ឬ ប្រាក់ចំណេញរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចត្រូវបានប្រើប្រាស់ជាទ្រព្យធានានូវកាតព្វកិច្ចផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅនោះ ។ ទ្រព្យធានានោះ ត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

**មាត្រា ៣៤.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចធ្វើសេចក្តីសម្រេចអំពីសិទ្ធិរបស់ខ្លួននៅក្នុងការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

**មាត្រា ៣៥.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬ បុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅ ឱ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបាន ។

អ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួនដរាបណាអ្នកគ្រប់គ្រងនោះមិនប្រព្រឹត្តអំពើក្លែងបន្លំ ។ ការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែងដោយសំឡេងភាគច្រើនដោយប្រៀបនៃវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៣៦.-**

នៅពេលដែលបុគ្គលច្រើនរូបត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងក្រុមហ៊ុន អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ៗ អាចអនុវត្តសកម្មភាពដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៣៧.-**

សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ ។

**មាត្រា ៣៨.-**

រាល់សហកម្មសិទ្ធិករទូទៅមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ហើយការអនុវត្តសិទ្ធិនោះមិនត្រូវបានបង្អាក់ដោយសារកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ ។

**មាត្រា ៣៩.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព័ត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជីនិងកំណត់ហេតុ ទោះបីជាសហកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ ។

នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬ មិនត្រូវធ្វើឱ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្តសិទ្ធិដូចគ្នាឡើយ ។

## គ_ ទំនាក់ទំនងនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាមួយតតិយជន

### មាត្រា ៤០._

សហកម្មសិទ្ធិករទូទៅម្នាក់ៗគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ហើយសហកម្មសិទ្ធិករទូទៅទាំងនោះត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុននូវរាល់អំពើដែលខ្លួនបានអនុវត្ត ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវបានចាត់ទុកជាគ្មានប្រសិទ្ធភាព ។

### មាត្រា ៤១._

សហកម្មសិទ្ធិករទូទៅម្នាក់ដែលបានចុះកិច្ចសន្យាជាមួយតតិយជន ត្រូវបានជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណាដែលកាតព្វកិច្ចនោះស្ថិតក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬ នៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យានោះជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

### មាត្រា ៤២._

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

តតិយជនត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុល ឬ ទ្រព្យសម្បត្តិពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ ។

### មាត្រា ៤៣._

បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយ ត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលបំណុលនោះកើតឡើងដែរ ។ ប៉ុន្តែបំណុលទាំងឡាយ

ណាដែលបានកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ បំណុលនោះអាចត្រូវបានចេញសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវបានចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ លើកលែងតែបុគ្គលនោះមានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ ។

## មាត្រា ៤៤.–

ការជូនដំណឹងទៅសហកម្មសិទ្ធិករទូទៅណាម្នាក់ ឬ ការដឹងឮរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់ដែលពាក់ព័ន្ធទៅនឹងការងាររបស់ក្រុមហ៊ុន ត្រូវចាត់ទុកថាជាសេចក្ដីជូនដំណឹង និងការដឹងឮដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះដែរ លើកលែងតែមានការក្លែងបន្លំ ដែលប្រព្រឹត្តឡើងដោយការឃុបឃិតពីសហកម្មសិទ្ធិករទូទៅនោះចំពោះក្រុមហ៊ុន ។

## មាត្រា ៤៥.–

បុគ្គលណាម្នាក់ដែលធ្វើឱ្យបុគ្គលផ្សេងទៀតជឿទុកចិត្តដោយផ្ទាល់ ឬ ដោយប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែការពិតបុគ្គលនោះមិនមែនជាសហកម្មសិទ្ធិករទូទៅទេ ត្រូវទទួលខុសត្រូវចំពោះតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ ។

ក្នុងករណីមានបុគ្គលក្លែងបន្លំ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនទទួលខុសត្រូវចំពោះតតិយជនណាឡើយ លើកលែងតែក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះមិនបានចាត់វិធានការដើម្បីការពារតតិយជននោះ ក្រោយពេលដែលក្រុមហ៊ុនបានដឹងថាមានការក្លែងបន្លំហើយ ។

## មាត្រា ៤៦.–

សហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលមិនបានប្រកាសចេញមុខដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលស្គាល់ថាជាសហកម្មសិទ្ធិករទូទៅកំបាំងមុខ ។ សហកម្មសិទ្ធិករទូទៅនោះ ត្រូវទទួលខុសត្រូវចំពោះតតិយ

ជនទាំងឡាយនូវរាល់កាតព្វកិច្ច ដូចសហកម្មសិទ្ធិករខ្វះទៅទាំងឡាយដែលបានប្រកាសចេញមុនដែរ ។

**មាត្រា ៤៧.-**

ក្រុមហ៊ុនសហកម្មសិទ្ធិខ្វះទៅមិនអាចបោះចេញ ឬ បែងចែកមូលបត្រ ឬ ប័ណ្ណដែលអាចលក់ដូរបានទៅឱ្យសាធារណជនឡើយ ។

កិច្ចសន្យាដែលចូលជាធរមានទៅក្នុងការបោះចេញមូលបត្រ ឬ ប័ណ្ណដែលធ្វើឡើងផ្ទុយពីមាត្រានេះត្រូវចាត់ទុកជាមោឃៈ ។

ក្រុមហ៊ុនសហកម្មសិទ្ធិខ្វះទៅ ត្រូវសងនូវការខូចខាតទាំងឡាយដែលបង្កឡើងពីមោឃភាពនៃកិច្ចសន្យាមូលបត្រ ឬ ប័ណ្ណទៅឱ្យតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ។

## ឃ- ការអស់សិទ្ធិជាសហកម្មសិទ្ធិករខ្វះទៅ

**មាត្រា ៤៨.-**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករខ្វះទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិខ្វះទៅ នៅពេលដែលបុគ្គលនោះ :

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន
- បានទទួលមរណភាព
- ត្រូវបានដាក់ក្រោមការពិនិត្យអង្កេតពេលក្ស័យធន
- បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ
- ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន
- បានទទួលសាលក្រមតុលាការអនុញ្ញាតឱ្យដកខ្លួនចេញ ឬ បញ្ជាឱ្យរំលាយអង្គសមាសផលប្រយោជន៍របស់បុគ្គលនោះ ។

**មាត្រា ៤៩.-**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បង្កឱ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងពីនេះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់ទុក និងការចុះបញ្ជី ដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ កិច្ចសន្យានោះត្រូវធ្វើការកែប្រែឱ្យស្របតាមនោះដែរ ។

**មាត្រា ៥០.-**

បុគ្គលណាមួយដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រៅពីដោយសារការផ្ទេរ ឬដោយសារការរឹបអូស អត្ថប្រយោជន៍របស់ខ្លួនបុគ្គលនោះអាចទទួលនូវតម្លៃណាមួយនៃអត្ថប្រយោជន៍របស់ខ្លួន អំពីការអស់សិទ្ធិជាសហ-កម្មសិទ្ធិករទូទៅនេះបាន ។ សហកម្មសិទ្ធិករទូទៅដទៃទៀត ត្រូវបង់ការចំណាយជាចាំបាច់ដល់បុគ្គលនោះ នូវតម្លៃណាមួយដែលអាចធ្វើទៅបានដោយឆាប់រហ័សជាមួយនិងការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ ។

តម្លៃនៃអត្ថប្រយោជន៍ត្រូវបានកំណត់ ដូចដែលមានចែងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬកិច្ចសន្យាក្នុងចំណោមសហកម្មសិទ្ធិករទូទៅទាំងឡាយ ។

បើមិនដូច្នោះទេ តម្លៃនោះត្រូវកំណត់ដោយអ្នកឯកទេសដែលបានជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅទាំងឡាយ ឬដោយតុលាការ ។

**មាត្រា ៥១.-**

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលមិនកំណត់ ឬ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលមាន

ចែងអំពីការបម្រុងទុកនូវសិទ្ធិដកខ្លួន សហកម្មសិទ្ធិករទូទៅនោះអាចដកខ្លួនចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន តាមការជូនដំណឹងអំពីការដកខ្លួនដោយសុទ្ធចិត្ត ។

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលកំណត់ អាចដកខ្លួនចេញបាន តែក្នុងករណីមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយ បើមិនដូច្នោះទេលុះត្រាតែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចែងផ្សេងពីនេះ ។

**មាត្រា ៥២.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចបណ្តេញចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវសហកម្មសិទ្ធិករទូទៅ ដែលខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬ ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលមានការជំទាស់ សហកម្មសិទ្ធិករទូទៅទាំងឡាយអាចស្នើសុំការអនុញ្ញាតពីតុលាការ ដើម្បីដកសហកម្មសិទ្ធិករទូទៅនោះចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ តុលាការអាចអនុញ្ញាតនូវការស្នើសុំនោះបាន លុះត្រាតែតុលាការពិចារណាឃើញថាការសុំដកចេញនោះសមស្រប ហើយចេញដីកាផ្អែកទៅតាមកំហុសរបស់សហកម្មសិទ្ធិករទូទៅ ។

## ១_ ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**មាត្រា ៥៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដូចខាងក្រោម :

ក-មូលហេតុដែលមានចែងក្នុងកិច្ចសន្យា

-គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់

-គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត

-តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ

ខ- តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់ ។ នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន ។

**មាត្រា ៥៤.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតឡើងដោយមានកាលកំណត់មួយនៃកិច្ចសន្យា អាចពន្យារបន្តសកម្មភាពរបស់ខ្លួនបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

**មាត្រា ៥៥.-**

ការទទួលដាក់រួមនូវអត្ថប្រយោជន៍ទាំងអស់ទៅក្នុងដៃសហកម្មសិទ្ធិករទូទៅតែម្នាក់ មិនមែនជាមូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ដរាបណាមានបុគ្គលណាមួយផ្សេងទៀតក្លាយជាសហកម្មសិទ្ធិករទូទៅ ក្នុងអំឡុង ១២០ (មួយរយម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃដែលអត្ថប្រយោជន៍នោះដាក់បញ្ចូលគ្នា ។

**មាត្រា ៥៦.-**

សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់ ។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងជាមុនអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ ។

**មាត្រា ៥៧.-**

ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់ទៅនឹងសិទ្ធិតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬ មិនប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

**មាត្រា ៥៨.-**

នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បន្តរហូតដល់ចប់នូវការជម្រះបញ្ជីរបស់ក្រុមហ៊ុននោះ ។

**មាត្រា ៥៩.-**

សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផង ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬ ផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះ ឬ នៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម ។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៦០.-**

នៅពេលធ្វើការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សិទ្ធិក្នុងការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី ។

អ្នកជម្រះបញ្ជីត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ អ្នកជម្រះបញ្ជីត្រូវបានផ្តល់សិទ្ធិពេញលេញក្នុងការចាត់ចែងទាំងមូល ។

អ្នកជម្រះបញ្ជីមានសិទ្ធិទាមទារពីសហកម្មសិទ្ធិករទូទៅទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិ និងកាតព្វកិច្ចនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៦១.-**

អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀតទៅតាមសិទ្ធិបុរិមាជាមុន រួចទើបធ្វើការបែងចែកភាគទុន ។

អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិដែលនៅសេសសល់ ឱ្យទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។

ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិរបស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ ។

**មាត្រា ៦២.-**

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះតម្រូវឱ្យទុកជាភស្តុតាង ។

**មាត្រា ៦៣.-**

ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក ។ ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

## ផ្នែកទី ២
## ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

**មាត្រា ៦៤.-**

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងនិងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬ ច្រើននាក់ ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ ។

**មាត្រា ៦៥.-**

បុគ្គលម្នាក់អាចជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផង នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។

បុគ្គលម្នាក់ដែលជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផងក្នុងពេលតែមួយ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានសិទ្ធិ និងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅ ។

**មាត្រា ៦៦.-**

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ ។ ក្នុងករណីកិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ និងសហកម្មសិទ្ធិករមានកម្រិតយ៉ាងតិចម្នាក់ ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

រយៈពេលនៃកិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនត្រូវលើសកំណត់ ៩៩ (កៅសិបប្រាំបួន) ឆ្នាំឡើយ ប៉ុន្តែអាចពន្យាររពេលបន្តបាន ។

**មាត្រា ៦៧.-**

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបានបង្កើតតាមកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម ស្របទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

ក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនបានចុះបញ្ជីពាណិជ្ជកម្មទេ ក្រុមហ៊ុននោះ ត្រូវបានចាត់ទុកថា ជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ក្នុងករណីនេះ ក្រុមហ៊ុនប្រភេទនេះមិនមាននីតិបុគ្គលិកលក្ខណៈទេ ។

**មាត្រា ៦៨.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចូលឈ្មោះរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ។ នៅខាងក្រោយ ឬ ក្រោមនាមករណ៍នោះ ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវប្រើឈ្មោះនោះក្នុងខណៈដែលខ្លួនធ្វើអាជីវកម្ម ។

**មាត្រា ៦៩.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាទុកនូវកំណត់ហេតុដែលមានឈ្មោះ អាសយដ្ឋានរបស់សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ និងព័ត៌មានដែលទាក់ទងទៅនឹងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាកំណត់ហេតុទុកនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជី ការតម្កល់ទុក និងការផ្សព្វផ្សាយដែលតម្រូវឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះអនុវត្ត ។

**មាត្រា ៧០.-**

ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬ ជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ ។ សហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា ។

ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត ។

**មាត្រា ៧១.-**

សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ មានសិទ្ធិទទួលចំណែកនៃប្រាក់ចំណេញរបស់ខ្លួន ។ ប៉ុន្តែប្រសិនបើការទទួលប្រាក់ចំណេញនោះ នៅតែធ្វើឱ្យមានឱនភាពដល់ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតដែលបានទទួលចំណែកនៃប្រាក់ចំណេញនោះ ត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ដើម្បីទប់ទល់ទៅនឹងឱនភាពភាគទុនរបស់ខ្លួន ។

**មាត្រា ៧២.-**

សហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវទៅលើតែចំនួនទឹកប្រាក់ ឬ តម្លៃនៃទ្រព្យសម្បត្តិដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុនប៉ុណ្ណោះ ។

**មាត្រា ៧៣.-**

សហកម្មសិទ្ធិករមានកម្រិត ដែលមានឈ្មោះនៅក្នុងនាមករណ៍ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដូចជាសហកម្មសិទ្ធិករទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានបញ្ជាក់ច្បាស់លាស់ ។

**មាត្រា ៧៤.-**

សហកម្មសិទ្ធិករទូទៅមានសិទ្ធិនិងកាតព្វកិច្ចដូចជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។ សហកម្មសិទ្ធិករទូទៅ ត្រូវរាយការណ៍ពីការគ្រប់គ្រងដល់សហកម្មសិទ្ធិករមានកម្រិតទាំងឡាយ ។

សហកម្មសិទ្ធិករទូទៅមានកាតព្វកិច្ចទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិសហកម្មសិទ្ធិករមានកម្រិតដទៃទៀត ដែលមាននៅក្នុងដើមទុនរបស់ក្រុមហ៊ុន ។

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអាចជៀសវាងកាតព្វកិច្ចនេះបានទេ ។

**មាត្រា ៧៥.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតចំពោះតតិយជន ។

**មាត្រា ៧៦.-**

សហកម្មសិទ្ធិករមានកម្រិត អាចទទួលប្រាក់បៀវត្សពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន ។

**មាត្រា ៧៧.-**

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតកើតឡើងនៅក្នុងករណីណាក៏ដោយ សហកម្មសិទ្ធិករមានកម្រិតមិនអាចដកចំណែកណាមួយនៃភាគទុនរបស់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ និងក្រោយពីការដកនោះ ទ្រព្យសម្បត្តិដែលនៅសល់ក្នុងក្រុមហ៊ុនមានគ្រប់គ្រាន់ដើម្បីដោះបំណុលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបាន ។

**មាត្រា ៧៨.-**

សហកម្មសិទ្ធិករមានកម្រិតម្នាក់ អាចធ្វើការផ្ទេរអត្ថប្រយោជន៍របស់ខ្លួនបាននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតឡើយ ។

ក្នុងទំនាក់ទំនងទៅនឹងតតិយជន សហកម្មសិទ្ធិករមានកម្រិតដែលបានផ្ទេរអត្ថប្រយោជន៍របស់ខ្លួនរួចមកហើយនោះ នៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលដែលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិត ។

**មាត្រា ៧៩.-**

សហកម្មសិទ្ធិករមានកម្រិតមិនអាចចូលរួមនៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ ។

សហកម្មសិទ្ធិករមានកម្រិតអាចធ្វើការពិនិត្យរបាយការណ៍ និងការរីកចំរើនរបស់ក្រុមហ៊ុន និងអាចផ្តល់ជាគំនិតក្នុងការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបានគ្រប់ដំណាក់កាល ។

សហកម្មសិទ្ធិករមានកម្រិតមិនអនុញ្ញាតឱ្យចរចាក្នុងកិច្ចការពាណិជ្ជកម្មណាមួយក្នុងនាមនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬ មិនអនុញ្ញាតឱ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុននោះឡើយ ។

សហកម្មសិទ្ធិករមានកម្រិតដែលប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចរបស់ក្រុមហ៊ុនដែលកើតឡើងដោយសារការប្រព្រឹត្តទាំងនោះ ។

សហកម្មសិទ្ធិករមានកម្រិត អាចអនុញ្ញាតឱ្យទទួលខុសត្រូវដូចសហកម្មសិទ្ធិករទូទៅដែរ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ប្រសិនបើសកម្មភាពទាំងឡាយដែលបានរៀបរាប់រួចហើយ ឬ សារៈសំខាន់នៃសកម្មភាពទាំងនោះស្របតាមដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយមានភស្តុតាងបញ្ជាក់ថា សហកម្មសិទ្ធិករមានកម្រិតធ្វើសកម្មភាពក្នុងនាមសហកម្មសិទ្ធិករទូទៅពិតប្រាកដមែន ។

**មាត្រា ៨០.-**

នៅពេលសហកម្មសិទ្ធិករទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មតទៅមុខទៀតបានទេ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃដែលជាតម្រូវការក្នុងដំណើរការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅទាំងឡាយ មិនត្រូវបានជំនួសក្នុងរយៈពេល ១២០(មួយរយម្ភៃ)ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនឹងត្រូវបានរំលាយ ។

**មាត្រា ៨១.-**

តតិយជនដែលជាម្ចាស់បំណុលអាចប្តឹងទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនិងពីសហកម្មសិទ្ធិករទូទៅបានដូចគ្នា ដូចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។

**មាត្រា ៨២.-**

នៅពេលណាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនគ្រប់គ្រាន់ទេ សហកម្មសិទ្ធិករទូទៅទាំងឡាយត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះតតិយជននូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ សហកម្មសិទ្ធិករមានកម្រិត ត្រូវទទួលខុសត្រូវនូវបំណុលត្រឹមតែចំនួនភាគទុន ដែលខ្លួនបានព្រមព្រៀងដាក់ជាមួយគ្នា ដោយមិនគិតការផ្ទេរអត្ថប្រយោជន៍ណាមួយរបស់ខ្លួនឡើយ ។

**មាត្រា ៨៣.-**

ក្នុងករណីបំណុលកើនលើសពីដើមទុន ឬ ក្នុងករណីក្ស័យធននៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗដែលជាម្ចាស់បំណុល មិនអាចទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ រហូតដល់ម្ចាស់បំណុលដទៃទៀតនៃក្រុមហ៊ុនមានកម្រិតនេះ ត្រូវបានដោះស្រាយចប់សព្វគ្រប់ ។

**មាត្រា ៨៤.-**

វិធាននៃការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែរ ។

# ជំពូកទី ៣
# ក្រុមហ៊ុនមូលធន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៥.-**

ច្បាប់នេះអនុញ្ញាតឱ្យបង្កើតក្រុមហ៊ុនមូលធន ដែលមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដើម្បីប្រកបពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចបង្កើតឡើងក្រោមច្បាប់នេះក្នុងគោលបំណងធ្វើអាជីវកម្ម ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនឥណទានបានឡើយ ។

**មាត្រា ៨៦.-**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺជាទម្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនហើយត្រូវមានលក្ខណៈសម្គាល់ដូចតទៅ :

ក-ក្រុមហ៊ុនអាចមានសមាជិកភាគហ៊ុនពី ០២(ពីរ)នាក់ រហូតដល់៣០(សាមសិប)នាក់ ។ ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ ដែលមានឈ្មោះថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្តីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុន ។

ខ-ក្រុមហ៊ុននោះមិនអាចអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬ មូលបត្រដទៃទៀតជាសាធារណៈបានឡើយ ។ ប៉ុន្តែអាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុន

សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន ។ ក្នុងករណីផ្ទេរអនុប្បទានទៅឱ្យតតិយជនត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀតតាមសំឡេងភាគច្រើន ។

គ-ក្រុមហ៊ុននោះអាចមានការរឹតត្បិតមួយ ឬ ច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់ ។

ឃ-ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៨៧.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន ។

**មាត្រា ៨៨.-**

នៅក្នុងជំពូកនេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-លក្ខន្តិកៈ មានន័យថាលក្ខន្តិកៈដើម ឬ លក្ខន្តិកៈធ្វើការកែប្រែ ។

២-សវនករ មានន័យថាគណនេយ្យករជំនាញម្នាក់ដែលធ្វើកិច្ចការក្នុងលក្ខណៈជាបុគ្គល ឬ ធ្វើកិច្ចការក្នុងក្រុមហ៊ុនគណនេយ្យណាមួយ ។

៣-កាតព្វកិច្ចបំណុលគឺជាសញ្ញាប័ណ្ណ ឬ ជាលិខិតបញ្ជាក់បំណុលផ្សេងៗ ឬ លិខិតស្នាមរបស់ក្រុមហ៊ុនដែលអាចធានា ឬ មិនអាចធានាបាន ។

៤-មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមានន័យថាមន្ត្រីដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដើម្បីអនុវត្តការងារនៃច្បាប់នេះ ។

៥-អភិបាលមានន័យថាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ។

៦-ស្ថាបនិកក្រុមហ៊ុនមានន័យថារូបវន្តបុគ្គលដែលចុះហត្ថលេខាលើ

លក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៧-សេចក្តីសម្រេចសាមញ្ញមានន័យថាជាសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើនដាច់ខាតដែលបានចូលរួមក្នុងការបោះឆ្នោត ។

៨-ភាគហ៊ុនអាចវិលោះបានមានន័យថាជាភាគហ៊ុនដែលត្រូវបានចេញដោយក្រុមហ៊ុនណាមួយ :

-ក្រុមហ៊ុននោះអាចទិញ ឬ វិលោះបានទៅតាមតម្រូវការរបស់ក្រុមហ៊ុន

-ក្រុមហ៊ុននោះត្រូវបានតម្រូវឱ្យដោយលក្ខន្តិកៈរបស់ខ្លួនដើម្បីទិញ ឬវិលោះនៅពេលកំណត់ណាមួយ ឬ ក៏ទៅតាមតម្រូវការរបស់ម្ចាស់ហ៊ុនណាម្នាក់ ។

៩-ស៊េរីនៅក្នុងទំនាក់ទំនងទៅនឹងភាគហ៊ុនមានន័យថាជាការបែងចែកចំណាត់ថ្នាក់ភាគហ៊ុនឱ្យទៅជាប្រភេទភាគហ៊ុននីមួយៗ ។

១០-សេចក្តីសម្រេចពិសេសមានន័យថាជាសេចក្តីសម្រេចមួយត្រូវធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើន ២/៣ (ពីរភាគបី) ដែលបានចូលរួមក្នុងការបោះឆ្នោត ឬ ពីការចុះហត្ថលេខារបស់សមាជិកភាគហ៊ុនទាំងឡាយ ដែលមានសិទ្ធិក្នុងការបោះឆ្នោតធ្វើសេចក្តីសម្រេចនោះ ។

១១-មូលបត្រមានន័យថា :

ក-ជាភាគហ៊ុននៅក្នុងស៊េរីនៃភាគហ៊ុនណាមួយ ឬ ជាភាគហ៊ុននៅក្នុងប្រភេទនៃភាគហ៊ុនណាមួយ ។

ខ-សញ្ញាប័ណ្ណ ។

គ-រួមបញ្ចូលទាំងវិញ្ញាបនបត្របញ្ជាក់ដែលផ្តល់ភស្តុតាងអំពីមូលបត្រទាំងឡាយ ។

**មាត្រា ៨៩.-**

ក្រុមហ៊ុនពាណិជ្ជកម្មមួយអាចធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយទៀតបាន ប្រសិនបើក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុននោះ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនផ្សេង ឬ ក្រុមហ៊ុនទាំងពីរជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនតែមួយដូចគ្នា ឬ ក្រុមហ៊ុននីមួយៗត្រូវគ្រប់គ្រងដោយបុគ្គលតែមួយរូបដូចគ្នា ។

ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មពីរ ធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនមួយដូចគ្នា នៅក្នុងពេលតែមួយ ក្រុមហ៊ុនទាំងនោះត្រូវចាត់ទុកថាជាក្រុមហ៊ុនដែលមានទំនាក់ទំនងធ្វើសម្ព័ន្ធភាពជាមួយគ្នា ។

**មាត្រា ៩០.-**

ស្ថាបនិក ឬ អភិបាលម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តនូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងការផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់ ។

## ផ្នែកទី ២
## ក- ការបង្កើតក្រុមហ៊ុនមូលធន

**មាត្រា ៩១.-**

នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬ ច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៩២.-**

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬ សរសេរអក្សរកាត់ដាក់ខាងចុង ឬខាងក្រោម ។

នាមករណីរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬ សរសេរអក្សរកាត់ដាក់ខាងចុង ឬ ខាងក្រោម ។

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យនូវនាមករណី ដែលបានស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធនូវនាមករណីណាដែលប្រហាក់ប្រហែលគ្នាធ្វើឱ្យមានការភាន់ច្រឡំទៅនឹងនាមករណីរបស់ក្រុមហ៊ុនផ្សេងទៀត ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនរួចហើយ ឬ នាមករណីមួយដែលផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈដែលមានឈ្មោះអាស្រូវ ឬ ដែលមិនសមរម្យ ។ សេចក្តីសម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដែលពាក់ព័ន្ធទៅនឹងនាមករណីរបស់ក្រុមហ៊ុនគឺជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា ៩៣.–**

លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងនូវលក្ខខណ្ឌដូចខាងក្រោម :

ក-នាមករណីរបស់ក្រុមហ៊ុន ។

ខ-ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ-កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះធ្វើពាណិជ្ជកិច្ច ។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬ ច្រើនប្រភេទដែលមិនផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់ ។

ឃ-ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ ។

ង-ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឱ្យបោះចេញដោយក្រុមហ៊ុននោះ ។

ច-ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឱ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ ។

ឆ-ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាសេរី លក្ខន្តិកៈក្រុមហ៊ុននោះត្រូវអនុញ្ញាតឱ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃសេរីនីមួយៗ ដើម្បីកំណត់ឬបំបែងចែកសេរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងសេរីនីមួយៗនោះ ។

ជ-ក្នុងករណីការបោះចេញ ការផ្ទេរ ឬការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធភាព និងមានរបាយការណ៍ពីការកម្រិតនោះ ។

ឈ-ឈ្មោះនិងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ ។

ញ- ចំនួនអភិបាល ឬ ចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ ។

**មាត្រា ៩៤.–**

លក្ខន្តិកៈត្រូវរួមបញ្ចូលផងដែរ នូវរាល់ចំណុចផ្សេងទៀតតាមការចាំបាច់ ។

**មាត្រា ៩៥.–**

លក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតរវាងឯកជន ឬជាលិខិតសារការី ។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬ ហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ ។

**មាត្រា ៩៦.–**

ស្ថាបនិកក្រុមហ៊ុន ត្រូវស្នើសុំទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការតម្កល់លក្ខន្តិកៈនោះជាមួយឯកសារសុំចុះបញ្ជីពាណិជ្ជកម្មផ្សេងទៀត ។

**មាត្រា ៩៧.-**

ក្រោយពីការយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់នោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញនូវលិខិតបញ្ជាក់មួយជាសម្គាល់ ។

**មាត្រា ៩៨.-**

ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

## ខ- សមត្ថភាព និងសិទ្ធិរបស់ក្រុមហ៊ុន

**មាត្រា ៩៩.-**

ក្រុមហ៊ុនដែលបានបង្កើតឡើងតាមច្បាប់នេះមានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ ។

ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជាបាន ។

**មាត្រា ១០០.-**

ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចរបស់ខ្លួនធ្វើកិច្ចការរបស់ខ្លួន និងអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងដែនសមត្ថកិច្ចនៃប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែច្បាប់នៃប្រទេសនោះបានអនុញ្ញាត ។

**មាត្រា ១០១.-**

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរ លុះត្រាតែ :

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១ (ហាសិបមួយ) ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ។

**មាត្រា ១០២.-**

ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវ-កម្មរបស់ក្រុមហ៊ុន ។

មិនចាំបាច់មានបទបញ្ជាផ្ទៃក្នុងមួយ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុន និងអភិបាលក្រុមហ៊ុន ។

**មាត្រា ១០៣.-**

ក្រុមហ៊ុនមិនត្រូវប្រកបពាណិជ្ជកិច្ចណាមួយ ឬ អនុវត្តសិទ្ធិណាមួយ ដែលលក្ខន្តិកៈរបស់ខ្លួនបានហាមឃាត់ ឬ មិនត្រូវអនុវត្តសិទ្ធិណាមួយដែលផ្ទុយពីលក្ខន្តិកៈរបស់ខ្លួនឡើយ ។

**មាត្រា ១០៤.-**

ប្រការដែលក្រុមហ៊ុនបានប្រព្រឹត្តរំលោភលើលក្ខន្តិកៈរបស់ខ្លួន មិនធ្វើឱ្យមានមោឃភាពដល់ការប្រព្រឹត្តនោះឡើយ ។ វិធាននេះអនុវត្តចំពោះគ្រប់ការប្រព្រឹត្ត រួមមានការផ្ទេរទ្រព្យសម្បត្តិទៅឱ្យក្រុមហ៊ុន ឬ ការផ្ទេរទ្រព្យសម្បត្តិពីក្រុមហ៊ុន ។

**មាត្រា ១០៥.-**

ប្រការដែលមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មតម្កល់ទុកឯកសាររបស់ក្រុមហ៊ុន ឬ ប្រការដែលឯកសារសម្រាប់ធ្វើអធិការកិច្ច ដែលថតចម្លងទុកនៅក្នុងការិយាល័យក្រុមហ៊ុនមិនត្រូវបានចាត់ទុកថាធ្វើឱ្យប៉ះពាល់ទៅលើបុគ្គលណាមួយ ឬ ជាការជូនដំណឹងដល់បុគ្គលណាមួយឡើយ ។

**មាត្រា ១០៦.-**

ក្រុមហ៊ុន ឬ បុគ្គលម្នាក់ដែលធានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោមជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជនដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះ ឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបាន



ស

ឡើយ ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ ឬ បានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួន ឬ ដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ :

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម ។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ ។

គ- ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំង ឬ មិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្ត និងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬ ភ្នាក់ងារណាម្នាក់របស់ក្រុមហ៊ុនមិនមានសុពលភាព ឬ មិនយកជាការបានឡើយ ។

ច-ប្រាក់ខ្ចី និង ការធានា ឬ ការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ ។

## គ_ ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និង កំណត់ហេតុ

**មាត្រា ១០៧.-**

នៅគ្រប់ពេលវេលា ក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានបញ្ជាក់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

**មាត្រា ១០៨.–**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវសេចក្តីជូនដំណឹងអំពីទីតាំង ទីស្នាក់ការចុះបញ្ជីជាមួយគ្នា និងលក្ខន្តិកៈដែលស្តីពីទីតាំង ឬ ពីការផ្លាស់ប្តូរទីតាំងស្នាក់ការចុះបញ្ជីនោះ ។

លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជី ត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ ។

**មាត្រា ១០៩.–**

ក្រុមហ៊ុនត្រូវរៀបចំនិងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួននូវ :

ក- លក្ខន្តិកៈ និងគ្រប់ការកែប្រែទាំងអស់ ។

ខ- កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ហ៊ុន ។

គ- ឯកសារនៃសេចក្តីជូនដំណឹងតម្រូវឱ្យធ្វើ ឬ តម្កល់ទុកជាឯកសារ ។

ឃ- បញ្ជីមូលបត្រ ។

**មាត្រា ១១០.–**

ម្ចាស់ហ៊ុន និងម្ចាស់បំណុលរបស់ក្រុមហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចពិនិត្យគ្រប់ឯកសារដូចដែលបានចែង នៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើសម្រង់បានដោយមិនគិតកម្រៃ ។

ប្រសិនបើក្រុមហ៊ុន ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាចធ្វើសម្រង់លើគ្រប់ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប ។

**មាត្រា ១១១.–**

រាល់បញ្ជីឈ្មោះម្ចាស់ហ៊ុន មិនត្រូវបានប្រើដោយបុគ្គលណាម្នាក់ឡើយ លើកលែងតែបុគ្គលនោះមានការពាក់ព័ន្ធជាមួយ :

ក-ការខិតខំប្រឹងប្រែងដើម្បីរកសំឡេងគាំទ្រក្នុងការបោះឆ្នោតពីម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

ខ-ការផ្តល់សំណើទិញភាគហ៊ុនរបស់ក្រុមហ៊ុន ។

គ-អ្វីផ្សេងៗទៀត ដែលទាក់ទងទៅនឹងការងាររបស់ក្រុមហ៊ុន ។

**មាត្រា ១១២.-**

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងឡាយ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិបាលឱ្យបានសព្វគ្រប់ ។

កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល ត្រូវរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬ នៅកន្លែងដទៃទៀត ដែលអភិបាលយល់ឃើញថាសមស្របហើយឯកសារទាំងនោះត្រូវបានបើកចំហ ដើម្បីឱ្យអភិបាលធ្វើការពិនិត្យបានគ្រប់ពេល ។

**មាត្រា ១១៣.-**

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់សម្រាប់រយៈពេល ១០(ដប់)ឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ។

ប្រសិនបើបញ្ជីគណនេយ្យត្រូវរក្សាទុកនៅក្រៅព្រះរាជាណាចក្រកម្ពុជា ឯកសារច្បាប់ចម្លងនៃបញ្ជីគណនេយ្យនោះ ក៏ត្រូវបានរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីផងដែរ ។

**មាត្រា ១១៤.-**

ក្រុមហ៊ុន និងភ្នាក់ងាររបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកសៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទៀងទាត់ និងការពារឱ្យបានត្រឹមត្រូវ ។

**មាត្រា ១១៥.-**

លិខិតស្នាម ឬ កិច្ចសន្យា ដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់ ឬ ភ្នាក់ងារម្នាក់របស់ក្រុមហ៊ុនមានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ ។

## ឃ- អភិបាល និង អ្នកគ្រប់គ្រងក្រុមហ៊ុន

**មាត្រា ១១៦.-**

នៅពេលតម្កល់ទុកឯកសារ និងលក្ខន្តិកៈការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ស្ថាប-និកទាំងឡាយត្រូវផ្តល់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងរបស់អភិបាល ទៅតាមបែបបទដែលបានកំណត់ដោយក្រសួងពាណិ-ជ្ជកម្ម ។

ក្រោយពីចេញវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ស្ថាបនិកម្នាក់ ឬ អភិ-បាលម្នាក់អាចកោះប្រជុំក្រុមប្រឹក្សាភិបាលបានដោយផ្តល់ការជូនដំណឹងយ៉ាងតិច ០៥ (ប្រាំ)ថ្ងៃ តាមរយៈលិខិតទៅគ្រប់អភិបាល ។ លិខិតជូនដំណឹងនោះ មានបញ្ជាក់ពីពេលវេលា និងទីកន្លែងប្រជុំផង ។

អភិបាលដំបូងត្រូវកាន់តំណែង ចាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកទីមួយ ។

**មាត្រា ១១៧.-**

ក្រុមប្រឹក្សាភិបាលដំបូងទាំងឡាយ ត្រូវចាត់ចែងមហាសន្និបាតលើកទី ១ របស់ម្ចាស់ហ៊ុនក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីក្រុមហ៊ុនបានបង្កើតឡើង ។ លិខិតជូនដំណឹងពីមហាសន្និបាតនោះ ត្រូវចែកយ៉ាងហោចណាស់ ២០ (ម្ភៃ)ថ្ងៃ មុនទៅបុគ្គលដែលមានសិទ្ធិចូលរួមមហាសន្និបាតនោះ ។ លិខិតជូនដំណឹងត្រូវបញ្ជាក់អំពីកាលបរិច្ឆេទទីកន្លែង និងរបៀបវារៈនៃមហាសន្និបាតនោះ ។

**មាត្រា ១១៨.-**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬ ច្រើននាក់ ។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលយ៉ាងតិច ០៣(បី) នាក់ ។

ម្ចាស់ហ៊ុន ត្រូវបោះឆ្នោតជ្រើសរើសអភិបាល តាមរយៈសេចក្ដីសម្រេចសាមញ្ញនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ។

**មាត្រា ១១៩.-**

ក្រុមប្រឹក្សាភិបាលត្រូវចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។ លក្ខន្តិកៈក្រុមហ៊ុនត្រូវចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ :

១-តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២-កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣-កម្រិតប្រាក់បៀវត្ស ឬ ប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំសេចក្ដីសម្រេច ។

៤-ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាម ដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនោះ ។

៥-ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬ លុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦-ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬ រួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧-ស្នើសុំម្ចាស់ហ៊ុនដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ឬមួយភាគ ។

៨-ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

៩-ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ ។

១០-ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

១១-ខ្ចីប្រាក់ ។

១២- បោះចេញ បោះចេញសាជាថ្មី ឬ លក់មូលបត្ររបស់ក្រុមហ៊ុន ។

១៣-ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន ។

១៤-ធ្វើអ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥-រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន ។

**មាត្រា ១២០.-**

រាល់រូបវន្តបុគ្គល ដែលមានសមត្ថភាពមានអាយុលើសពី ១៨ (ដប់ប្រាំបី)ឆ្នាំ អាចបម្រើការងារជាអភិបាល ឬ ជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន ។ អភិបាលមិនចាំបាច់ជាម្ចាស់ហ៊ុនទេ ឬ មិនចាំបាច់តម្រូវឱ្យមានលក្ខណសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវ ។

**មាត្រា ១២១.-**

ក្នុងករណីលក្ខន្តិកៈក្រុមហ៊ុនមិនចែងអំពីអាណត្តិទេ អភិបាលម្នាក់ៗត្រូវមានអាណត្តិ ០២(ពីរ)ឆ្នាំ ហើយអាចត្រូវបោះឆ្នោតឱ្យសាជាថ្មីទៀតបាន ។

**មាត្រា ១២២.-**

អាណត្តិរបស់អភិបាល អាចត្រូវកំណត់ជាតំណាក់ៗ តែអាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំជាមួយគ្នាបានឡើយ ។

**មាត្រា ១២៣.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចចែងបានផងដែរពីសិទ្ធិរបស់អ្នកកាន់ប័ណ្ណភាគហ៊ុននៃប្រភេទនីមួយៗ ដើម្បីបោះឆ្នោតជ្រើសរើសអភិបាលមួយ ឬ ច្រើន ដែលអភិបាលនោះបម្រើអាណត្តិ និងមានសិទ្ធិចាត់ចែងការងារផ្សេងៗ ដែលបានចែងក្នុងលក្ខន្តិកៈ ។ អាណត្តិនៃមុខតំណែង និង សិទ្ធិនៃការបោះឆ្នោតរបស់អភិបាលប្រភេទមួយអាចច្រើនជាង ឬ តិចជាងអភិបាលប្រភេទមួយផ្សេងទៀតបាន ។

**មាត្រា ១២៤.-**

អភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបានដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ ។

**មាត្រា ១២៥.-**

អភិបាលអាចលាលែងពីមុខតំណែងនៅពេលណាក៏បានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន ។ ការលាលែងពីមុខតំណែងនេះ ត្រូវមានសុពលភាពភ្លាមៗ ឬ មានប្រសិទ្ធភាពចាប់ពីពេលដែលបានចែងនៅក្នុងលិខិតជូនដំណឹងនោះ ។

អភិបាលម្នាក់ ដែលជាអភិបាលនៅសល់ចុងក្រោយក្នុងក្រុមហ៊ុន ហើយអភិបាលនោះធ្វើការលាលែងមុនពេលអភិបាលផ្សេងត្រូវបានតែងតាំង ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានបង្កឡើងដល់ក្រុមហ៊ុនដោយសារការលាលែងរបស់ខ្លួន ។

**មាត្រា ១២៦.-**

បន្ទាប់ពីអាណត្តិរបស់ខ្លួនបានផុតកំណត់ អភិបាលត្រូវបន្តបម្រើការងាររបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងជំនួសជាថ្មី ។

### មាត្រា ១២៧.–

ក្រុមប្រឹក្សាភិបាល ត្រូវបោះឆ្នោតជ្រើសតាំងប្រធានពីក្នុងចំណោមសមាជិករបស់ខ្លួន ។ ប្រធានក្រុមប្រឹក្សាភិបាលអាចត្រូវដកហូតពីមុខតំណែងដោយសំឡេងភាគច្រើនដាច់ខាតរបស់អភិបាលទាំងឡាយ ប៉ុន្តែមិនត្រូវបានដកហូតពីឋានៈអភិបាលឡើយ ។

### មាត្រា ១២៨.–

ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិអញ្ជើញអភិបាលប្រជុំ ។ មួយភាគបីនៃសមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការងារក៏អាចអញ្ជើញក្រុមប្រឹក្សាភិបាលប្រជុំបានដែរ ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់បីខែ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលយកជាបានការ លុះត្រាតែមានសំឡេងភាគច្រើនដោយប្រៀបរបស់សមាជិក ឬ តំណាងដែលមានវត្តមាន ។

### មាត្រា ១២៩.–

ក្រុមប្រឹក្សាភិបាលអាចជួបប្រជុំនៅកន្លែងណាមួយទៅតាមលិខិតជូនដំណឹង ។ លិខិតជូនដំណឹងត្រូវបញ្ជាក់ផងដែរពីកាលបរិច្ឆេទ និងរបៀបវារៈពិស្តារ ។

អភិបាលអាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូនដំណឹងពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ប៉ុន្តែនៅពេលចូលរួមប្រជុំ អភិបាលនោះអាចធ្វើការជំទាស់ទៅនឹងពាណិជ្ជកិច្ចណាមួយបាន ដោយសំអាងថាការប្រជុំនោះមិនបានកោះហៅត្រឹមត្រូវតាមច្បាប់កំណត់ ។

### មាត្រា ១៣០.–

អភិបាលអាចធ្វើសកម្មភាពបានតាមរយៈការទាក់ទងគ្នាជាលិខិត លើកលែងតែលក្ខន្តិកៈចែងផ្សេង ។

រាល់អភិបាលត្រូវទទួលសំណុំរឿងនៃសេចក្តីសម្រេចដែលត្រូវស្នើសុំការពិនិត្យ និងការសម្រេចគាំទ្រ ឬ មិនគាំទ្រ ព្រមទាំងសន្លឹកឆ្នោតសម្រាប់បោះ "ព្រម" ឬ "មិនព្រម" ចំពោះប្រធានបទនោះ ។

ក្នុងករណីដែលអភិបាលទាំងអស់ បោះឆ្នោតអនុម័តលើប្រធានបទមួយ ប្រធានបទនោះត្រូវចាត់ទុកថាមានការអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ការឆ្លើយតបជាលិខិតត្រូវចូលជាផ្នែកមួយនៃកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាល ។ លេខាធិការរបស់ក្រុមហ៊ុន ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរពីការប្រាស្រ័យទាក់ទងគ្នាជាលិខិតនោះ និងត្រូវចែករបាយការណ៍នេះទៅអភិបាលទាំងអស់ ។

**មាត្រា ១៣១.-**

ដើម្បីសម្រួលការងាររបស់ខ្លួនក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗបានតាមការចាំបាច់ ។ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល អាចត្រូវបង្កើតឡើងដោយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការនីមួយៗត្រូវមានអភិបាលមួយរូប ឬ ច្រើនរូបដែលត្រូវតែងតាំងដោយសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការត្រូវអនុវត្តកិច្ចប្រជុំរបស់ខ្លួនតាមវិធីដូចគ្នានឹងក្រុមប្រឹក្សាភិបាលដែរ ។ គណៈកម្មាធិការនីមួយៗ ត្រូវមានសិទ្ធិដែលបានផ្តល់ឱ្យដោយឯកសារជាលាយលក្ខណ៍អក្សរដែលបានបង្កើតគណៈកម្មាធិការនោះ ។ ប៉ុន្តែគណៈកម្មាធិការមួយមិនអាចត្រូវបានគេផ្ទេរអំណាចណាមួយដើម្បីធ្វើសកម្មភាពដូចតទៅនេះទេ :

ក-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ខ-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើកិច្ចសន្យាវិលាយក្រុមហ៊ុនបញ្ចូលគ្នា ឬ ការរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលណាមួយផ្សេង ។

គ-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមួយភាគ ឬទាំងអស់ ។

ឃ-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

ង-ប្រកាសភាគលាភ ។

ច-បោះចេញនូវប័ណ្ណភាគហ៊ុននៅក្នុងក្រុមហ៊ុន ។

**មាត្រា ១៣២.-**

ចំនួនភាគច្រើននៃអភិបាលទាំងអស់ ដែលមានវត្តមាននៅក្នុងពេលប្រជុំបង្កើតបានជាកូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល ឬរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលនោះ ប៉ុន្តែលក្ខន្តិកៈរបស់ក្រុមហ៊ុនអាចតម្រូវឱ្យកូរ៉ុមមានចំនួនច្រើនជាងនេះបាន ។

អភិបាលម្នាក់ ត្រូវមានសំឡេងឆ្នោតតែមួយ ។ អភិបាលអាចធ្វើជាអាណត្តិគាហកៈឱ្យអភិបាលមួយរូបផ្សេងទៀតបាន នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាដោយអភិបាលដែលខ្លួនធ្វើតំណាងឱ្យ ។

លេខាធិការត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាភិបាល ហើយត្រូវផ្ញើឯកសារថតចម្លងនៃកំណត់ហេតុនេះ ទៅឱ្យអភិបាលទាំងអស់ ។

**មាត្រា ១៣៣.-**

ក្រុមហ៊ុនអាចចេញសងការចំណាយដល់អភិបាលបច្ចុប្បន្ន ឬអភិបាលពីមុន អ្នកគ្រប់គ្រង ឬ បុគ្គលិករបស់ក្រុមហ៊ុនក្នុងការបំពេញភារកិច្ចដែលបានអនុវត្តដោយស្មោះត្រង់ និងសមហេតុសមផល ។

ការចេញសងត្រូវធ្វើឡើងនៅពេលដែលអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកបានសំអាងក្នុងឆន្ទៈល្អនៅលើកំណត់ហេតុ ឬ សៀវភៅបញ្ជី ដែលមានភាពត្រឹមត្រូវរបស់ក្រុមហ៊ុន ឬ នៅលើព័ត៌មានមតិយោបល់របាយការណ៍ផ្សេងៗ ឬរបាយការណ៍ ដែលបង្ហាញដោយអ្នកគ្រប់គ្រងណាម្នាក់របស់ក្រុមហ៊ុននោះ ឬ ជនណាម្នាក់ផ្សេងអំពីបុគ្គលទាំងនោះ ។

ការចេញសងត្រូវបានអនុវត្តចំពោះតែការចំណាយ ឬ ការខូចខាតសមហេតុសមផលដែលទទួលរងដោយអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកនៅពេលបម្រើការងារឱ្យក្រុមហ៊ុនប៉ុណ្ណោះ ។

**មាត្រា ១៣៤.-**

អភិបាល ឬ អ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវបង្ហាញនូវទំហំផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅឱ្យក្រុមហ៊ុន ឬ ស្នើឱ្យមានសេចក្ដីប្រកាស ដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងករណី :

ក-ដែលខ្លួនជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

ខ-ដែលខ្លួនមានអត្ថប្រយោជន៍ជាមួយបុគ្គលណាម្នាក់ ដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

**មាត្រា ១៣៥.-**

ក្នុងករណីជាអភិបាល ការបង្ហាញត្រូវធ្វើឡើង :

ក-នៅពេលប្រជុំ កិច្ចសន្យាដែលបានស្នើឡើងត្រូវពិចារណាជាលើកទីមួយ ។

ខ-នៅពេលប្រជុំលើកិច្ចសន្យា អភិបាលនោះមិនបានបង្ហាញថាមានការពាក់ព័ន្ធផលប្រយោជន៍ទេ ប៉ុន្តែក្រោយមកគាត់បានបញ្ជាក់ថាមានការពាក់ព័ន្ធ ។

គ-នៅក្រោយពេលកិច្ចសន្យាត្រូវបានធ្វើឡើង ហើយក្រោយមកអភិបាលនោះ បានបង្ហាញប្រាប់ថាមានការពាក់ព័ន្ធដល់ផលប្រយោជន៍របស់ខ្លួន ។

ឃ- ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអភិបាល ។

**មាត្រា ១៣៦.-**

ក្នុងករណីជាអ្នកគ្រប់គ្រងក្រុមហ៊ុន ការបង្ហាញត្រូវធ្វើឡើង :

ក-ក្រោយពីអ្នកគ្រប់គ្រងនោះ នឹងភ្ញាមថាកិច្ចសន្យា ឬ កិច្ចសន្យាដែលបានដាក់ស្នើសុំនោះត្រូវសម្រេច ឬ ត្រូវបានសម្រេចរួចហើយ នៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ។

ខ-ប្រសិនបើអ្នកគ្រប់គ្រងនោះ បានបកស្រាយបង្ហាញមុនពេលដែលកិច្ចសន្យានោះបានធ្វើរួចរាល់ ។

គ-ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ ។

**មាត្រា ១៣៧.-**

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចណាមួយក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជា :

ក-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចី ឬកាតព្វកិច្ចទាំងឡាយ ដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុន ឬ ដល់សាខាមួយរបស់ក្រុមហ៊ុន ។

ខ-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួនដែលជាអភិបាល អ្នកគ្រប់គ្រង បុគ្គលិកភ្នាក់ងាររបស់ក្រុមហ៊ុន ឬ សាខាមួយរបស់ក្រុមហ៊ុន ។

គ-កិច្ចសន្យាមួយធ្វើឡើងជាការភ្ជាប់រងសងការខូចខាត ឬជាការធានា ។

ឃ-កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ ។

**មាត្រា ១៣៨.-**

លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនអាចមានចែង :

ក-ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមានសិទ្ធិចាត់ចែងការិយាល័យរបស់ក្រុម

ហ៊ុន តែងតាំងអ្នកគ្រប់គ្រងក្រុមហ៊ុន កំណត់តួនាទីភារកិច្ចនិងសិទ្ធិរបស់អ្នកទាំងនោះឱ្យ បានច្បាស់លាស់ ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។

ខ-អភិបាលអាចត្រូវបានតែងតាំងឱ្យគ្រប់គ្រងការិយាល័យណាមួយរបស់ក្រុមហ៊ុន ។

គ-បុគ្គលម្នាក់អាចរៀបចំគ្រប់គ្រងការិយាល័យមួយ ឬ ច្រើនរបស់ក្រុមហ៊ុនបាន ។

**មាត្រា ១៣៩.-**

បុគ្គលម្នាក់ៗដែលបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងនាម ឬតំណាងឱ្យក្រុមហ៊ុនមុនពេលក្រុមហ៊ុននោះមានអត្ថិភាព ឬ បុគ្គលនោះត្រូវជាប់កាតព្វកិច្ចដោយផ្ទាល់នៅក្នុងកិច្ចសន្យានោះ និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍នោះដែរ ។

ក្រោយពីកិច្ចសន្យាមួយ បានបង្កើតឡើងក្នុងពេលវេលាមួយសមស្រប ក្រុមហ៊ុនអាចទទួលយកបាននូវកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះ ដែលបានធ្វើឡើងមុនពេលក្រុមហ៊ុនមានអត្ថិភាព និងមុនការទទួលយល់ព្រមនៅក្នុងក្រុមហ៊ុន ។ ការទទួលនេះផ្អែកលើសកម្មភាព ឬ ការប្រព្រឹត្តដែលផ្តោតទៅលើគោលបំណងដ៏សំខាន់នៃកិច្ចសន្យាដែលបានជាប់កាតព្វកិច្ចរួចមកហើយនោះ ។

ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចដោយកិច្ចសន្យា ហើយមានសិទ្ធិក្នុងការទទួលផលប្រយោជន៍ដូចពេលដែលក្រុមហ៊ុនមានអត្ថិភាព ចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា និងដូចពេលដែលក្រុមហ៊ុននោះជាចំណែកមួយនៃកិច្ចសន្យា ។

បុគ្គលម្នាក់ដែលប្តឹងទាមទារថាបានអនុវត្តក្នុងនាម ឬ តំណាងឱ្យក្រុមហ៊ុនមានកាតព្វកិច្ច ឬ មានសិទ្ធិទទួលផលប្រយោជន៍នៅក្នុងកិច្ចសន្យាបាន លុះត្រាតែមានដីកាសម្រេចរបស់តុលាការ ។

**មាត្រា ១៤០.-**

អភិបាលដែលបោះឆ្នោតឱ្យ ឬ យល់ព្រមក្នុងការធ្វើសេចក្តីសម្រេចលើការអនុញ្ញាតឱ្យចេញប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូល ដែលមិនមែនជាសាច់ប្រាក់ទេត្រូវ



ល

ទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះក្រុមហ៊ុនទៅតាមចំនួនតម្លៃសមមូលដែលបានទទួល ដែលតិចជាងតម្លៃត្រឹមត្រូវជាសាច់ប្រាក់ ដែលក្រុមហ៊ុនបានទទួល ប្រសិនបើប័ណ្ណភាគហ៊ុនដែលបានបោះចេញនោះសម្រាប់លក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច ។

អភិបាលមិនទទួលខុសត្រូវទេ ប្រសិនបើអភិបាលនោះបង្ហាញថាមិនបានដឹងថាភាគហ៊ុនដែលបោះចេញសម្រាប់តម្លៃសមមូល ដែលតិចជាងសាច់ប្រាក់ ដែលក្រុមហ៊ុនអាចនឹងទទួលប្រសិនបើប័ណ្ណភាគហ៊ុននោះ ដែលបានបោះចេញសម្រាប់លក់យកជាប្រាក់ ។

សកម្មភាពក្នុងការអនុវត្តនូវការទទួលខុសត្រូវបំណុល ដែលតម្រូវដោយច្បាប់នេះមិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ)ឆ្នាំ បានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

**មាត្រា ១៤១.-**

អភិបាលដែលបានបោះឆ្នោតឱ្យ ឬ យល់ព្រមចំពោះសេចក្តីសម្រេចដែលអនុញ្ញាតឱ្យមានការទិញមកវិញនូវភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានលក់កន្លងមក ឬធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬ ធ្វើការចែកភាគលាភដែលផ្ទុយពីបទប្បញ្ញត្តិនៃជំពូកនេះត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវរាល់ចំនួនដែលបានបែងចែក ឬ បានបង់ហើយ ដើម្បីស្តារក្រុមហ៊ុនឡើងវិញ ។

សកម្មភាពដើម្បីអនុវត្តការទទួលខុសត្រូវដែលតម្រូវដោយមាត្រានេះ មិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំ បានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

**មាត្រា ១៤២.-**

អភិបាលម្នាក់ ដែលមានវត្តមាននៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលត្រូវចាត់ទុកថាបានយល់ព្រមនូវរាល់សេចក្តីសម្រេចដែលបានអនុម័ត ឬ សកម្មភាពដែលបានធ្វើឡើងនៅក្នុងមហាសន្និបាតលើកលែងតែ :

១-អភិបាលនោះមានការជំទាស់ ដែលស្នើដាក់ចូលក្នុងកំណត់ហេតុអង្គប្រជុំនៃមហាសន្និបាតនោះ ។

២-អភិបាលនោះ ផ្ញើគំនិតជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅលេខាធិការរបស់មហាសន្និបាត មុនពេលបិទមហាសន្និបាតនោះ ។

អភិបាលដែលអវត្តមាននៅក្នុងមហាសន្និបាត នៅពេលសេចក្តីសម្រេចដែលត្រូវអនុម័ត ឬសកម្មភាពដែលបានធ្វើឡើងរួចមកហើយគឺចាត់ទុកថាបានយល់ព្រម លើកលែងតែក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃ ក្រោយពីបានដឹងសេចក្តីសម្រេចនោះ អភិបាលនោះបាន :

១-បង្ហាញមូលហេតុនៃការជំទាស់របស់គាត់ ដែលបានបញ្ចូលទៅក្នុងកំណត់ហេតុនៃមហាសន្និបាត ។

២-ផ្ញើគំនិតជំទាស់របស់ខ្លួនតាមរយៈលិខិតអនុសិដ្ឋ ឬ យកទៅប្រគល់ផ្ទាល់នៅឯការិយាល័យរបស់ក្រុមហ៊ុន ។

## ខ_ ភាគហ៊ុន និង ភាគលាភ

### មាត្រា ១៤៣._

ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់ ។ ភាគហ៊ុននីមួយៗ ត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើប័ណ្ណនោះទេ ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

### មាត្រា ១៤៤._

ក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនទេ ក្រុមហ៊ុនត្រូវបោះលក់ចេញយ៉ាងតិចបំផុតមួយពាន់ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុន។ ។

ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នា និងរួមបញ្ចូលនូវសិទ្ធិ :

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

២-ក្នុងការទទួលនូវរាល់ភាគលាភ ដែលបានប្រកាសដោយក្រុមហ៊ុន ។

៣- ក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុន នៅពេលមានការរំលាយ ។

**មាត្រា ១៤៥.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុន អាចចែងឱ្យមានប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ក្នុងករណីនេះ សិទ្ធិនៃប្រភេទរបស់ប័ណ្ណភាគហ៊ុននីមួយៗអាចមានលក្ខណៈដាច់ខាត ឬលក្ខណៈធៀប ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទភាគហ៊ុននីមួយៗ ត្រូវកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ ។ សិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៤៤ ត្រូវភ្ជាប់ដោយឡែក ឬ ទាំងស្រុងទៅនឹងភាគហ៊ុនមួយប្រភេទណាមួយ ។ សិទ្ធិទាំងនោះរួមមាន :

ក-ភាពដែលអាចផ្ទេរបាន ឬភាពដែលអាចផ្លាស់ប្តូរបាននៅក្នុងប្រភេទភាគហ៊ុនមួយផ្សេងទៀត ឬ មូលបត្រផ្សេងទៀតនៃក្រុមហ៊ុនមូលធន ឬ ក្រុមហ៊ុនផ្សេងទៀតអាស្រ័យទៅលើជម្រើសរបស់ក្រុមហ៊ុនមូលធន ឬ អាស្រ័យទៅលើជម្រើសរបស់ម្ចាស់ហ៊ុន ឬអាស្រ័យទៅលើការកើតឡើងនៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ ។

ខ-អាទិភាពនៃការទទួលយកទ្រព្យសម្បត្តិ ដែលសល់ពីការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុនមូលធន ។

គ-ការលោះមកវិញ ការទិញឡើងវិញទៅតាមជម្រើសរបស់ក្រុមហ៊ុនមូលធន ឬ ទៅតាមជម្រើសរបស់អ្នកកាន់កាប់ភាគហ៊ុន ។

ឃ-ការរឹតត្បិតទៅលើភាពដែលអាចផ្ទេរបាន ។

**មាត្រា ១៤៦.-**

ផ្អែកទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងរាល់សិទ្ធិដែលអាចទិញមុនគេរបស់ម្ចាស់ហ៊ុន ភាគហ៊ុន និងមូលបត្រ អាចអនុញ្ញាតឱ្យបោះចេញទៅតាមពេលវេលា និងចំពោះបុគ្គលទាំងឡាយដែលអភិបាលក្រុមហ៊ុនកំណត់ឱ្យ ។

អភិបាលត្រូវកំណត់តម្លៃរបស់ប័ណ្ណភាគហ៊ុន និងតម្លៃមូលបត្រដែលត្រូវលក់ចេញ ។

តម្លៃភាគហ៊ុនមិនត្រូវបោះចេញទេរហូតដល់ការបង់ថ្លៃសម្រាប់ភាគហ៊ុនត្រូវបានបំពេញចប់សព្វគ្រប់ជាសាច់ប្រាក់ ជាវត្ថុ ឬ ជាសេវាពីមុនទៅក្នុងក្រុមហ៊ុន ។

ការបង់ភាគហ៊ុនជាវត្ថុ អាចរួមបញ្ចូលពាណិជ្ជសញ្ញា សិទ្ធិនិពន្ធ ប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិប្រើប្រាស់ទ្រព្យអរូបិយ ឬ សិទ្ធិប្រើប្រាស់លិខិតអនុញ្ញាតពាណិជ្ជសញ្ញា ។

អភិបាលទាំងឡាយកំណត់តម្លៃនៃការដាក់ភាគទុនជាវត្ថុ ឬ ជាសេវាកម្មពីមុននោះ ហើយសេចក្តីសម្រេចរបស់អភិបាលទាំងនេះចាត់ទុកជាបានការប្រសិនបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ ។

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មិនអនុញ្ញាតឱ្យមានភាគទុនជាសេវាទេ ។

**មាត្រា ១៤៧.-**

ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនទាំងឡាយចំពោះបំណុលនៅក្នុងក្រុមហ៊ុនគឺមានកម្រិតត្រឹមតែលើតម្លៃជាវភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ ។

**មាត្រា ១៤៨.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចអនុញ្ញាតឱ្យបោះចេញលើគ្រប់ប្រភេទនៃប័ណ្ណភាគហ៊ុនតាមសេរីមួយ ឬ ច្រើន ។ លក្ខន្តិកៈនេះអាចអនុញ្ញាតឱ្យអភិបាលទាំងឡាយកំណត់ចំនួនប័ណ្ណ និងកំណត់ការបែងចែកសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់

ទៅនឹងប័ណ្ណភាគហ៊ុនក្នុងសេរីនីមួយៗ ដោយអនុលោមទៅតាមការកំណត់ដែលបានធ្វើឡើងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ ។ បើពុំដូច្នេះទេ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត ឬ លក្ខខណ្ឌដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុន ប្រភេទនិងសេរីដូចគ្នា ត្រូវតែមានលក្ខណៈដូចគ្នា ។

**មាត្រា ១៤៩.-**

ក្រុមហ៊ុនត្រូវរក្សាទុកគណនីដើមទុន ដែលបានចុះបញ្ជីប្រកាសដោយឡែកពីគ្នាសម្រាប់ប្រភេទនិងសេរីភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនបានបោះចេញ ។

ក្រុមហ៊ុនត្រូវបន្ថែមទៅក្នុងគណនីដើមទុន ដែលបានប្រកាសនូវការបង់ពេញលេញណាមួយជាសាច់ប្រាក់ ជាវត្ថុ ឬ ជាសេវាពីមុនដែលក្រុមហ៊ុនបានទទួលចំពោះប័ណ្ណភាគហ៊ុនដែលបានបោះចេញ ។

**មាត្រា ១៥០.-**

ពេលណាក្រុមហ៊ុនស្នើសុំបន្ថែមនូវចំនួនណាមួយទៅក្នុងគណនីដើមទុន ដែលបានប្រកាសលើរាល់ប្រភេទ ឬ សេរីនៃភាគហ៊ុន ប្រសិនបើចំនួនដែលត្រូវបន្ថែមនោះក្រុមហ៊ុនមិនបានទទួលគ្រប់ចំនួនទេ ពេលនោះការបន្ថែមចំនួនចូលទៅក្នុងគណនីដើមទុន ត្រូវតែមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ក្រុមប្រឹក្សាភិបាល ។

ក្រុមហ៊ុនមិនអាចបន្ថយគណនីដើមទុនដែលបានប្រកាស ឬ គណនីដើមទុនណាមួយបានឡើយ ។ ក្រុមហ៊ុនអាចបន្ថយគណនីដើមទុនរបស់ខ្លួនបានសម្រាប់គោលបំណងណាមួយតាមរយៈសេចក្តីសម្រេចពិសេស ។ សេចក្តីសម្រេចពិសេស ត្រូវបញ្ជាក់គណនីដើមទុនដែលនឹងត្រូវបន្ថយ ។

ក្រុមហ៊ុនមិនត្រូវបន្ថយគណនីដើមទុនរបស់ខ្លួនទេ ប្រសិនបើមានមូលហេតុដូចខាងក្រោម :

១-ក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលរបស់ខ្លួនបានទេ តាមកាលបរិច្ឆេទដែលបានកំណត់បន្ទាប់ពីការចំណាយ ។

២-តម្លៃទ្រព្យដែលអាចចាត់ស្វាទបានរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល ។

វិធាននេះមិនយកមកអនុវត្តទេ ប្រសិនបើក្រុមហ៊ុនកាត់បន្ថយគណនីដើមទុនរបស់ខ្លួន នូវចំនួនណាមួយដែលមិនពាក់ព័ន្ធដល់ទ្រព្យសម្បត្តិ ដែលអាចទទួលផលបាននៅពេលក្រោយ ។

ម្ចាស់បំណុលរបស់ក្រុមហ៊ុន អាចធ្វើបណ្តឹងទៅតុលាការសុំឱ្យក្រុមហ៊ុនសងមកវិញនូវសាច់ប្រាក់ ឬ ទ្រព្យសម្បត្តិ បន្ទាប់ពីការកាត់បន្ថយគណនីដើមទុនដែលបានធ្វើឡើងផ្ទុយពីមាត្រានេះ ។

បណ្តឹងទាមទារការសងបំណុលដែលបានចែងដោយមាត្រានេះ មិនត្រូវធ្វើឡើងក្រោយរយៈពេលពីរ (០២)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

**មាត្រា ១៥១.-**

បើសិនជាលក្ខន្តិកៈក្រុមហ៊ុនផ្តល់នូវសិទ្ធិអាចទិញបានចំពោះប្រភេទណាមួយនៃប័ណ្ណភាគហ៊ុន គ្មានប័ណ្ណភាគហ៊ុនណាផ្សេងទៀតនៃប្រភេទនោះត្រូវបោះចេញទៀតឡើយ លើកលែងតែម្ចាស់ហ៊ុនដែលមានសិទ្ធិទិញមុនគេត្រូវបានផ្តល់សិទ្ធិដំបូងគេបង្អស់ ។

ម្ចាស់ហ៊ុនមានសិទ្ធិទិញបានមុននូវភាគហ៊ុន ដែលបានដាក់សំណើលក់ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនប្រភេទនោះតាមតម្លៃ និងលក្ខខណ្ឌផ្សេងៗដូចដែលប័ណ្ណភាគហ៊ុនទាំងនោះ ត្រូវបានដាក់សំណើលក់ដល់តតិយជនផងដែរ ។

**មាត្រា ១៥២.-**

ក្រុមហ៊ុនអាចបោះចេញវិញ្ញាបនបត្របញ្ជាក់ពីឯកសិទ្ធិនៃការផ្លាស់ប្តូរ ជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរក្នុងការទទួលមូលបត្ររបស់ក្រុមហ៊ុន ។ នៅក្នុងករណីនេះ វិញ្ញាបនបត្របញ្ជាក់ ឬ ក៏មូលបត្រទាំងឡាយត្រូវកំណត់ចេញនូវលក្ខខណ្ឌ



ស

ដែលអាចអនុវត្តបាននៅក្នុងឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរ ។

ឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរក្នុងការទិញមូលបត្ររបស់ក្រុមហ៊ុនអាចធ្វើឡើងឱ្យមានភាពដែលអាចផ្ទេរបាន ឬ មិនអាចផ្ទេរបាន ហើយជម្រើសនិងសិទ្ធិក្នុងការទិញអាចធ្វើដោយដាច់ពីគ្នា ឬ មិនដាច់ពីគ្នាពីរាល់មូលបត្រ ។

**មាត្រា ១៥៣.-**

ម្ចាស់ហ៊ុនម្នាក់មានសិទ្ធិទទួលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុន ។ នៅលើវិញ្ញាបនបត្រហ៊ុននីមួយៗ ដែលត្រូវបានបោះចេញដោយក្រុមហ៊ុនត្រូវមាននាមករណ៍ក្រុមហ៊ុន ឈ្មោះរបស់បុគ្គលដែលត្រូវបោះចេញឱ្យ ហើយនិងចំនួន និងប្រភេទរបស់ប័ណ្ណភាគហ៊ុន និងការកំណត់នូវរាល់សេរីដែលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុននោះតំណាង ។

**មាត្រា ១៥៤.-**

យោងទៅតាមការរឹតត្បិតនៅក្នុងច្បាប់នេះ និងដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ភាគហ៊ុនទាំងឡាយអាចធ្វើការផ្ទេរបាន ។ ក្រុមហ៊ុនអាចផ្ទេរបាននូវភាគហ៊ុននោះនឹងធ្វើការកត់បញ្ជីទៅក្នុងសៀវភៅ និងបញ្ជីរបស់ក្រុមហ៊ុនទៅតាមសំណើរបស់ភាគីផ្ទេរ និងភាគីទទួល ។

**មាត្រា ១៥៥.-**

ផ្អែកទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រុមហ៊ុនអាចដាវ ឬ ទិញមកវិញនូវភាគហ៊ុនទាំងឡាយដែលបានបោះចេញ ។

ក្រុមហ៊ុនត្រូវមានប័ណ្ណភាគហ៊ុនដែលបោះចេញ យ៉ាងហោចណាស់ក៏មួយប្រភេទនៃប័ណ្ណភាគហ៊ុនដែលមានសិទ្ធិពេញលេញក្នុងសិទ្ធិបោះឆ្នោត និងដែលមិនស្ថិតក្រោមភាពចាំបាច់នៃការទិញមកវិញ ឬ ការលោះមកវិញនោះទេ ។

បើសិនជាប័ណ្ណភាគហ៊ុនត្រូវលោះយកមកវិញ ម្ចាស់ភាគហ៊ុនមានភារកិច្ចប្រគល់ប័ណ្ណភាគហ៊ុនទៅក្រុមហ៊ុនវិញ ដោយទទួលយកមកវិញនូវតម្លៃនៃការលោះនោះ ។ បើសិនជាម្ចាស់ហ៊ុនមិនព្រមប្រគល់ឱ្យវិញ ក្រុមហ៊ុនអាចតក់នូវតម្លៃនៃភាគហ៊ុន ដែលត្រូវលោះទៅក្នុងគណនីដាច់ដោយឡែកទៅក្នុងធនាគារមួយដែលទទួលស្គាល់ដោយក្រុមហ៊ុន ហើយក្រុមហ៊ុនត្រូវផ្ញើនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ហ៊ុននោះ ។ ក្រុមហ៊ុនត្រូវលុបចោលភ្លាមពីសៀវភៅបញ្ជីនូវប័ណ្ណភាគហ៊ុនដែលបានលោះនៅពេលដែលលុយតក់ត្រូវបានទទួល ។ ប៉ុន្តែក្រុមហ៊ុនមិនត្រូវធ្វើការទូទាត់ណាមួយទៅលើការទិញ ឬ ការលោះប័ណ្ណភាគហ៊ុនទេ ដែលបានបោះចេញ ប្រសិនបើមានហេតុផលថា :

១-ក្រោយពេលទិញ ក្រុមហ៊ុនគ្មានលទ្ធភាពក្នុងការសងបំណុលឱ្យទាន់ពេល វេលាទេ ។

២-ក្រោយពេលទិញតម្លៃពិតប្រាកដនៃទ្រព្យរបស់ក្រុមហ៊ុននៅតិចជាងតម្លៃសរុបរបស់បំណុល ។

ប័ណ្ណភាគហ៊ុនដែលបានទិញ និងបានលោះរួចមកហើយ ឬ បានទទួលដោយក្រុមហ៊ុនត្រូវបានលុបចេញ ឬ ប្រសិនបើលក្ខន្តិកៈរបស់ក្រុមហ៊ុនកម្រិតនូវចំនួននៃប័ណ្ណភាគហ៊ុនដែលអនុញ្ញាតឱ្យបោះចេញ ក្រុមហ៊ុនអាចដាក់ប័ណ្ណភាគហ៊ុនក្នុងលក្ខណៈអនុញ្ញាត ប៉ុន្តែពុំទាន់លក់ចេញ ។

**មាត្រា ១៥៦.-**

នៅពេលក្រុមហ៊ុនទិញ លោះមកវិញ ឬ ទទួលភាគហ៊ុនចូលក្រុមហ៊ុនត្រូវធ្វើការកែតម្រូវដោយភ្ជាប់ទៅនឹងគណនីដើមទុនដែលរក្សាទុកសម្រាប់ប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនដែលបានទិញលោះមកវិញ ឬ បានទទួល ។

**មាត្រា ១៥៧.-**

ក្នុងករណីដែលមានការរឹតត្បិតនៅក្នុងលក្ខន្តិកៈ អភិបាលអាចប្រកាសចេញនូវភាគលាភសល់ ឬ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន ។

អភិបាលអាចចាត់ចែងប្រាក់បម្រុងពិសេសមួយភាគ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដោយប្រើប្រាស់មូលនិធិណាមួយរបស់ក្រុមហ៊ុនដែលមានសម្រាប់បែងចែកភាគលាភ ។

**មាត្រា ១៥៨.-**

ក្រុមហ៊ុនមិនអាចប្រកាស ឬ បែងចែកភាគលាភបានទេ ប្រសិនបើក្រុមហ៊ុនមានមូលហេតុសមហេតុសមផលដើម្បីធ្វើឱ្យជឿថា :

ក-ក្រោយពីការបែងចែកភាគលាភនោះ ក្រុមហ៊ុនគ្មានលទ្ធភាពសងបំណុលដូចដែលបានកំណត់ឱ្យសងនោះទេ ។

ខ-តម្លៃដែលអាចប៉ាន់ស្មានបាននៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល និងដើមទុន ប្រកាសរបស់ភាគហ៊ុនគ្រប់ប្រភេទ ។

**មាត្រា ១៥៩.-**

ក្រុមហ៊ុនអាចបែងចែកភាគលាភ ដោយធ្វើការបោះចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុន ។ ផ្អែកតាមការរឹតត្បិតនៅក្នុងផ្នែកនេះ ក្រុមហ៊ុនអាចបែងចែកភាគលាភជាសាច់ប្រាក់ ឬ ជាទ្រព្យសម្បត្តិបាន ។

**មាត្រា ១៦០.-**

ប្រសិនបើប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានបោះចេញដើម្បីទូទាត់ភាគ-លាភ ចំនួនភាគលាភដែលបានប្រកាសបញ្ជាក់ចំនួនសាច់ប្រាក់ត្រូវបន្ថែមទៅក្នុងគណនីដើមទុន ឬ ត្រូវបានរក្សាទុកសម្រាប់ប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនដែលបានបោះចេញដើម្បីទូទាត់ភាគលាភនោះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣០៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣០៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម/០៦០៥/០១៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ហត្ថលេខា**
**ចម ប្រសិទ្ធ**

លេខ: ២៥៥ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាខី តាន់

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ក្រមរដ្ឋប្បវេណី

៣-ក្នុងករណីដែលភាគីបានយកប្រាក់ធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន បើមានការយឺតយ៉ាវក្នុងការបង់ប្រាក់នោះ ក្រៅពីត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ក៏ត្រូវបង់ទៅលើការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវនោះ ចំពោះក្រុមហ៊ុនផងដែរ ។

៤-ក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយ ក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុន ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) ជំពូកទី ២ នៃគន្ថីទី ៤ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះ ត្រូវបានបង្កើត ដោយភាគីដទៃទៀត ។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនពុំអាចសម្រេចគោលបំណងបាន ដោយសារកង្វះភាគីនោះ ត្រូវចាត់ទុកថាក្រុមហ៊ុននោះ ពុំត្រូវបានបង្កើតឡើយ ។

**មាត្រា ៧០១.–** កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន

១-ទ្រព្យធនវិនិយោគរបស់សមាជិកក្រុមហ៊ុននីមួយៗ និង ទ្រព្យសម្បត្តិក្រុមហ៊ុនផ្សេងៗទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។

២-សមាជិកក្រុមហ៊ុន ពុំអាចទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្រុមហ៊ុន នៅមុនពេលធ្វើការជម្រះបញ្ជីរបស់ក្រុមហ៊ុន បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន មានការព្រមព្រៀង ទោះបីជានៅមុនពេលធ្វើការជម្រះបញ្ជីក៏ដោយ ក៏អាចទាមទារឱ្យបែងចែកបានដែរ ។

៣-ការបែងចែកដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ខាងលើនេះ ពុំអាចយកមកតតាំងចំពោះតតិយជន ដែលបានធ្វើជំនួញជាមួយនឹងក្រុមហ៊ុន នៅមុនពេលធ្វើការបែងចែកនោះបានឡើយ ។

៤-សមាជិកក្រុមហ៊ុន ពុំអាចចាត់ចែងភាគដែលខ្លួនមាន ចំពោះទ្រព្យសម្បត្តិក្រុមហ៊ុននោះ បានឡើយ ។

**មាត្រា ៧០២.–** វិធីអនុវត្តកិច្ចការ

១-ក្នុងករណីដែលពុំបានកំណត់សមាជិកក្រុមហ៊ុន ឬ តតិយជនទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ សមាជិកនីមួយៗនៃក្រុមហ៊ុន មានសិទ្ធិ

អំណាចអនុវត្តកិច្ចការរបស់ក្រុមហ៊ុននោះ ។ ប៉ុន្តែ ការអនុវត្តកិច្ចការក្រុមហ៊ុន ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

២-ប្រសិនបើបានកំណត់ថាសមាជិកក្រុមហ៊ុន ឬ តតិយជនដែលទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវមានច្រើននាក់ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

៣-ទោះបីមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ សមាជិកក្រុមហ៊ុននីមួយៗ ឬ អ្នកអនុវត្តកិច្ចការម្នាក់ៗ អាចអនុវត្តកិច្ចការប្រក្រតីរបស់ក្រុមហ៊ុនដោយឯកតោភាគីបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើសមាជិកនៃក្រុមហ៊ុន ឬ អ្នកអនុវត្តកិច្ចការផ្សេងទៀត បានបញ្ចេញមតិតវ៉ា នៅមុនពេលបញ្ចប់កិច្ចការនោះ ។

**មាត្រា ៧០៣.–** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។

**មាត្រា ៧០៤.–** ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ

១-ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ ពុំអាចលាឈប់ ឬ ត្រូវបញ្ឈប់បានឡើយ ។

២-ដើម្បីបញ្ឈប់សមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ដោយមានមូលហេតុត្រឹមត្រូវ ត្រូវមានសម្លេងយល់ព្រម លើសពីពាក់កណ្តាលនៃចំនួនសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

**មាត្រា ៧០៥.–** សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិ

ទោះបីជាគ្មានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនក៏ដោយ ក៏សមាជិក

នីមួយៗរបស់ក្រុមហ៊ុន អាចធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ បានដែរ ។

**មាត្រា ៧០៦.–** សិទ្ធិទាមទារចែកចំណេញ ភាគនៃការបែងចែកការចំណេញ ខាត

១-សមាជិកក្រុមហ៊ុន ត្រូវគណនាការចំណេញ ខាត នៅក្នុងអំឡុងពេលទៀងទាត់ ហើយក្នុងករណីដែលមានចំណេញ អាចទាមទារឱ្យបែងចែកផលចំណេញនោះបាន ។

២-ប្រសិនបើសមាជិកក្រុមហ៊ុន មិនបានកំណត់ភាគនៃការបែងចែកការចំណេញ ខាតទេ ត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកនីមួយៗនៃក្រុមហ៊ុននោះ ។

៣-ប្រសិនបើបានកំណត់តែភាគនៃការបែងចែកចំពោះការចំណេញ ខាតណាមួយ ត្រូវសន្មតថាភាគនោះ ដូចគ្នាទៅនឹងការខាតបង់ និង ការចំណេញ ។

**មាត្រា ៧០៧.–** ភាគដែលត្រូវទទួលបន្ទុកនៃការខាតបង់របស់សមាជិកក្រុមហ៊ុន ចំពោះម្ចាស់បំណុល

១-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាព ។ ប៉ុន្តែ កាតព្វកិច្ចនោះ ត្រូវសងដោយទ្រព្យសម្បត្តិក្រុមហ៊ុនសិន ហើយប្រសិនបើមិនអាចសងកាតព្វកិច្ចទាំងអស់ ដោយទ្រព្យសម្បត្តិក្រុមហ៊ុន ទើបសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ ។

២-បន្ទុករបស់សមាជិកនីមួយៗ ត្រូវអនុលោមតាមសមាមាត្រនៃភាគវិនិយោគ លើកលែងតែមានការសន្យាពិសេស ។

**មាត្រា ៧០៨.–** ការហាមឃាត់មិនឱ្យទូទាត់កាតព្វកិច្ចក្រុមហ៊ុន

កូនបំណុលរបស់ក្រុមហ៊ុន ពុំអាចទូទាត់កាតព្វកិច្ចនោះ ជាមួយនឹងសិទ្ធិលើបំណុលចំពោះសមាជិកនីមួយៗនៃក្រុមហ៊ុន បានឡើយ ។

**មាត្រា ៧០៩.–** ការដកខ្លួនដោយស្ម័គ្រចិត្ត

១-ប្រសិនបើពុំបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុននៅក្នុងកិច្ចសន្យា

ក្រុមហ៊ុនទេ ឬ បើបានកំណត់អត្ថិភាពដែលក្រុមហ៊ុនត្រូវមាន ក្នុងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកនីមួយៗ អាចដកខ្លួនចេញ នៅពេលណាក៏បាន ។ ប៉ុន្តែ ការដកខ្លួននេះ ពុំអាចធ្វើបានឡើយ បើបណ្តាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន លើកលែងតែក្នុងករណីដែលពុំអាចជៀសវាងបាន ។

២-ទោះបីជាបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនក៏ដោយ នៅក្នុងករណីដែលពុំអាចជៀសវាងបាន សមាជិកនីមួយៗ អាចដកខ្លួនបាន ។

៣-ការដកខ្លួនអាចធ្វើទៅបាន ដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន ។

**មាត្រា ៧១០.–** ការដកខ្លួនតាមច្បាប់

ក្រៅពីបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា ៧០៩ (ការដកខ្លួនដោយស្ម័គ្រចិត្ត) ខាងលើ សមាជិកក្រុមហ៊ុន ត្រូវដកខ្លួន ដោយមូលហេតុណាមួយ ដូចខាងក្រោមនេះ :

ក-មរណភាព ។

ខ-ធនក្ស័យ ។

គ-បានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ។

ឃ-ការលុបឈ្មោះ ។

**មាត្រា ៧១១.–** ការលុបឈ្មោះ

ការលុបឈ្មោះសមាជិកក្រុមហ៊ុន អាចអនុវត្តបាន ដោយមតិយល់ព្រមជាឯកច្ឆន្ទពីសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន តែក្នុងករណីដែលមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ ។ ប៉ុន្តែ បើមិនបានជូនដំណឹងពីការលុបឈ្មោះ ដល់សមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះទេ ពុំអាចយកទៅតតាំងជាមួយនឹងសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះនោះ បានឡើយ ។

**មាត្រា ៧១២.–** ការសងវិញ នូវចំណែករបស់សមាជិកក្រុមហ៊ុន ដែលដកខ្លួន

១-ការគណនារវាងសមាជិកក្រុមហ៊ុនដែលបានដកខ្លួន និង សមាជិកផ្សេងទៀត

របស់ក្រុមហ៊ុន ចាំបាច់ត្រូវអនុវត្ត ដោយផ្អែកតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន នៅពេលដែលដកខ្លួននោះ ។

២-ចំណែកដែលសមាជិកក្រុមហ៊ុនដែលបានដកខ្លួននោះមាន អាចសងវិញជាប្រាក់បាន ដោយពុំគិតពីប្រភេទនៃទ្រព្យធនដែលវិនិយោគនោះឡើយ ។

៣-ចំពោះចំណុចដែលពុំទាន់បានបញ្ចប់ នៅពេលដកខ្លួន អាចគណនាបាន នៅក្រោយពេលធ្វើការបញ្ចប់នោះ ។

៤-ការសងចំណែកដែលមាន ទៅសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះ ត្រូវភ្ជាប់ការប្រាក់ តាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ចំពោះអំឡុងពេលគិតចាប់ពីពេលដែលបានជូនដំណឹងអំពីការលុបឈ្មោះ រហូតដល់ពេលដែលបានសងវិញ ។

**មាត្រា ៧១៣.–** ការរំលាយក្រុមហ៊ុន

១-ក្រុមហ៊ុន ត្រូវរំលាយតាមករណីណាមួយ ដូចកំណត់ខាងក្រោមនេះ :

ក-ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុន ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

ខ-បើមានការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន ។

គ-បើនៅសល់សមាជិកក្រុមហ៊ុន តែម្នាក់ ។

ឃ-បើអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបញ្ចប់ ។

២-ក្នុងករណីដែលមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចទាមទារឱ្យរំលាយក្រុមហ៊ុនបាន ។

៣-ការទាមទារនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់ របស់ក្រុមហ៊ុន ។

**មាត្រា ៧១៤.–** ភាពគ្មានប្រតិសកម្មនៃការរំលាយ

ការរំលាយក្រុមហ៊ុន ពុំមានអានុភាពប្រតិសកម្មឡើយ ។

**មាត្រា ៧១៥.–** អ្នកជម្រះបញ្ជី

១-ប្រសិនបើក្រុមហ៊ុនត្រូវបានរំលាយ ការជម្រះបញ្ជីត្រូវធ្វើ ដោយសហការគ្នារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុន ឬ ដោយអ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំងដោយសមាជិកក្រុមហ៊ុន ។

២-ការជ្រើសតាំងអ្នកជម្រះបញ្ជីនៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលគ្មានកំណត់ពិសេសនៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកក្រុមហ៊ុននោះ ។

**មាត្រា ៧១៦.–** ការអនុវត្តកិច្ចការរបស់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០២ (វិធីអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអ្នកជម្រះបញ្ជី មានចំនួនច្រើននាក់ ។

**មាត្រា ៧១៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០៤ (ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន បានព្រមព្រៀងជ្រើសតាំងអ្នកជម្រះបញ្ជី ពីក្នុងចំណោមសមាជិកក្រុមហ៊ុននោះ ។

**មាត្រា ៧១៨.–** មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី វិធីបែងចែកទ្រព្យសម្បត្តិដែលនៅសេសសល់

១-បញ្ញត្តិនៃមាត្រា ៧១ (មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទី និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី ។

២-ទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវបែងចែកដោយសមាមាត្រតាមតម្លៃនៃទ្រព្យធនដែលសមាជិកនីមួយៗរបស់ក្រុមហ៊ុន បានវិនិយោគ ។

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

## ជំពូកតោល

## អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.– កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ឧ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
ចារ.ល.០៧១២.៦២២ **ហត្ថលេខា និងព្រះរាជលញ្ចករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខៈ៥៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧ ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**យុន ជិនគេន**

453/453

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៨៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងសម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីចូលរួមចំណែកលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងទាក់ទាញការវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌតម្រូវ និងការអនុញ្ញាតដល់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដែលក្នុងនោះមាន៖

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ការពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## នីតិវិធីនៃការចុះបញ្ជីអាជីវកម្ម និង ការពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាន និងឯកសារភ្ជាប់

**មាត្រា ៥.-**

បុគ្គលស្នើសុំ ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវទាំងអស់ ក្នុងទម្រង់អេឡិចត្រូនិក ដែលកំណត់ក្នុងគេហទំព័រចុះបញ្ជី https://www.registrationservices.gov.kh។

បុគ្គលស្នើសុំ អាចផ្ទេរសិទ្ធិឱ្យអ្នកតំណាងចុះបញ្ជី ដើម្បីធ្វើការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះក្នុងនាមបុគ្គលស្នើសុំ ដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិ ឬ/និង ឯកសារពាក់ព័ន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦.-**

ព័ត៌មាននិងឯកសារភ្ជាប់ស្នើសុំចុះបញ្ជីអាជីវកម្ម ដែលបានបំពេញដោយបុគ្គលស្នើសុំ សម្រាប់តម្កល់តាមក្រសួង-ស្ថាប័នមានសមត្ថកិច្ចជាទម្រង់អេឡិចត្រូនិក ត្រូវបញ្ជូនដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការពិនិត្យ និងសម្រេចផ្តល់ការអនុញ្ញាតការចុះបញ្ជីអាជីវកម្ម។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារភ្ជាប់ តាមសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួង-ស្ថាប័ននីមួយៗ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយអនុលោមតាមអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីព័ត៌មាន និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬ/និងមិនគ្រប់គ្រាន់ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវជូនដំណឹងដល់បុគ្គលស្នើសុំ ដើម្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែម។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តល់វិញ្ញាបនបត្រឬលិខិតបញ្ជាក់ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែម។

**មាត្រា ៧.-**

កម្រៃសេវាពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ កម្រៃសេវានេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

## ជំពូកទី៣

## ការផ្តល់ ព្យួរ និងដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់
## របស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈគេហទំព័រចុះបញ្ជី

### ផ្នែកទី១

### ការផ្តល់វិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ៨.-**

ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបាន សម្រាប់ប្រើប្រាស់ជាផ្លូវការ តាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ៩.-**

ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្មដោយក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវលើព័ត៌មាននិងឯកសារភ្ជាប់ និងត្រូវផ្តល់ការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជី សម្រាប់ប្រើប្រាស់ជាផ្លូវការ រួមមាន ប័ណ្ណពន្ធប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ និងលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

ក្នុងគោលបំណងលើកទឹកចិត្តនិងជំរុញការចុះបញ្ជីពន្ធដារ អ្នកជាប់ពន្ធគ្រប់ប្រភេទត្រូវបង់ពន្ធប៉ាតង់ត្រឹមតែ ៥០ (ហាសិប) ភាគរយនៃប្រាក់ពន្ធប៉ាតង់ដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានប៉ុណ្ណោះ សម្រាប់ឆ្នាំដែលធ្វើការចុះបញ្ជីអាជីវកម្ម។ ប្រាក់ពន្ធប៉ាតង់នេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល បុគ្គលស្នើសុំត្រូវផ្តល់ព័ត៌មានអំពីគណនីធនាគារជូនអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារក្នុងកថាខណ្ឌទី១ខាងលើ ត្រូវបានដកហូតដោយស្វ័យប្រវត្តិ។

**មាត្រា ១០.-**

បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីពន្ធដារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយផ្តល់នូវការចុះលេខរដ្ឋបាលនៃការទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនេះ តាមគេហទំព័រចុះបញ្ជីក្នុងរយៈពេល ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ករណីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនបានពិនិត្យនិងផ្តល់នូវការចុះលេខរដ្ឋបាលនៃការទទួលសេចក្តីប្រកាសនេះ ក្នុងរយៈពេល ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការទេ សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ត្រូវបានចាត់ទុកថា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនេះ ដោយស្វ័យប្រវត្តិ។

ការទទួលយកសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសរបស់បុគ្គលស្នើសុំ តាមទម្រង់ឌីជីថលនេះ អាចបោះពុម្ពបានដោយបុគ្គលស្នើសុំ សម្រាប់ប្រើប្រាស់ជាផ្លូវការ បន្ទាប់ពីបានបំពេញលក្ខខណ្ឌពេញលេញនិងត្រឹមត្រូវតាមគេហទំព័រចុះបញ្ជី ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១១.-**

ក្នុងរយៈពេលយ៉ាងយូរ ២០ (ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ និងប្រសិនបើគម្រោងដែលស្នើសុំនេះមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមានទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាននិងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីគម្រោងតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានសម្រាប់ប្រើប្រាស់ជាផ្លូវការ ជូនបុគ្គលស្នើសុំតាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ១២.-**

វិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ ក្នុងទម្រង់ឌីជីថល ត្រូវបានបង្កើតឡើងដោយអាចរកប្រភព និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវបានតាមលេខអត្តសញ្ញាណសហគ្រាស តាមគេហទំព័រចុះបញ្ជី ឬនៅតាមក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា ១៣.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចចេញប្រកាស ឬគោលការណ៍ណែនាំ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ផ្នែកទី២

## ការព្យួរ ឬការដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ១៤.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចព្យួរឬដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ ក្នុងករណីបុគ្គលស្នើសុំ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- មិនគោរព ឬមិនបន្តគោរពតាមលក្ខខណ្ឌតម្រូវវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ ដូចកំណត់ក្នុងអនុក្រឹត្យនេះ

២- បានផ្តល់ព័ត៌មានមិនពិត ឬប្រើឯកសារក្លែងក្លាយ

៣- ប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីព្យួរ ដកហូតឬលុបចោលនូវវិញ្ញាបនបត្រ និងលិខិតបញ្ជាក់នានា ត្រូវអនុលោមតាមអនុក្រឹត្យនេះ និងតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី៤

## ការអះអាងភាពត្រឹមត្រូវនៃព័ត៌មានចុះបញ្ជី ក្រមសីលធម៌វិជ្ជាជីវៈ និងការរក្សាការសម្ងាត់

**មាត្រា ១៥.-**

បុគ្គលស្នើសុំ ត្រូវធានាអះអាង តាមទម្រង់អេឡិចត្រូនិក ថាព័ត៌មានស្នើសុំចុះបញ្ជីអាជីវកម្ម និងឯកសារភ្ជាប់ដែលខ្លួនបានបំពេញ និងបញ្ចូលទៅក្នុងគេហទំព័រចុះបញ្ជី ពិតជាព័ត៌មាននិងឯកសារត្រឹមត្រូវនិងមិនក្លែងបន្លំ។ ក្នុងករណីព័ត៌មាននិងឯកសារទាំងនោះ មិនត្រឹមត្រូវឬមានការក្លែងបន្លំ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១៦.-**

អ្នកតំណាងចុះបញ្ជី ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដូចខាងក្រោម÷

១- មានភាពសុចរិត និងភាពស្មោះត្រង់ក្នុងការប្រកបអាជីវកម្ម

២- ផ្តល់សេវាប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់

៣- បំពេញភារកិច្ចដោយគិតដល់ប្រយោជន៍របស់អតិថិជនជាចម្បង

៤- ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជន

៥- ត្រូវជៀសវាងមិនឱ្យមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន ឬមានវិធានការសមស្រប ដើម្បីការពារដល់ផលប្រយោជន៍អតិថិជន និងត្រូវជូនដំណឹងជាមុនដល់អតិថិជន ក្នុងករណីដែលមានទំនាស់ផលប្រយោជន៍។

អ្នកតំណាងចុះបញ្ជី ត្រូវរក្សាការសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់សម្រាប់ចុះបញ្ជីអាជីវកម្មដែលតម្រូវដោយអនុក្រឹត្យនេះ ដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយអតិថិជន។

**មាត្រា ១៧.-**

មន្ត្រីអនុវត្តការងារពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈដែលកំណត់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត។ មន្ត្រីពាក់ព័ន្ធទាំងនេះ ត្រូវរក្សាការសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់ដែលតម្រូវក្នុងអនុក្រឹត្យនេះ ដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គលស្នើសុំ ឬអ្នកតំណាងចុះបញ្ជី។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវមាននីតិវិធី មធ្យោបាយ និងយន្តការផ្ទៃក្នុង ដើម្បីរក្សាការសម្ងាត់នូវរាល់ព័ត៌មាននិងឯកសាររបស់បុគ្គលស្នើសុំ។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចរៀបចំប្រកាសអន្តរក្រសួង ដើម្បីគ្រប់គ្រងព័ត៌មាន និងឯកសារភ្ជាប់ដែលតម្រូវដោយអនុក្រឹត្យនេះ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥ រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

## នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២០

## សទ្ទានុក្រម

**១.បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ ដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**២.អ្នកតំណាងចុះបញ្ជី** សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងទទួលបានការផ្ទេរសិទ្ធិពីបុគ្គលស្នើសុំ ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ ដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវព័ត៌មានដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៣.ការចុះបញ្ជីអាជីវកម្ម** សំដៅដល់ការចុះបញ្ជីអាជីវកម្ម តាមគេហទំព័រចុះបញ្ជី តាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដើម្បីទទួលបាន ក្នុងទម្រង់ឌីជីថលនូវ÷

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**៤.គេហទំព័រចុះបញ្ជី** សំដៅដល់គេហទំព័ររួមមួយ សម្រាប់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងទម្រង់អេឡិចត្រូនិក ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**៥.លេខអត្តសញ្ញាណសហគ្រាស** សំដៅដល់លេខបញ្ជាក់អត្តសញ្ញាណសហគ្រាស ដែលផ្តល់ឱ្យដោយប្រព័ន្ធស្វ័យប្រវត្តិស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៦.ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (Cambodia Data Exchange - CamDX) សំដៅដល់ថ្នាលបច្ចេក-វិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានាដោយសុវត្ថិភាព និងដោយយន្តការច្បាស់លាស់ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ក្នុងគោលដៅតភ្ជាប់ជាប្រព័ន្ធរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថល។

**៧.ទម្រង់អេឡិចត្រូនិក** សំដៅដល់ព័ត៌មាន ឬទិន្នន័យ ដែលអាចយកមកដំណើការដោយកុំព្យូទ័រ ធ្វើការកែប្រែ និងចែករំលែក រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**៨.ឯកសារទម្រង់ឌីជីថល** សំដៅដល់ឯកសារដែលមានទម្រង់ជា Portable Document Format (PDF) ឬរូបភាព សម្រាប់ប្រើប្រាស់ជាឯកសារយោងឬភ្ជាប់ដែលបានស្កែន ឬថតចេញពីឯកសាររូបី ឬឯកសារដែលមានទម្រង់ជា PDF ឬរូបភាព ដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

**៩.លិខិតបញ្ជាក់** សំដៅដល់ការបញ្ជាក់ក្នុងទម្រង់ឌីជីថល ដូចខាងក្រោម៖

- ប័ណ្ណពន្ធប៉ាតង់ ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការទទួលនូវសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

# បើកអាជីវកម្មរបស់លោកអ្នកក្នុងប្រទេសកម្ពុជាថ្ងៃនេះ ដោយប្រើប្រាស់តែ

## ៧ ជំហាន ប៉ុណ្ណោះ

ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

១



ចូលទៅកាន់ **www.registrationservices.gov.kh**
រួចចុច "ចុះបញ្ជីអាជីវកម្ម"។

២



បង្កើតគណនីលើកម្មវិធី **CamDigiKey**។
រំលងជំហាននេះ ប្រសិនបើអ្នកមានគណនីរួចរាល់។

៣




**Login** ដោយប្រើប្រាស់កម្មវិធី **CamDigiKey**។

៤



បំពេញព័ត៌មាន និងភ្ជាប់ឯកសារចាំបាច់។

៥



ទូទាត់សងប្រាក់តាមមធ្យោបាយ
ទូទាត់សងប្រាក់អនឡាញដែលមានស្រាប់។

៦



ទទួលបានការសម្រេចចិត្តក្នុងរយៈពេល
៨ ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ។ អ្នកអាច
ត្រូវបានស្នើសុំឯកសារបន្ថែម។

៧



ទាញយក និងបោះពុម្ពអាជ្ញាបណ្ណ/ វិញ្ញាបនបត្រ
ឌីជីថលចំនួន ៥ និងប័ណ្ណពន្ធប៉ាតង់ ប្រសិនបើទទួលបានការអនុញ្ញាត។

# កម្រៃ និងពន្ធសម្រាប់ការចុះបញ្ជីអាជីវកម្មថ្មី



## • ក្រសួងពាណិជ្ជកម្ម

| | |
|---|---|
| ក្រុមហ៊ុនមូលធន | ១.០១ លានរៀល |
| ក្រុមហ៊ុនបរទេស | ១.០១ លានរៀល |
| ក្រុមហ៊ុនសហកម្មសិទ្ធិ | ១.០១ លានរៀល |
| សហគ្រាសឯកបុគ្គល | ១៨០ ពាន់រៀល |

## • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| | |
|---|---|
| កម្រៃលើការចុះបញ្ជិកា សេចក្តីជូនដំណឹង បើកសហគ្រាស | ១២០ ពាន់រៀល |

## • អគ្គនាយកដ្ឋានពន្ធដារ

### • ពន្ធប៉ាតង់សម្រាប់សកម្មភាពអាជីវកម្មមួយ

(សម្រាប់តែឆ្នាំដំបូងប៉ុណ្ណោះ)

| | |
|---|---|
| អ្នកជាប់ពន្ធតូច | ២០០ ពាន់រៀល |
| អ្នកជាប់ពន្ធមធ្យម | ៦០០ ពាន់រៀល |
| អ្នកជាប់ពន្ធធំ | ១.៥ លានរៀល (ករណី ៤ ពាន់លានរៀល < ផលរបរ ≤ ១០ពាន់លានរៀល)<br>២.៥ លានរៀល (ករណីផលរបរ > ១០ ពាន់លានរៀល) |

### • កម្រៃចុះបញ្ជីពន្ធដារ

| | |
|---|---|
| អ្នកជាប់ពន្ធតូច | ២០ ពាន់រៀល |
| អ្នកជាប់ពន្ធមធ្យម | ៤០០ ពាន់រៀល |
| អ្នកជាប់ពន្ធធំ | ៤០០ ពាន់រៀល |


ទំនាក់ទំនងមកយើងខ្ញុំ
ទូរស័ព្ទ : (+៨៥៥) ៨១ ៨៨៨ ២៩៦
អ៊ីម៉ែល : registrationservices@mef.gov.kh
គេហទំព័រ : www.registrationservices.gov.kh